# សូមថ្វាយព្រះរាជសព្ទសាធុការពរ បវរមហាប្រសើរ

## នៅក្នុងឱកាសដ៏មហានក្ខត្តឫក្ស នៃព្រះរាជពិធីបុណ្យចំរើនព្រះជន្ម

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី

## ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

## គម្រប់ព្រះជន្ម ៦១ យាងចូល ៦២ ព្រះវស្សា

( ១៤.០៥.១៩៥៣ - ១៤.០៥.២០១៤ )



ទូលព្រះបង្គំយើងខ្ញុំ សូមឧទ្ទិសបួងសួងគុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិនានាក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆត្រ និងព្រះវិញ្ញាណក្ខន្ធនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមជួយគ្រោះព្រំ គាំពារថែរក្សាព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមមានព្រះរាជសុខភាពបរិបូរ ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ក្នុងព្រះសិរីរាជសម្បត្តិ ជានិមិត្តរូបដ៏ខ្ពង់ខ្ពស់បំផុតនៃ ឯករាជ្យ ឯកភាពជាតិ អធិបតេយ្យជាតិ បូរណភាពទឹកដី វឌ្ឍនភាព និងវិបុលភាព នៃព្រះរាជាណាចក្រកម្ពុជា និងជាម្លប់ដ៏ត្រជាក់នៃប្រជារាស្ត្រខ្មែរតរៀងទៅ ។

*សូមក្រាបបង្គំទូលថ្វាយដោយភក្តីភាពគតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត*

*ទស្សនាវដ្តីប្រជាជន*

# សូមប្រសិទ្ធពរបវរមហាប្រសើរជូន



## សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

## ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា

## និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជាជាទីគោរពដ៏ខ្ពង់ខ្ពស់ !

### ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាគម្រប់ជន្មាយុ ៨០ ឈានចូល ៨១ វស្សា របស់សម្តេច

សូមលំឱនកាយគោរពដោយក្តីដឹងគុណដ៏ជ្រាលជ្រៅបំផុត សម្តេចជាវីរកុលបុត្រខ្មែរដ៏ឆ្នើម និងជារដ្ឋបុរសដ៏ឧត្តុង្គឧត្តម ដែលបានលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាញាណ ដើម្បីដឹកនាំមាតុភូមិកម្ពុជាសម្រេចបានជោគជ័យដ៏ធំធេងជាប្រវត្តិសាស្ត្រជូនជាតិនិងប្រជាជនតាំងពីដំណាក់កាលសង្គ្រោះជាតិរហូតមកដល់ដំណាក់កាលសន្តិភាពប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ ។

សូមឧទ្ទិសបួងសួងគុណបុណ្យព្រះរតនត្រ័យ ទេវតាឆ្នាំថ្មី និងវត្ថុស័ក្តិសិទ្ធិ ទាំងឡាយក្នុងលោក ព្រមទាំងតេជះបារមីនៃវិញ្ញាណក្ខន្ធរបស់បុព្វវីរបុរសខ្មែរគ្រប់ៗជំនាន់សូមតាមជួយប្រោះព្រំគាំពារថែរក្សាសម្តេចនិងលោកជំទាវ សូមបានប្រកបនូវពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ ជា រៀងដរាប ។

*គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត*

*ទស្សនាវដ្តីប្រជាជន*

វិចារណកថា
EDITORIAL

# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ អាណត្តិទីពីរ ជាជំហានថ្មីមួយទៀតនៃដំណើរការប្រជាធិបតេយ្យ និងនីតិរដ្ឋរបស់កម្ពុជា

# Municipal and District Council Elections – a New Step in Cambodia's Democratic Process and Rule of Law

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី២នឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ខែឧសភាឆ្នាំ២០១៤ ខាងមុខនេះ ដែលជាការបោះឆ្នោតបែបអសកល ដោយមានសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ កំពុងស្ថិតក្នុងតំណែងជាអង្គបោះឆ្នោត ។ ថ្វីត្បិតតែជាការបោះឆ្នោតអសកល ប៉ុន្តែគឺជាការបោះឆ្នោតដែលតំណាងឱ្យឆន្ទៈរបស់ប្រជាជនពិតប្រាកដ ពីព្រោះថាក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយប្រជាជនផ្ទាល់ ។

ការបោះឆ្នោតថ្នាក់ក្រោមជាតិនាពេលនេះ គឺជាព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រមួយថ្មីទៀតនៃព្រះរាជាណាចក្រកម្ពុជា ក្រោយពីការអនុវត្តដោយជោគជ័យនូវការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី ៣ កាលពីថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៣ នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ នាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅ ។ គណបក្សប្រជាជនកម្ពុជាបានទទួលជោគជ័យនៅក្នុងការបោះឆ្នោតទាំងនេះ ដែលបង្ហាញច្បាស់ថា ប្រជាជនកម្ពុជាត្រូវការចាំបាច់នូវតួនាទីដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាតទៅមុខទៀត ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាណត្តិទីពីរនេះ ក៏ជាការតស៊ូខាងនយោបាយដ៏សំខាន់មួយទៀតរបស់គណបក្សប្រជាជនកម្ពុជាជាមួយនឹងគណបក្សដទៃ ក្នុងស្ថានភាពនៃការប្រកួតប្រជែងដោយសេរី ដែលមានលក្ខណៈកាន់តែតឹងតែង និងស្មុគស្មាញឡើង ។ ប៉ុន្តែទោះជាយ៉ាងណាក្តីក៏គណបក្សប្រជាជនកម្ពុជានៅតែមានមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការឆ្លើយតបទៅនឹងការវិវត្តនានា អាស្រ័យដោយមានការគាំទ្រពីសំណាក់ប្រជាជនភាគច្រើនដាច់ខាត មានគោលនយោបាយច្បាស់លាស់ និងត្រឹមត្រូវ មានឆន្ទៈមុតស្រួច និងបទពិសោធន៍ក្នុងការដឹកនាំ មានជួរមន្ត្រីដ៏ស្មោះត្រង់របស់គណបក្សនៅមូលដ្ឋាន ជាពិសេសមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបន្តអនុវត្តនូវរាល់កំណែទម្រង់ដ៏ស៊ីជម្រៅទាំងក្នុងវិស័យនយោបាយ ច្បាប់ ប្រព័ន្ធ យុត្តិធម៌ សេដ្ឋកិច្ច

The forthcoming second-term municipal and district council elections will take place on 18 May 2014. It will be a non- universal suffrage to be carried out by incumbent members of the communal councils. Though a non-universal suffrage, the elections will still represent the true will of the people because they have elected every member of the communal councils.

The sub-national elections is a new historic event of the Kingdom of Cambodia after successfully implementing the elections of members of the third legislative term of the Senate on 29 January 2012; the third communal councils elections on 3 June 2012 and the fifth legislative term of the National Assembly on 28 July 2013. That the Cambodian People's Party won the victories in those elections clearly indicates that the people of Cambodia still need the leadership role of the Cambodian People's Party in both national and local levels.

The second-term elections of the municipal and district councils is in fact a new and important political struggle of the Cambodian People's Party versus others in a free, but tougher and more complicated competition. Nevertheless, the Cambodian People's Party maintains a strong foundation in responding to every development for the fact that it has the support from the absolute majority of the people; holds clear and just policies; and possesses sharpened will and leadership experiences. Moreover, the Party sustains a good number of faithful officials who are members of the Party at local level, and especially determined to continue implementing deep reforms in the field of politics, law, judicial system, socio-economic development, while fighting against corruption to uproot obstacles that hinder development and raise high the people's well being.

Over the past 35 years, the Cambodian People's Party fulfills its central leadership role to realize numerous historic achievements for the country. The people of Cambodia have gone through together many turns in the past three decades and understood the Party's stance of faithfulness, courage and wisdom in its leadership. Those achievements bring about the supreme pride for every Cambodian, especially for

សង្គមកិច្ច និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដើម្បីគាស់រំលើងឱ្យខាងតែបាននូវឧបសគ្គនានា ដែលរារាំងដល់ការអភិវឌ្ឍ និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ។

រយៈពេលជាង ៣៥ ឆ្នាំកន្លងទៅ គណបក្សប្រជាជនកម្ពុជា បានបំពេញតួនាទីជាស្នូលក្នុងការដឹកនាំប្រទេសសម្រេចបានសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រយ៉ាងច្រើនជូនជាតិ ។ ប្រជាជនកម្ពុជាដែលបានរួមដំណើរឆ្លងកាត់នូវភាពបត់បែននៃដំណើរជាតិកម្ពុជាជាង ៣ ទសវត្សមកនេះ សុទ្ធតែបានឃើញ បានយល់អំពីជំហរស្មោះត្រង់ភាពអង់អាច និងឈ្លាសវៃរបស់គណបក្សប្រជាជនកម្ពុជាក្នុងការដឹកនាំប្រទេស ។ សមិទ្ធផលដ៏ធំធេងទាំងអស់នេះ បាននាំមកនូវមោទនភាពដ៏ឧត្តុង្គឧត្តមបំផុតសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសសម្រាប់ស្រទាប់យុវវ័យដែលបានកើត និងធំដឹងក្ដីឡើងក្រោយថ្ងៃជ័យជំនះ ៧ មករា ។ អាស្រ័យហេតុនេះហើយ ទើបនៅគ្រប់ការបោះឆ្នោត ទាំងការបោះឆ្នោតសកល និងអសកល ទាំងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន គណបក្សប្រជាជនកម្ពុជាតែងតែទទួលបានជ័យជម្នះ ។ លើមូលដ្ឋាននេះ គណបក្សប្រជាជនកម្ពុជា ពិតជានឹងទទួលបានជោគជ័យជាថ្មីទៀតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី ២ ។

ទន្ទឹមនេះ គួរកត់សម្គាល់ថា បច្ចុប្បន្នក្រុមប្រឆាំង និងបណ្ដាមជ្ឈដ្ឋានប្រតិកិរិយាដែលតែងតែប្រឆាំងជានិច្ច និងការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា កាន់តែបង្ហាញនូវចរិតឃ្លើន និងពិសពុលឡើង ។ ពួកគេកំពុងរិះរកគ្រប់វិធីដើម្បីផ្ដួលរំលំគណបក្សប្រជាជនកម្ពុជា តាមរយៈការភូតកុហកបោកប្រាស់អ្នកគាំទ្ររបស់ខ្លួន និងជំរុញសកម្មភាពប្រទូសរ៉ាយឥតឈប់ឈរដែលបំពានយ៉ាងធ្ងន់ធ្ងរលើរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។ ប្រសិនបើបំណងរបស់ពួកគេបានសម្រេចនោះ វានឹងជំរុញឱ្យមាតុភូមិកម្ពុជាត្រូវធ្លាក់ទៅក្នុងភាពចលាចល អស្ថិរភាព និងការបែកបាក់នូវឯកភាពជាតិជាថ្មីទៀត ដែលនឹងបំផ្លាញរាល់ក្ដីសង្ឃឹមរបស់ប្រជាជនយើងចំពោះអនាគតដ៏រុងរឿងរបស់ប្រទេស ។ ប៉ុន្តែប្រជាជនយើងដែលមានគណបក្សប្រជាជនកម្ពុជាជាបង្អែកដ៏រឹងមាំ នឹងមិនទុកឱកាសឱ្យក្រុមប្រឆាំង និងមជ្ឈដ្ឋានប្រតិកិរិយាទាំងនោះអាចសម្រេចបំណងរបស់ខ្លួនបានឡើយ ។

យើងទាំងអស់គ្នាត្រូវតែរួបរួមគ្នាការពារ លើកស្ទួយលទ្ធិប្រជាធិបតេយ្យ ការពាររាល់សមិទ្ធផលរបស់ជាតិ ការពារស្ថិរភាពនយោបាយ និងដំណើរអភិវឌ្ឍន៍នៃសង្គមជាតិ ហើយមិនអនុញ្ញាតឱ្យកម្លាំង អមិត្តណាមួយមក បំផ្លាញមនុញ្ញផលនៃការខិតខំប្រឹងប្រែងយ៉ាងលំបាកលំបិនបំផុត និងសេចក្ដីសង្ឃឹមរបស់ប្រជាជាតិយើងបានឡើយ ។ ក្នុងស្មារតីនេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី ២ នៅពេលខាងមុខនេះ គឺជាជំហានថ្មីមួយទៀតក្នុងដំណើរការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជាផង ហើយក៏ជាការរួមចំណែកដ៏សំខាន់ដល់ការពង្រឹងស្ថិរភាពរបស់ប្រទេសជាតិ និងជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាពផងដែរ ។/

ទស្សនាវដ្ដីប្រជាជន

the strata of youth, born and grown up after the event of 7 January. Taking all facts into consideration, in every election – universal and non-universal suffrage, at national, sub-national and local levels – the Cambodian People's Party always emerges a winner. Based on these results, the Cambodian People's Party will achieve further success in the forthcoming second-term municipal and district council elections.

Currently, it should be noted, the opposition and reactionary circles who always oppose to the leadership of the Cambodian People's Party have demonstrated even more audacious and perfidious nature. They seek to topple the Cambodian People's Party by means of telling lies to supporters and instigating endless controversial actions on existing Constitution and laws. Should their aim fulfill, the country would move into turmoil, instability and division of national unity once again, which in the end would kill our people's hope for the country's prosperous future. However, with the Cambodian People's Party as their chief buttress, the people would not let the opposition and reactionary circles possess the chance of getting their aim fulfilled.

We all must stand together for the defense and promotion of democracy, and protect national achievements, political stability and national development. We should not allow hostile forces to destroy achievements that are born out of our efforts and hardships as well as the hope of the people. It is in and with such spirit that the forthcoming second-term municipal and district elections will be not only a new step in implementing democracy and rule of law in Cambodia, but also an important contribution for strengthening national stability and promoting sustainable socio-economic development./.

*THE PRACHEACHUN MAGAZINE*

# ថ្ងៃ ២០ ឧសភា ជាទិវាប្រវត្តិសាស្ត្រដ៏ឈឺចាប់ដែលត្រូវចងចាំ

ថ្ងៃ ២០ ឧសភា ជាទិវាប្រវត្តិសាស្ត្រដ៏ឈឺចាប់មួយដែលធ្វើឱ្យប្រជាជនកម្ពុជាគ្រប់រូបចងចាំជានិច្ចមិនអាចបំភ្លេចបាននូវមហាវិនាសកម្ម សោកនាដកម្ម និងឧក្រិដ្ឋកម្មដែលរបបប្រល័យពូជសាសន៍ ប៉ុល ពត បានបង្កឡើងចំពោះប្រជាជាតិយើងក្នុងរយៈពេល ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ ពីថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ មករា ឆ្នាំ ១៩៧៩។

ការប្រារព្ធទិវា ២០ ឧសភា នៅឆ្នាំនេះ ក៏ដូចនៅឆ្នាំមុនៗដែរ គឺជាការរំឭកទៅដល់អតីតកាលដ៏ឈឺចាប់បំផុតដែលមាតុភូមិ និងប្រជាជនយើងធ្លាប់បានឆ្លងកាត់ក្នុងរបបមួយដ៏សែនឃោរឃៅដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រនៃកម្ពុជា ក៏ដូចប្រវត្តិសាស្ត្រពិភពលោក។ នោះគឺប្រវត្តិសាស្ត្រដ៏សោកសៅរបស់ប្រជាជាតិមួយដែលធ្លាប់មានវប្បធម៌អរិយធម៌រុងរឿង តែបែជាត្រូវប្រឈមមុខនឹងគ្រោះវិនាសសូន្យទៅវិញ។ គួររំឭកថា បន្ទាប់ពីពួក ប៉ុល ពត បានឡើងកាន់អំណាចនៅកម្ពុជានាថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ជិតមួយខែក្រោយមក គឺនៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៧៥ ពួកប៉ុល ពត បានប្រកាសចេញជាចំហនូវគោលការណ៍មួយចំនួនរួមមាន ៖ ការជម្លៀសប្រជាជនចេញពីទីក្រុងនានា ការលុបចោលទីផ្សារទាំងអស់ក្នុងប្រទេស ការបំបាត់រូបិយវត្ថុនៃរបបចាស់ ការដកក្រដាសប្រាក់បដិវត្តន៍ដែលបានបោះពុម្ពរួចហើយយកទុកវិញ ការផ្សឹកព្រះសង្ឃទាំងអស់ ការបង្កើតផ្ទះបាយរួមនៅទូទាំងប្រទេស ការបណ្តេញជនជាតិវៀតណាម ការបញ្ជូនកងទ័ពទៅព្រំដែន ជាពិសេសព្រំដែនវៀតណាម ការបិទមន្ទីរពេទ្យទាំងអស់នៅទីក្រុងភ្នំពេញ ការបិទមហាវិទ្យាល័យ វិទ្យាល័យ អនុវិទ្យាល័យ និងសាលាបឋមសិក្សាទូទាំងប្រទេស និងការកម្ចាត់ចោលទាំងស្រុងនូវពួកខ្មាំងបង្កប់។ ដូច្នេះគឺថ្ងៃ ២០ ឧសភានោះហើយជាថ្ងៃចាប់ផ្តើមនៃការអនុវត្តនយោបាយប្រល័យពូជសាសន៍នៅកម្ពុជាដែលបានបញ្ឈប់ទាំងស្រុងនូវដំណើររីកចម្រើនទៅមុខរបស់សង្គមជាតិ ហើយទាញបញ្ច្រាសឱ្យដើរថយក្រោយយ៉ាងវែងឆ្ងាយវិលទៅរកសម័យទាសភាពក្នុងបុព្វកាលវិញ ។ របបប៉ុល ពត បានបំផ្លាញទាំងស្រុងនូវក្តីសង្ឃឹមគ្រប់យ៉ាងរបស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់យ៉ាងវេទនាបំផុតនូវភ្លើងសង្គ្រាមវិនាសកម្មរយៈពេល ៥ ឆ្នាំមកហើយ ចាប់ពីឆ្នាំ ១៩៧០ មក ដោយអនុវត្តអំណាចផ្តាច់ការយ៉ាងព្រៃផ្សៃ ឆក់ប្លន់យកអស់នូវសិទ្ធិ សេរីភាពរបស់ប្រជាជន ប្រែក្លាយប្រជាជនទៅជាទាសករដាច់ថ្លៃរបស់ពួកវា។ មនុស្សរស់ដូចសត្វធាតុ រស់នៅក្នុងក្តីរន្ធត់ភ័យខ្លាចរាល់ដង្ហើមចេញចូល ប្រជាជនជាងបីលាននាក់ត្រូវបាត់បង់ជីវិត និងរាប់លាននាក់ទៀតត្រូវព្រាត់ប្រាសបែកបាក់គ្រួសារ ក្លាយជាស្ត្រីមេម៉ាយ ក្មេងកំព្រា ជនពិការ...។ សង្គមកម្ពុជាត្រូវបំផ្លាញខ្ទេចខ្ទីដល់ឫសគល់ គ្មានស្នាមញញឹម គ្មានសំណើច គ្មានការអប់រំ គ្មានសេចក្តីស្រឡាញ់ គឺមានតែការភ័យរន្ធត់ ការអត់ឃ្លាន ទារុណកម្ម និងការកាប់សម្លាប់ប៉ុណ្ណោះ។

ប៉ុន្តែពួកប្រល័យពូជសាសន៍មិនអាចកម្ទេចស្មារតីស្នេហាជាតិ ស្រឡាញ់សេរីភាព និងយុត្តិធម៌របស់ប្រជាជនបានឡើយ។ ក្រោមទង់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ប្រជាជនយើងនៅគ្រប់ទិសទីបានក្រោកឈរឡើងប្រយុទ្ធតស៊ូផ្តួលរំលំរបបដ៏យង់ឃ្នងនេះ រហូតទទួលបានជ័យ ជម្នះនៅថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ដែលបានសង្គ្រោះជាតិឱ្យរស់រានឡើងវិញទាន់ពេលវេលា ហើយបង្កើតឡើងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលជារដ្ឋរបស់ប្រជាជន និងដើម្បីប្រជាជនពិតប្រាកដ។

ដើម្បីរំឭកទុកជាការចងចាំ និងប្តេជ្ញាចិត្តមិនឱ្យប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនេះវិលសាជាថ្មីមកវិញបាននោះ នៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ ១៩៨៣ រដ្ឋសភាអាណត្តិទី ១ នៃអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងសម័យប្រជុំលើកទី ៥ បានអនុម័តកំណត់យកថ្ងៃ ២០ ឧសភា ជារៀងរាល់ឆ្នាំជាទិវារំឭកវិញ្ញាណក្ខន្ធប្រជាជនកម្ពុជាដែលត្រូវបាត់បង់ជីវិតក្រោមរបបប្រល័យពូជសាសន៍ (នៅពេលនោះទិវានេះត្រូវបានកំណត់ថាជាទិវាចងកំហឹងចំពោះរបបប្រល័យពូជសាសន៍ប៉ុល ពត)។ ចាប់តាំងពីពេលនោះមក ថ្ងៃ ២០ ឧសភា ក៏បានក្លាយជាថ្ងៃរំឭកនូវការចងចាំចំពោះប្រវត្តិសាស្ត្រដ៏ឈឺចាប់របស់កម្ពុជាក្នុងរបបប្រល័យពូជសាសន៍ ។ ជារៀងរាល់ឆ្នាំ ប្រជាជននៅទូទាំងប្រទេសតែងតែប្រារព្ធទិវានេះឡើង ដើម្បីគោរពទៅដល់វិញ្ញាណក្ខន្ធនៃជនរួមជាតិដែលត្រូវស្លាប់យ៉ាងអយុត្តិធម៌ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងវីរយុទ្ធជន យុទ្ធនារី និងអ្នកស្នេហាជាតិខ្មែរទាំងឡាយដែលបានធ្វើពលិកម្មដ៏ឧត្តុង្គឧត្តមក្នុងបុព្វហេតុសង្គ្រោះជាតិ មាតុភូមិឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ។

រហូតមកដល់ពេលនេះគឺមានរយៈពេលជាង ៣៥ ឆ្នាំហើយ ដែលយើងបានផ្តួលរំលំរបបដ៏យង់ឃ្នងនេះ គណបក្សប្រជាជនកម្ពុជាបានពុះពារជម្នះរាល់ឧបសគ្គយ៉ាងលំបាកលំបិនជាទីបំផុតប្រឹងប្រែងស្តារ និងកសាងប្រទេសចេញពីបាតដៃទទេ ពីគំនរផេះផង់ ធ្វើឱ្យទឹកដីមាតុភូមិត្រូវបានស្តារឡើងវិញ និងរីកចម្រើនជាជំហានៗ និងបានធ្វើឱ្យរលំរលាយទាំងស្រុងនូវអង្គការចាត់តាំងទាំងខាងនយោបាយ និងយោធាដែលនៅសេសសល់របស់ពួកប្រល័យពូជសាសន៍ នាំមកនូវសន្តិភាពពេញលេញជូនប្រជាជាតិ។ បច្ចុប្បន្នប្រជាជនកម្ពុជាកំពុងរស់នៅយ៉ាងសុខសាន្តក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ ហើយកំពុងបញ្ចេញអស់កម្លាំងកាយ កម្លាំងចិត្ត ដើម្បីអភិវឌ្ឍប្រទេសជាតិ និងលើកកម្ពស់ជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើងឥតឈប់ឈរ។ សមិទ្ធផលទាំងអស់នេះគឺផ្តើមចេញពីជ័យជម្នះ ៧ មករា។ នេះជាសច្ចធម៌ប្រវត្តិសាស្ត្រដែលយើងទាំងអស់គ្នាត្រូវតែចងចាំ ។

រំឭកនូវការចងចាំពីអតីតកាលដ៏ឈឺចាប់ក្នុងរបបប្រល័យពូជសាសន៍ គឺជាការទទួលខុសត្រូវរបស់ប្រជាជនកម្ពុជាយើងគ្រប់ៗរូប ជាពិសេសក្នុងមជ្ឈដ្ឋានយុវជនដែលជាអ្នកបន្តវេនកសាងអនាគតប្រទេសជាតិទៅមុខទៀត។ យុវជនកម្ពុជាគ្រប់ៗរូប គប្បីមានទស្សនៈឱ្យបានត្រឹមត្រូវចំពោះប្រវត្តិសាស្ត្ររបស់ជាតិ យល់ដឹងអំពីមេរៀន និងបទពិសោធន៍នានាដែលជាតិយើងបានទទួលពីដំណាក់កាលនីមួយៗនៃប្រវត្តិសាស្ត្រ ហើយពួតដៃគ្នាជាធ្លុងមួយដើម្បីការពាររាល់មរតកដ៏ថ្លៃថ្លាទាំងឡាយដែលបុព្វការីយើងបានបន្សល់ទុកឱ្យ និងអភិវឌ្ឍប្រទេសទៅមុខទៀតឱ្យបានខ្លាំងក្លាឡើង។ ទន្ទឹមនេះយុវជនកម្ពុជាយើងមិនត្រូវធ្លាក់ចូលក្នុងស្ថានភាពបំភ្លេចចោលនូវប្រវត្តិសាស្ត្ររបស់ជាតិខ្លួន ដោយសារតែការភូតកុហកបោកប្រាស ញុះញង់របស់ក្រុមអ្នកនយោបាយអគតិ និងមជ្ឈដ្ឋានបរទេសមួយចំនួននោះឡើយ។

ប្រជាជាតិមួយតែងតែមានប្រវត្តិសាស្ត្ររបស់ខ្លួន ហើយការចងចាំប្រវត្តិសាស្ត្ររបស់ខ្លួន គឺជាកត្តាដ៏សំខាន់ចាំបាច់មួយនៃអត្តិភាពរបស់ប្រជាជាតិនោះ ។/

# កិច្ចប្រជុំកំពូលនៃគណៈកម្មការទន្លេមេគង្គលើកទី ២ ក្រោមប្រធានបទ "សន្តិសុខទឹក ថាមពល និងស្បៀង នៅក្នុងបរិបទបម្រែបម្រួលអាកាសធាតុសម្រាប់អាងទន្លេមេគង្គ"




*នាយករដ្ឋមន្ត្រី និងតំណាងនាយករដ្ឋមន្ត្រីនៃប្រទេសទាំង ៤ ចូលរួមក្នុងកិច្ចប្រជុំចង្អៀតនៃកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ២*

ពីថ្ងៃទី ៤-៥ ខែមេសា ឆ្នាំ ២០១៤ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំកំពូលលើកទី២នៃគណៈកម្មការទន្លេមេគង្គនៅទីក្រុងហូជីមិញ ក្រោមប្រធានបទ"សន្តិសុខទឹក ថាមពល និងស្បៀង នៅក្នុងបរិបទបម្រែបម្រួលអាកាសធាតុសម្រាប់អាងទន្លេមេគង្គ"។ កិច្ចប្រជុំនេះមានការចូលរួមពីប្រមុខរដ្ឋាភិបាលកម្ពុជា ឡាវ ថៃនិងវៀតណាម ព្រមទាំងបណ្តាប្រទេសដៃគូសន្ទនាមួយចំនួនទៀត។ អ្នកជំនាញការអន្តរជាតិ និងថ្នាក់តំបន់ខាងផ្នែកធនធានទឹក អ្នកពាក់ព័ន្ធនានាមកពីបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ប្រទេសចិន មីយ៉ាន់ម៉ា និងដៃគូ អភិវឌ្ឍន៍សរុបជាង ២៥០ នាក់ បានចូលរួមពិភាក្សាបញ្ហានានាដែលទាក់ទងនឹងកិច្ចប្រជុំកំពូលលើកទី ២ នេះ។ កិច្ចប្រជុំកំពូលលើកនេះបានពិភាក្សាលើបញ្ហាមួយចំនួនស្តីពីកាលានុវត្តភាព បញ្ហាប្រឈមសម្រាប់អាងទន្លេមេគង្គ និងតួនាទីរបស់គណៈកម្មការទន្លេមេគង្គសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ដើម្បីជំរុញការប្រែប្រួល និងការអភិវឌ្ឍប្រកបដោយចីរភាពនៃទន្លេមេគង្គក្នុងបរិបទនៃកំណើនតម្រូវការធនធានធម្មជាតិសម្រាប់ការអភិវឌ្ឍ និងបម្រែបម្រួលអាកាសធាតុ។

ក្នុងឱកាសស្នាក់នៅទីក្រុងហូជីមិញនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅថ្ងៃទី ៤ ខែមេសា សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានជួបចរចាទ្វេភាគីជាមួយឯកឧត្តម **ង្វៀន តាន់យ៉ុង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ក្នុងជំនួបពិភាក្សាគ្នានេះ ឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាមបានថ្លែងថា វត្តមានដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន** ក្នុងកិច្ចប្រជុំកំពូលមេគង្គលើកទី ២ នាពេលនេះ គឺជាកម្លាំងចលករដ៏រឹងមាំក្នុងការជំរុញកិច្ចប្រជុំកំពូលមេគង្គលើកទី ២ របស់យើងឱ្យទទួលបានលទ្ធផលដ៏ត្រចះត្រចង់។ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរបានធ្វើការពិភាក្សាគ្នាទាក់ទិនទៅនឹងសកម្មភាពការងារមួយចំនួនដែលប្រទេសក្នុងតំបន់មេគង្គទាំង ៤បានអនុវត្តក្រោយកិច្ចប្រជុំកំពូលមេគង្គលើកទី ១ នៅទីក្រុង ហ៊ូហ៊ីននៃព្រះរាជាណាចក្រថៃ កាលពីឆ្នាំ ២០១០។ មេដឹកនាំទាំងពីរក៏បានពិភាក្សាគ្នាដោយយកចិត្តទុកដាក់ ទាក់ទិនទៅនឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ក៏ដូចជាបញ្ហាតំបន់ និងអន្តរជាតិ ដែលមានការយកចិត្តទុកដាក់ដូចគ្នា ជាពិសេសការជំរុញកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគនៃប្រទេសទាំងពីរឱ្យឈានដល់ចំណុចកំពូលថ្មីមួយទៀតដែលប្រមុខរដ្ឋាភិបាល និងប្រជាជននៃប្រទេសទាំងពីរប្រាថ្នាចង់បាន។ កិច្ចពិភាក្សានេះក៏បានលើកឡើងផងដែរទាក់ទិនទៅនឹងការប្រើប្រាស់ប្រព័ន្ធទឹកនៅតាមតំបន់ព្រំដែន សំដៅធ្វើយ៉ាងណាឱ្យប្រជាជននៃប្រទេសទាំងពីនៅតាមតំបន់ព្រំដែនទទួលបានផ្លែផ្កានៃកំណើនពីការប្រើប្រាស់ប្រភពទឹកដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

នៅថ្ងៃទី ៥ ខែមេសា កិច្ចប្រជុំកំពូលលើកទី ២ នៃគណៈកម្មការទន្លេមេគង្គបានប្រារព្ធឡើងជាផ្លូវការ។ កិច្ចប្រជុំបានផ្តោតការពិភាក្សាក្នុងការស្វែងរកឆន្ទៈនយោបាយរបស់មេដឹកនាំថ្នាក់ជាតិ ដើម្បីធ្វើការ




*សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ឡើងថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំកំពូលលើកទី ២ នៃគណៈកម្មការទន្លេមេគង្គ (០៥.០៤.២០១៤)*



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្នុងជំនួបចរចាទ្វេភាគីជាមួយឯកឧត្តម **ង្វៀន តាន់យ៉ុង***

ជាមួយគ្នា ក្នុងបំណងជម្នះឧបសគ្គ និងការប្រឈមនានានៅក្នុងការអភិវឌ្ឍនៃអាងទន្លេមេគង្គ។ ការអភិវឌ្ឍអាងទន្លេមេគង្គកំពុងមានការកើនឡើងដែលរួមទាំងការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅលើដៃទន្លេនានា និងនៅលើដងទន្លេមេ និងគម្រោងបង្វែរទឹកសម្រាប់ការស្រោចស្រពកាន់តែច្រើនជាងមុនរួមទាំងការធ្វើនាវាចរ និងវារីវប្បកម្មផងដែរ។ ធនធានទន្លេមេគង្គមានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ធនធានជលផលទឹកសាបធំជាងគេលើពិភពលោកសម្រាប់ការដឹកជញ្ជូនតាមដងទន្លេ និងសម្រាប់តំបន់ដីសើម និងទំនាបលិចទឹកដែលផ្តល់របរចិញ្ចឹមជីវិត សម្រាប់ពលរដ្ឋជាច្រើនលាននាក់ជាពិសេសប្រជាជនក្រីក្រ។ និន្នាការអភិវឌ្ឍន៍នេះទទួលរងឥទ្ធិពលនៃគោលដៅអភិវឌ្ឍន៍របស់ប្រទេសតាមដងទន្លេក្នុងការប្រើប្រាស់ទឹក និងធនធានដែលពាក់ព័ន្ធដើម្បីទ្រទ្រង់គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមរបស់ខ្លួន និងការកាត់បន្ថយភាពក្រីក្រ។ ប្រធានបទនានានៃកិច្ចប្រជុំកំពូលលើកទី ២ របស់គណៈកម្មការទន្លេមេគង្គ និងសន្និសីទអន្តរជាតិបានឆ្លុះបញ្ចាំងអំពីភាពបន្ទាន់ក្នុងការដោះស្រាយការជាប់ទាក់ទងគ្នានៃបញ្ហាទាំងអស់នេះ។

ក្នុងឱកាសអញ្ជើញមាតុភូមិនិវត្តន៍មកដល់កម្ពុជាវិញ ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាដែលបានអញ្ជើញអមដំណើរសម្តេចតេជោ **ហ៊ុន សែន** ចូលរួមកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ២ បានមានប្រសាសន៍ថា កិច្ចប្រជុំកំពូលនៃគណៈកម្មការទន្លេមេគង្គបានចេញសេចក្តីថ្លែងការណ៍រួមទីក្រុងហូជីមិញដោយបញ្ជាក់យ៉ាងច្បាស់ឱ្យបណ្តាប្រទេសសមាជិកទន្លេមេគង្គអន្តរជាតិអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកិច្ចព្រមព្រៀងរបស់គណៈកម្មការអន្តរជាតិ ទន្លេមេគង្គឆ្នាំ ១៩៩៥។ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា កិច្ចប្រជុំបានចាប់អារម្មណ៍ច្រើនផ្តោតទៅលើការ សាងសង់ទំនប់វារីអគ្គិសនីដនសាហុងរបស់ប្រទេសឡាវ។ ទំនប់វារីអគ្គិសនីដនសាហុងគឺជាប្រធានបទមួយក្តៅ មិនមែនតែក្នុងប្រទេសកម្ពុជានោះទេ គឺប្រទេសសមាជិកនៃគណៈកម្មការទន្លេមេគង្គ និងដៃគូអភិវឌ្ឍន៍អន្តរជាតិបានចាប់អារម្មណ៍ និងធ្វើការងារជាច្រើនពាក់ព័ន្ធនឹងគម្រោងសាងសង់ទំនប់វារីអគ្គិសនី។ ភាគីកម្ពុជាជាភាគីដែលជាម្ចាស់ទន្លេមេគង្គមុនគេ ដែលបានធ្វើលិខិតទៅកាន់ភាគីឡាវសុំឱ្យឡាវផ្អាកការសាងសង់ទំនប់ដនសាហុងនេះសិន ហើយបានស្នើសុំឱ្យដាក់បញ្ហាតំបន់ដនសាហុងនេះចូលទៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ។ ប្រសិនជាភាគីឡាវមិនអនុវត្តតាមកិច្ចព្រមព្រៀងរបស់គណៈកម្មការអន្តរជាតិទន្លេមេគង្គឆ្នាំ ១៩៩៥ ហើយបន្តសាងសង់ទំនប់ដនសាហុងដោយចិត្តឯងនោះ ប្រទេសសមាជិកទន្លេមេគង្គ និងដៃគូអភិវឌ្ឍន៍នានាប្រាកដជាចាំមើល ហើយប្រហែលជាមិនបណ្តោយឱ្យប្រទេសឡាវបន្តធ្វើតាមចិត្តនោះទេ។ យើងរង់ចាំមើលបន្ត យើងមិនអាចឈប់បានទេ ព្រោះយើងនៅតែការពារផលប្រយោជន៍របស់មេគង្គ និងផលប្រយោជន៍របស់ប្រជាជនកម្ពុជា។ឯកឧត្តម **លឹម គានហោ** បានបញ្ជាក់ច្បាស់ថាប្រទេសកម្ពុជានៅតែប្រកាន់ជំហរការពារដាច់ខាតនូវសក្តានុពលរបស់មេគង្គ ធ្វើយ៉ាងណាឱ្យទន្លេមេគង្គមាននិរន្តរភាព ពិសេសគិតគូរដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាដែលពឹងផ្អែកទៅលើទន្លេមេគង្គ។ កម្ពុជាមានជំហរច្បាស់លាស់ណាស់ចំពោះបញ្ហានេះ។

មេដឹកនាំទាំងអស់ក្នុងកិច្ចប្រជុំកំពូលលើកទី ២ នៃគណៈកម្មការទន្លេមេគង្គបានវាយតម្លៃខ្ពស់ចំពោះរដ្ឋាភិបាលវៀតណាមដែលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំដែលបានបញ្ចប់ទៅប្រកបដោយលទ្ធផលដ៏ល្អប្រសើរ និងបានប្រគល់ភារកិច្ចជូនដល់ប្រទេសកម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ ដែលនឹងត្រូវរៀបចំឡើងនៅក្នុងខែមេសា ឆ្នាំ ២០១៨ ខាងមុខនេះ។/

# ទស្សនកិច្ចប្រកបដោយផ្លែផ្កានៃប្រមុខរាជរដ្ឋាភិបាលកម្ពុជា នៅសាធារណរដ្ឋអាស៊ែបៃហ្សង់ និងសាធារណរដ្ឋបេឡារុស

*រយៈពេលជិតមួយសប្តាហ៍នាចុងខែមេសាឆ្នាំ ២០១៤ កន្លងទៅនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលអមដំណើរឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងឯកឧត្តមអស់លោកជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិករាជរដ្ឋាភិបាលជាច្រើនរូប បានអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋអាស៊ែបៃហ្សង់ និងសាធារណរដ្ឋបេឡារុស ។ ប្រទេសទាំងនេះសុទ្ធសឹងជាប្រទេសដែលធ្លាប់ស្ថិតនៅក្នុងអតីតសហភាពសូវៀត និងជាមិត្តចាស់របស់កម្ពុជាចាប់តាំងពីទសវត្សឆ្នាំ ៨០ មកម្លេះ ។ ទស្សនកិច្ចនេះបានចាប់ផ្តើមពីថ្ងៃទី ២០ ខែមេសា និងធ្វើមាតុភូមិនិវត្តន៍នារសៀលថ្ងៃទី ២៦ ខែ មេសា ។*



*កិច្ចចរចាទ្វេភាគីរវាងនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ កម្ពុជា-អាស៊ែបៃហ្សង់*

ទស្សនកិច្ចជាផ្លូវរដ្ឋនៅសាធារណរដ្ឋអាស៊ែបៃហ្សង់បានប្រព្រឹត្តទៅពីថ្ងៃទី ២១ ដល់ថ្ងៃទី ២៣ ខែមេសា ។ ក្នុងឱកាសស្នាក់នៅទីនោះសម្តេចតេជោ **ហ៊ុន សែន** បានជួបសម្តែងការគួរសមជាមួយឯកឧត្តម **អ៊ីលហាម អាលីយេវ** ( Ilham Aliyev ) ប្រធានាធិបតីនៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ឯកឧត្តម **អុកតៃ អាសាដូវ** ( Oktay Asadov ) ប្រធានរដ្ឋសភានិងជួបពិភាក្សាទ្វេភាគីជាមួយឯកឧត្តម **អាធឺ រ៉ាស៊ីហ្សាដ** (ArturRasi-zade) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ។

ជំនួបទ្វេភាគីរវាងប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរកម្ពុជា អាស៊ែបៃហ្សង់ បានប្រព្រឹត្តទៅនៅវិមានរដ្ឋាភិបាលក្នុងទីក្រុងបាគូ (Ba ku) ។ ក្នុងជំនួបនេះភាគីទាំងពីរបានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដែលបាន និងកំពុងតែបោះជំហានទៅមុខប្រកបដោយភាពសុខដុមរមនា និងរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ។ ប៉ុន្តែបើទោះបីជាមានការរីកចម្រើនធំធាត់លើវិស័យនយោបាយ និងការទូតក៏ពិតមែន ក៏ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរមានការមិនទាន់ពេញចិត្តដូចគ្នាចំពោះទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរដែលហាក់នៅមានកម្រិតនៅឡើយ ហើយតាមរយៈជំនួបចរចាទ្វេភាគីនេះ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានសន្យារួមគ្នាថានឹងបង្កើននូវកិច្ចសហប្រតិបត្តិការលើគ្រប់កម្រិត និងគ្រប់វិស័យ សំដៅធ្វើយ៉ាងណាពង្រីកទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរកម្ពុជា-អាស៊ែបៃហ្សង់ឱ្យកាន់តែមានទំហំធំទ្វេឡើងថែមទៀត ។

ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ទៅលើបញ្ហាតំបន់ និងអន្តរជាតិដែលមានការយកចិត្តទុកដាក់ដូចគ្នា ។ ក្នុងនោះភាគីអាស៊ែបៃហ្សង់បានសម្តែងនូវអំណរគុណ ជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែធ្វើការគាំទ្រឥតសំចៃ ចំពោះបុព្វហេតុសន្តិភាព និងបូរណភាពទឹកដី និងអធិបតេយ្យភាពរបស់ប្រទេសអាស៊ែបៃហ្សង់ និងជាពិសេសទៅទៀតនោះ កម្ពុជាបានគាំទ្របេក្ខភាពអាស៊ែប៊ៃហ្សង់ ក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សសម្រាប់អាណត្តិ ២០០៦-២០០៨ ។ ចំណែកកម្ពុជាក៏បានថ្លែងនូវអំណរគុណចំពោះអាស៊ែប៊ៃហ្សង់វិញដែរ ដែលបានគាំទ្របេក្ខភាពកម្ពុជាជាសមាជិកមិនអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិសម្រាប់អាណត្តិ ២០១៣-២០១៤ បើទោះបីជាមិនមានសំឡេងគាំទ្រច្រើនលើសលប់ដូចសាធារណរដ្ឋកូរ៉េក៏ពិតមែនប៉ុន្តែនោះគឺជាសន្តានចិត្តដ៏ល្អរបស់អាស៊ែបៃហ្សង់ក្នុងការគាំទ្រដល់កម្ពុជា ក្នុងនាមជាមិត្តភក្តិដ៏ល្អផងដែរ ។

ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានបង្ហាញពីឆន្ទៈនយោបាយពិតប្រាកដ ក្នុងការពិភាក្សាគ្នាបង្កើតឡើងនូវគណៈកម្មការរួមនៃប្រទេសទាំងពីរ ដើម្បីធ្វើការដោះស្រាយនូវរាល់បញ្ហាបច្ចេកទេសនានា ដើម្បីឈានទៅបង្កើតគណៈកម្មការរួមឱ្យបានចេញនូវរូបរាងពិតប្រាកដនៅពេលខាងមុខ ។ ជាមួយគ្នានេះប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានប្តេជ្ញារួមគ្នានឹងខិតខំរិះរកគម្រោងជាក់លាក់ណាមួយដែលនឹងបម្រើឱ្យផលប្រយោជន៍នៃប្រទេសទាំងពីរ ។

សម្តេចតេជោមានប្រសាសន៍ទៅកាន់សមភាគីដែរថា វត្តមាននៃដំណើរទស្សនកិច្ចរបស់សម្តេចមកកាន់ប្រទេសអាស៊ែបៃហ្សង់



*សម្តេចតេជោ **ហ៊ុន សែន** និងឯកឧត្តម Artur Rasi-Zade នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋអាស៊ែបៃហ្សង់*

នៅពេលនេះ នឹងរួមវិភាគទានដល់ការពង្រឹងទំនាក់ទំនងទ្វេភាគីនៃប្រទេសទាំងពីរឱ្យកាន់តែរឹងមាំទ្វេឡើងថែមទៀត ។ សម្តេចក៏បានថ្លែងអំណរគុណជូនចំពោះរដ្ឋាភិបាលអាស៊ែបៃហ្សង់ ដែលបានផ្តល់អាហារូបករណ៍ចំនួន ៥ កន្លែងដល់និស្សិតកម្ពុជាសម្រាប់សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅបណ្ឌិតសភាការទូតអាស៊ែបៃហ្សង់រយៈពេល ២ ឆ្នាំ ក្នុងឆ្នាំ ២០១៤ -២០១៦ និងបានស្នើដល់ភាគីរដ្ឋាភិបាលអាស៊ែបៃហ្សង់បន្តជួយដល់ការបណ្តុះបណ្តាលធនធានមនុស្សដល់កម្ពុជា ពិសេសលើវិស័យប្រេង និងឧស្ម័ន ដោយសារនៅពេលខាងមុខ កម្ពុជានឹងក្លាយជាប្រទេសផលិតប្រេង និងឧស្ម័នផងដែរ ។ សម្តេចក៏បានស្នើដល់សមភាគីពិនិត្យលទ្ធភាព ក្នុងការបណ្តាក់ទុនវិនិយោគលើការកសាងម៉ាស៊ីនកិនស្រូវនៅកម្ពុជា ដើម្បីនាំអង្ករមកកាន់អាស៊ែបៃហ្សង់ និងទីផ្សារអឺរ៉ុប ។ សម្តេចបានថ្លែងនូវអំណរគុណចំពោះអាស៊ែបៃហ្សង់ដែលបានបញ្ជូនអ្នកអង្កេតការណ៍ទៅពិនិត្យដំណើរការបោះឆ្នោតសកលកាលពីថ្ងៃទី២៨ខែកក្កដាឆ្នាំ២០១៣ ។

ប្រមុខរដ្ឋាភិបាលទាំងពីរក៏បានពិភាក្សាផងដែរ អំពីការមិនយកពន្ធត្រួតគ្នាលើការវិនិយោគរបស់អ្នកវិនិយោគទុននៃប្រទេសទាំងពីរ ។ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចពិគ្រោះនយោបាយរវាងក្រសួងការបរទេសទាំងពីរ និងកិច្ចប្រជុំពិភាក្សានយោបាយរវាងក្រសួងទាំងពីរ ដែលនោះគឺជាមូលដ្ឋានសំខាន់ក្នុងការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងកម្ពុជា អាស៊ែបៃហ្សង់ ដើម្បីជាផលប្រយោជន៍រួមនៃប្រទេសទាំងពីរ ។ សម្តេចតេជោ **ហ៊ុន សែន** ក៏បានគោរពអញ្ជើញឯកឧត្តមនាយករដ្ឋមន្ត្រីអាស៊ែបៃហ្សង់អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសកម្ពុជា តាមពេលវេលាសមស្របណាមួយ ដើម្បីរឹតចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត ។

ក្នុងពេលបញ្ចប់នូវកិច្ចចរចាប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរបានអញ្ជើញធ្វើជាសាក្សីនៃពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការបង្កើតកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនិងក្រសួងការបរទេសនៃសាធារណរដ្ឋអាស៊ែបៃហ្សង់ដែលចុះហត្ថលេខារវាងឯកឧត្តម**សុខ អាន**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនៃប្រទេសកម្ពុជាជាមួយនិងឯកឧត្តម Elmar Mammadyrov រដ្ឋមន្ត្រីការបរទេសនៃប្រទេសអាស៊ែបៃហ្សង់ ។

ដោយឡែកក្នុងឱកាសអញ្ជើញចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម **អ៊ីលហាម អាលីយេវ** (Ilham Aliyev) ប្រធានាធិបតីនៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ។ ខណៈនោះឯកឧត្តមប្រធានាធិបតីបានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃកិច្ចចរចាថ្នាក់កំពូលរដ្ឋាភិបាលនៃប្រទេសទាំងពីរ កម្ពុជា-អាស៊ែបៃហ្សង់ ដែលបានប្តេជ្ញារួមគ្នាក្នុងការបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគនៃប្រទេសទាំងពីរឱ្យឈានដល់ចំណុចថ្មីមួយទៀត ។ ឯកឧត្តមប្រធានាធិបតីអាស៊ែបៃហ្សង់បានគាំទ្រចំពោះប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរ ដែលបានប្តេជ្ញាចិត្តរួមគ្នាក្នុងពង្រីកទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរឱ្យកាន់តែមានទំហំធំឡើងថែមទៀត ។

នៅទីក្រុងបាគូនេះដែរ សម្តេចតេជោ និងគណៈប្រតិភូជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជាបានអញ្ជើញទស្សនាមន្ទីររដ្ឋសភា ។សម្តេចតេជោ និងគណៈប្រតិភូបានអញ្ជើញចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម **អុកតៃ អាសាដូវ** ( Oktay Asadov) ប្រធានរដ្ឋសភានៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ។

ក្នុងជំនួបខាងលើនេះឯកឧត្តមប្រធានសភាអាស៊ែបៃហ្សង់មានប្រសាសន៍ថា រដ្ឋសភាក៏ដូចជាថ្នាក់ដឹកនាំទាំងអស់នៃប្រទេសអាស៊ែបៃហ្សង់ផ្តល់នូវសារសំខាន់ខ្លាំងណាស់ចំពោះវត្តមាននៃការអញ្ជើញបំពេញទស្សនកិច្ចផ្លូវការរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីនៅលើទឹកដីអាស៊ែបៃហ្សង់ ។ ដំណើរទស្សនកិច្ចរបស់សម្តេចនឹងជួយបង្កើតឱ្យមាននូវទំនាក់ទំនងជាអចិន្ត្រៃយ៍នៃប្រទេសទាំងពីរ ។ ឯកឧត្តមក៏បានសម្តែងនូវការសោកស្តាយដែរថា បើទោះបីជា



*ជំនួបចរចាទ្វេភាគីរវាងនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ កម្ពុជា-បេឡារុស*



*នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ កម្ពុជា-បេឡារុស ក្នុងពិធីចុះហត្ថលេខាលើសេចក្តីប្រកាសរួម*

ប្រទេសទាំងពីរបានភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នា ២០ ឆ្នាំក៏ពិតមែន ប៉ុន្តែប្រទេសទាំងពីរមិនទាន់មានឯកសារគោលជាផ្លូវការនៅឡើយទេ ទើបតែមាននៅក្នុងពិធីចុះហត្ថលេខាក្នុងដំណើរទស្សនកិច្ចការរបស់សម្តេចមកកាន់ប្រទេសអាស៊ែបៃហ្សង់នៅពេលនេះ ។ ឯកឧត្តមបានផ្តល់នូវសេចក្តីសង្ឃឹមថា នៅពេលខាងមុខប្រទេសទាំងពីរនឹងមានឯកសារគោលជាច្រើនទៀតដែលនឹងត្រូវចុះហត្ថលេខាជាមួយគ្នាបន្តទៀត ។

នៅក្នុងជំនួបពិភាក្សាគ្នានោះដែរ ឯកឧត្តមប្រធានសភាបានស្នើនូវគំនិតក្នុងការបង្កើតសមាគមមិត្តភាពសភានៃប្រទេសទាំងពីរ ដោយសារតែកន្លងមកសភារបស់ប្រទេសអាស៊ែបៃហ្សង់បានបង្កើតសមាគមសភាជាមួយនឹងប្រទេសចំនួន ៧៣ រួចមកហើយលើពិភពលោក ។ តាមសំណើររបស់ឯកប្រធានសភាអាស៊ែបៃហ្សង់នោះ សម្តេចនាយករដ្ឋមន្ត្រីបានចាត់តាំងឱ្យឯកឧបនាយករដ្ឋមន្ត្រី **សុខ អាន** តំណាងឱ្យសភាកម្ពុជាក្នុងការបង្កើតសមាគមមិត្តភាពជាមួយនឹងសភាអាស៊ែបៃហ្សង់ ហើយដែលភាគីសភាអាស៊ែបៃហ្សង់បានដាក់បេក្ខភាពឯកឧត្តម Elmar Mammadyrov រដ្ឋមន្ត្រីការបរទេសអាស៊ែបៃហ្សង់ ធ្វើជាប្រធានសមាគមសភាអាស៊ែបៃហ្សង់ ដើម្បីបង្កើតក្រុមការងាររួមនៃការបង្កើតសមាគមមិត្តភាពសភាប្រទេសទាំងពីរ ។

ក្នុងជំនួបនោះដែរ សម្តេចតេជោបានពាំនាំនូវការអញ្ជើញពីសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាកម្ពុជាអញ្ជើញឯកឧត្តមប្រធានសភាអាស៊ែបៃហ្សង់ទៅបំពេញទស្សនកិច្ចផ្លូវការតាមពេលវេលាសមស្របណាមួយនៅពេលខាងមុខ ។ ឯកឧត្តមប្រធានរដ្ឋសភាបានទទួលនូវការអញ្ជើញនេះ ។

ក្នុងឱកាសស្នាក់នៅទីក្រុងបាគូនៃសាធារណរដ្ឋអាស៊ែបៃហ្សង់នេះដែរ សម្តេច និងគណៈប្រតិភូបានអញ្ជើញទៅទស្សនាតំបន់សំខាន់ៗមួយចំនួននៃសាធារណរដ្ឋមួយនេះ ក្នុងនោះក៏បានអញ្ជើញទៅទស្សនាមជ្ឈមណ្ឌលស្ថាបត្យកម្ម Heydar Aliyev និងស្ថានីយផលិតប្រេង Sangachal Terminal ដ៏ធំរបស់អាស៊ែបៃហ្សង់ ។

បន្ទាប់មកចាប់ពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៥ ខែមេសា សម្តេចតេជោ **ហ៊ុន សែន** និងគណៈប្រតិភូបានបន្តទៅបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅសាធារណរដ្ឋបេឡារុស ។

ក្នុងពេលស្នាក់នៅទីក្រុងមីនស្គ៍ នៃសាធារណរដ្ឋបេឡារុស សម្តេចតេជោបានជួបសម្តែងការគួរសមជាមួយឯកឧត្តម **អាឡិចសាន់ដឺរ ឡូកាសិនកូ** ( Aleksandor Lukashenko ) ប្រធានាធិបតីនៃសាធារណរដ្ឋបេឡារុស ឯកឧត្តម **អាន់ណាតូលី រូប៊ីនន៉ូវ**( Anatoly Rubinov )ប្រធានក្រុមប្រឹក្សារដ្ឋសភា និងជួបពិភាក្សាទ្វេភាគីជាមួយឯកឧត្តម **មីខាយ មីយ៉ាសនីកូវិច** ( Mikhai Myasnikovich )នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋបេឡារុស ។

កិច្ចពិភាក្សាការងារទ្វេភាគីជាមួយសមភាគីបេឡារុសបានប្រព្រឹត្តទៅនៅវិមានរដ្ឋាភិបាលក្នុងទីក្រុងមីនស្គ៍ ។ឯកឧត្តមនាយករដ្ឋមន្ត្រីបេឡារុស **មីខាយ មីយ៉ាសនីកូវិច** បានជម្រាបសម្តេចតេជោថា លោកបានទទួលនូវដំណឹងដ៏សែនរីករាយចំពោះលទ្ធផលនៃកិច្ចសន្ទនារវាងសម្តេចតេជោ និងឯកឧត្តមប្រធានាធិបតីដែលបានធ្វើការពិភាក្សាដោយស្មោះត្រង់ជុំវិញការជំរុញកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនរឹងមាំថែមទៀត ។បេឡារុសមានសេចក្តីសោមនស្សរីករាយខ្លាំងណាស់ក្នុងការពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យការទូត នយោបាយ សេដ្ឋកិច្ចនិងពាណិជ្ជកម្មជាមួយនឹងប្រទេសកម្ពុជាដោយសារតែប្រទេសកម្ពុជានាពេលបច្ចុប្បន្នទទួលបាននូវសុខសន្តិភាពពេញលេញ ពិសេស កម្ពុជាគឺជាប្រទេសមួយ ដែលសម្បូរទៅដោយធនធានធម្មជាតិដែលអាចធ្វើការវិនិយោគរួមគ្នាបាន។ ឯកឧត្តមបន្តថា អ្វីដែលយើងមិនទាន់បានធ្វើការដោះស្រាយនិងឈានដល់ចំណុចមួយ



*នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ កម្ពុជា-បេឡារុស ក្នុងវេទិកាធុរកិច្ច*

ដែលអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាបាននោះ គឺយើងនឹងបន្តធ្វើការពិភាក្សាគ្នាបន្តទៀត សំដៅធ្វើយ៉ាងណាឱ្យប្រទេសទាំងពីរកាន់តែឈានចូលជិតគ្នានឹងបម្រើឱ្យផលប្រយោជន៍ពីគ្នាទៅវិញទៅមក ។ ឯកឧត្តមបានបញ្ជាក់ថា បើទោះបីជាប្រទេសទាំងពីរហាក់នៅឃ្លាតឆ្ងាយពីគ្នាក៏ពិតមែន ប៉ុន្តែសន្តានចិត្តដ៏ល្អរបស់ថ្នាក់ដឹកនាំ និងប្រជាជនកម្ពុជាបានជំរុញឱ្យថ្នាក់ដឹកនាំ និងប្រជាជនបេឡារុសទាំងអស់មានការស្រឡាញ់រាប់អានកាន់តែខ្លាំង និងប្រៀបដូចជាបងប្អូនដែលមានភូមិផងរបងជាមួយយ៉ាងដូច្នេះដែរ ។

ឯកឧត្តមនាយករដ្ឋមន្ត្រីបានវាយតម្លៃខ្ពស់ចំពោះភាពជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ ដោយបានដឹកនាំប្រទេសឈានឆ្ពោះមកកាន់សុខសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ ហើយដំណើរទស្សនកិច្ចរបស់សម្តេចមកកាន់បេឡារុសនៅពេលនេះ គឺធ្វើឡើងជិតនឹងការប្រារព្ធខួបលើកទី ២០ នៃទំនាក់ទំនងការទូតរបស់ប្រទេសទាំងពីរកម្ពុជា-បេឡារុស និងព្រឹត្តិការណ៍ដទៃទៀតដែលប្រទេសទាំងពីររួមគ្នាសម្រេចបានពិសេសលើវិស័យសេដ្ឋកិច្ច និងសង្គម ។

ក្នុងជំនួបចរចាកំពូលនោះ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះលទ្ធផលដែលក្រុមការងារនៃប្រទេសទាំងពីរសម្រេចបានក្នុងរយៈពេលកន្លងមក ។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំទាំងពីរក៏បានសម្តែងនូវការសោកស្តាយដែលប្រទេសទាំងពីរមិនទាន់បានអនុវត្តឱ្យកាន់តែស៊ីជម្រៅពីសក្តានុពលដែលប្រទេសទាំងពីរមាន ។ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរបានធ្វើការកត់សម្គាល់រួមគ្នាដែរថា ប្រទេសទាំងពីរមិនមែនត្រឹមតែធ្វើកិច្ចសហប្រតិបត្តិការក្នុងការទិញទំនិញសម្ភារៈ បច្ចេកទេសនោះទេ ប៉ុន្តែភាគីទាំងពីរគួរតែសង្កត់ធ្ងន់ទៅលើកិច្ចសហប្រតិបត្តិការលើការជំរុញការ វិនិយោគផងដែរ ។ ឯកឧត្តមនាយករដ្ឋមន្ត្រីបានកោតសរសើរសម្តេចតេជោដែលបានខិតខំជំរុញធ្វើយ៉ាងណាឱ្យមានគម្រោងរួមគ្នាក្នុងការពង្រីកកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរកាន់តែសម្រេចបានជោគជ័យថែមទៀត ។ឯកឧត្តមក៏បានគូសបញ្ជាក់ពីសារសំខាន់នៃធនាគារជាតិរបស់ប្រទេសទាំងពីរ ដែលគួរតែបង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្នាឱ្យកាន់តែរឹងមាំថែមក្នុងការជំរុញ ក៏ដូចជាការបង្កើននូវភាពជឿជាក់ និងទំនុកចិត្តដល់អ្នកវិនិយោគនៃប្រទេសទាំងពីរ ។

សម្តេចតេជោមានប្រសាសន៍វាយតម្លៃខ្ពស់ចំពោះភាពជោគជ័យ ដែលប្រទេសបេឡារុសសម្រេចបានក្នុងរយៈពេលជាង ៣៣ ឆ្នាំកន្លងមក បន្ទាប់ពីដំណើរទស្សនកិច្ចលើកទី ១ របស់សម្តេចមកកាន់ទីក្រុងមីនស្ក៍កាលពីឆ្នាំ ១៩៨១ ។ សម្តេចបានរំឭកថា កាលពីឆ្នាំ ២០១២ កន្លង ទៅប្រធានរដ្ឋសភាកម្ពុជាគឺសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** បានអញ្ជើញមកបំពេញទស្សនកិច្ចនៅបេឡារុស ហើយនៅឆ្នាំ ២០១៣ កន្លងទៅនោះដែរ ប្រធានសភាបេឡារុសបានបំពេញទស្សនកិច្ចនៅកម្ពុជា និងនៅខែមីនាកន្លងទៅថ្មីៗនេះ លោករដ្ឋមន្ត្រីក្រសួងការបរទេសបេឡារុសបានធ្វើទស្សនកិច្ចនៅកម្ពុជា ។ សម្តេចបានស្នើឱ្យភាគីទាំងពីរបន្តធ្វើការផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់នាំនៃប្រទេសទាំងពីរឱ្យកាន់តែញឹកញាប់ថែមទៀតសំដៅធ្វើយ៉ាងណាឱ្យប្រទេសទាំងពីរកាន់តែទទួលបាននូវភាពជិតស្និទ្ធ និងបង្កើតជាយន្តការស្របច្បាប់មួយនៃការអនុវត្តយន្តការដែលបានចុះហត្ថលេខារួមគ្នានោះ ។

សម្តេចតេជោក៏មានប្រសាសន៍ដែរថាវិស័យឯកជនគឺជាផ្នែកគន្លឹះនៃការអភិវឌ្ឍសមិទ្ធផលសង្គម សេដ្ឋកិច្ចនៃប្រទេសទាំងពីរ ហើយនៅពេលដ៏ខ្លីខាងមុខនឹងប្រារព្ធខួប ២០ ឆ្នាំនៃការបង្កើតចំណងការទូតនៃប្រទេសទាំងពីរ ដែលតាមរយៈនេះ យើងគួរបង្កើតនូវព្រឹត្តិការណ៍អ្វីមួយដើម្បីឱ្យនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរយកមកអនុវត្តដើម្បីឱ្យផ្នែកពាក់ព័ន្ធ និងវិស័យឯកជនកាន់តែយល់ជ្រួតជ្រាបពីអ្វីដែលប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរបានខិតខំប្រឹងប្រែងរួមគ្នានោះ ។

នៅក្នុងជំនួបនោះដែរ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរក៏បានពិភាក្សាទាក់ទិនទៅនឹងបញ្ហាសន្តិសុខនៅក្នុងតំបន់ និងពិភពលោក ដែលមានការយកចិត្តទុកដាក់ដូចគ្នា ពិសេសការពិភាក្សាទៅលើកម្រិតនៃការធ្វើពាណិជ្ជកម្ម និងសេដ្ឋកិច្ចជាលក្ខណៈសកល និងដែលបម្រើឱ្យផលប្រយោជន៍របស់ប្រទេស និងប្រជាជនទាំងពីរ កម្ពុជា-បេឡារុស ។ សម្តេចតេជោបានលើកទឹកចិត្តឱ្យប្រទេសបេឡារុសធ្វើការសិក្សាស្រាវជ្រាវបន្ថែមពីសក្តានុពលនៃការផលិតស្បៀង ដើម្បីធ្វើការនាំចេញមកកាន់បេឡារុស និងទីផ្សារនៅសហគមន៍អឺរ៉ុបក៏ដូចជាទីផ្សារពិភពលោក ។

សម្តេចតេជោមានប្រសាសន៍ថា យើងបានខិតខំសម្រេចលើកិច្ចការជាច្រើនដែលមានផលប្រយោជន៍ និងការទទួលខុសត្រូវខ្ពស់ពីសំណាក់មន្ត្រីថ្នាក់ដឹកនាំគ្រប់ផ្នែកទាំងអស់ក្នុងការឈានទៅសម្រេចនូវពិធីចុះហត្ថលេខាលើឯកសារសំខាន់ៗទាំង ១០ ដែលបានចុះហត្ថលេខាក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចនាពេលនេះ។ អ្វីដែលសម្រេចបាននេះ គឺកើតចេញពីការតាំងចិត្ត និងការប្តេជ្ញាចិត្តរួមគ្នារបស់មន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលទាំងពីរ ក្នុងការឈានទៅសម្រេចនូវឯកសារគោលដែលបម្រើឱ្យផលប្រយោជន៍រួមនៃប្រទេសទាំងពីរ ។ សម្តេចបានសន្យាថានឹងខិតខំប្រឹងប្រែងធ្វើឱ្យសម្រេចបាននូវគោលដៅដែលរដ្ឋាភិបាលនៃប្រទេសទាំងពីរបានប្តេជ្ញារួមគ្នា ក្នុងការជំរុញទំហំពាណិជ្ជកម្ម និងការវិនិយោគឱ្យកាន់តែរីកចម្រើនទ្វេឡើងថែមទៀតនោះ។

គួរបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបេឡារុស បានភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នានៅថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៩៥ ។

បន្ទាប់ពីកិច្ចពិភាក្សាទ្វេភាគីចប់ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរបានអញ្ជើញចូលរួមធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើឯកសារកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នាចំនួន ១០ ។ក្នុងនោះរួមមាន: ទី១កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រសួងឧស្សាហកម្មនៃសាធារណរដ្ឋបេឡារុស ដែលភាគីកម្ពុជាចុះហត្ថលេខាដោយ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាមួយឯកឧត្តម Dzmitry Katriarynich រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ។ទី២កិច្ចព្រមព្រៀងសហប្រតិបត្តិការលើវិស័យសុខភាពសាធារណៈ រវាងក្រសួងសុខាភិបាលកម្ពុជា ជាមួយក្រសួងសុខាភិបាលបេឡារុស ចុះហត្ថលេខារវាងឯកឧត្តម **សុខ អាន** ជាមួយ ឯកឧត្តម Vasilii Jarko រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ ទី ៣ កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងរ៉ែ និងថាមពលកម្ពុជា ជាមួយក្រសួងឧស្សាហកម្មបេឡារុសចុះហត្ថលេខារវាងឯកឧត្តម **សុខ អាន** ជាមួយនឹងឯកឧត្តម Dzmitry Katriarynich រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មបេឡារុស ។ទី ៤ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើតទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងទីក្រុងមីនស្គ៍ នៃសាធារណរដ្ឋបេឡារុស ជាមួយរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខាដោយឯកឧត្តម **សុខ អាន** ជាមួយ ឯកឧត្តម Mikalai Ladutska ប្រធានគណៈកម្មការធិការក្រុងមីនស្គ៍ ។ ទី ៥ កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលបេឡារុស ចុះហត្ថលេខារវាង ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាមួយនឹងឯកឧត្តម Valiantsin Rybakou អនុរដ្ឋមន្ត្រីក្រសួងការបរទេសបេឡារុស ។ទី៦ អនុស្សរណៈនៃការយោគយល់គ្នារវាងធនាគារជាតិនៃកម្ពុជា និងធនាគារជាតិបេឡារុស ចុះហត្ថលេខារវាងឯកឧត្តម **ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាមួយលោកជំទាវ Nadzeja Yermakova ប្រធានធនាគារជាតិ បេឡារុស ។ ទី ៧ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីសហប្រតិបត្តិការលើវិស័យកសិកម្មរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកម្ពុជា និងក្រសួងកសិកម្ម និងអាហារបេឡារុស ចុះហត្ថលេខារវាង ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងឯកឧត្តម Uladzimir Grakun អនុរដ្ឋមន្ត្រីក្រសួងកសិកម្ម បេឡារុស និងទី ៨ កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការបច្ចេកទេសយោធារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ចុះហត្ថលេខារវាងឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** រដ្ឋលេខាធិការក្រសួងការពារជាតិជាមួយនឹងឯកឧត្តម Uladzimir Sulimau អនុប្រធានទី ១ នៃគណៈកម្មាធិការឧស្សាហកម្មយោធារដ្ឋ ។ ទី ៩ កិច្ចព្រមព្រៀងស្តីពីការជំរុញ និងការការពារការវិនិយោគទៅវិញទៅមក ដែលចុះហត្ថលេខាដោយឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាមួយនឹងឯកឧត្តម Valiantsin Rybakou អនុរដ្ឋមន្ត្រីក្រសួងការបរទេសបេឡារុស និងទី ១០ សេចក្តីប្រកាសរួមនៃប្រទេសទាំងពីរ ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបេឡារុស ដែលចុះហត្ថលេខា ដោយប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរ ។

ក្នុងឱកាសបំពេញទស្សនកិច្ចនៅបេឡារុសនោះដែរ សម្តេចតេជោ និងសមភាគី បានអញ្ជើញចូលរួមក្នុងវេទិកាធុរកិច្ច កម្ពុជា-បេឡារុស ដែលមានការចូលរួមពីសភាពាណិជ្ជកម្មកម្ពុជា និងអ្នកវិនិយោគបេឡារុសយ៉ាងច្រើន ។

គណៈប្រតិភូជាន់ខ្ពស់កម្ពុជាបានធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាពនារសៀលថ្ងៃទី២៦ ខែមេសា ដោយនាំមកនូវលទ្ធផលជាផ្លែផ្កាក្នុងទំនាក់ទំនងលើច្រើនវិស័យរវាងប្រទេសកម្ពុជា និងអាស៊ែបៃហ្សង់ កម្ពុជា និងបេឡារុស ។ សមិទ្ធិមួយថ្មីនៃកិច្ចសហប្រតិបត្តិការអន្តរជាតិនេះនឹងលើកកម្ពស់កិត្យានុភាពកម្ពុជាថែមទៀតលើឆាកអន្តរជាតិ និងរួមចំណែកដល់ការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជាលើមាគ៌ាដ៏រឹងមាំ ។/

# សម្តេចចក្រី ហេង សំរិន ចូលរួមពិធីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តស្ទឹងតូច នៅស្រុកពញាក្រែក

ថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៤ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តស្ទឹងតូច ស្ថិតនៅភូមិស្ទឹងតូច ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ។ ពិធីនេះបានប្រព្រឹត្តទៅដោយមានព្រះសង្ឃ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋចូលរួមយ៉ាងច្រើនកុះករ ។

មានប្រសាសន៍នៅក្នុងឱកាសនោះ សម្តេចចក្រី **ហេង សំរិន** បានលើកឡើងថា ព្រះសង្ឃមិនគ្រាន់តែបានផ្សព្វផ្សាយព្រះធម៌ដល់ពុទ្ធសាសនិកប៉ុណ្ណោះទេ ប៉ុន្តែបានចូលរួមសកម្មក្នុងការអភិវឌ្ឍសង្គមជាតិ ការងារអប់រំសីលធម៌ ចរិយាធម៌ និងគុណធម៌ដល់ពុទ្ធបរិស័ទផងដែរ ។

សម្តេចបានរំលឹកថាក្រោយប្រទេសជាតិយើងបានរំដោះវិស័យព្រះពុទ្ធសាសនាក៏បានចាប់កំណើតឡើងវិញ ។ យើងបានធ្វើការស្តារ ជួសជុល និងកសាងប្រទេសឡើងវិញជាបន្តបន្ទាប់ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងផ្នែកអាណាចក្រ និងពុទ្ធចក្រ ។ សាលារៀន មណ្ឌលសុខភាព វត្តអារាមត្រូវបានកសាងគ្រប់ទិសទី សំដៅសម្រួលដល់ការរៀនសូត្ររបស់សិស្សានុសិស្ស ផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋដោយគ្មានការរើសអើង និងបង្កភាពងាយស្រួលដល់ប្រជាជនក្នុងការគោរពប្រតិបត្តិព្រះពុទ្ធសាសនា ។ ចំពោះសមិទ្ធផលដែលកើតឡើងនាពេលនេះ ពិតជានឹងបំពេញតួនាទីយ៉ាងសំខាន់ក្នុងការបម្រើវិស័យព្រះពុទ្ធសាសនា ជាពិសេសសម្រាប់ព្រះសង្ឃតែម្តង ។ លើសពីនេះវិស័យពុទ្ធិកសិក្សាក៏មានការរីកចម្រើនជាលំដាប់ដែរ ដោយសព្វថ្ងៃនេះ យើងមានសាលាធម្មវិន័យចាប់តាំងពីថ្នាក់ត្រី ទោ និងឯក មានសាលាពុទ្ធិកសិក្សាពីថ្នាក់បឋមរហូតដល់ថ្នាក់ពុទ្ធិកវិទ្យាល័យនិងមានពុទ្ធិកសាកលវិទ្យាល័យថែមទៀតផង ។

ប្រការនេះបញ្ជាក់ច្បាស់ពីការយកចិត្តទុកដាក់របស់រដ្ឋសភា រាជរដ្ឋាភិបាល ក្នុងការផ្តល់ប្រយោជន៍ដល់ពុទ្ធសាសនិក និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ រួមជាមួយការខិតខំប្រឹងប្រែងរបស់បងប្អូនប្រជាពលរដ្ឋយើងគ្រប់ៗគ្នា ។ រដ្ឋសភា រាជរដ្ឋាភិបាលនៅតែបន្តខិតខំប្រឹងប្រែងអភិវឌ្ឍវិស័យព្រះពុទ្ធសាសនា ដើម្បីជាប្រយោជន៍ក្នុងការរួមចំណែកពង្រឹងសាមគ្គីភាពជាតិ ការលើកកម្ពស់វប្បធម៌នៃការយោគយល់គ្នាក្នុងចំណោមពុទ្ធសាសនិក ដោយយើងប្តេជ្ញាបន្តការការពារ គោរព និងលើកស្ទួយតម្លៃព្រះពុទ្ធសាសនាជាដរាប ធ្វើយ៉ាងណាឱ្យកម្លាំងដ៏មានឥទ្ធិពលនៃព្រះពុទ្ធសាសនាបន្តស្ថិតនៅ និងជ្រួតជ្រាបក្នុងបេះដូងនៃប្រជាជនខ្មែរ ។ សម្តេចមានជំនឿមុតមាំថា ព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ គណៈកម្មការអាចារ្យវត្ត និងពុទ្ធបរិស័ទចំណុះជើងវត្តទាំងអស់ នឹងរួមគ្នាថែរក្សា ការពារសមិទ្ធផលដ៏ថ្លៃថ្លានេះឱ្យបានស្ថិតស្ថេរគង់វង្ស ដើម្បីជាប្រយោជន៍ដល់ការពង្រឹងទាំងវិស័យសាសនា និងសីលធម៌សង្គម ។



*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** និងលោកជំទាវ កាត់ខ្សែបូសម្ពោធសមិទ្ធផលនានា និងបញ្ចុះខណ្ឌសីមាព្រះវិហារវត្តស្ទឹងតូច ស្ថិតនៅភូមិស្ទឹងតូច ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ*

តាមរបាយការណ៍ដែលបានលើកឡើងដោយឯកឧត្តម **ជឹម លាវ** អភិបាលរងខេត្តកំពង់ចាមបានឱ្យដឹងថា វត្តនេះត្រូវបានពុទ្ធបរិស័ទរួមនឹងអាជ្ញាធរមូលដ្ឋានផ្តើមកសាងឡើងក្នុងឆ្នាំ ១៩៩២ លើដីទំហំជាង ១ ហិកតា ស្ថិតនៅភូមិស្ទឹងតូច ឃុំកក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម បច្ចុប្បន្នជាខេត្តត្បូងឃ្មុំ និងមានឈ្មោះជាផ្លូវការថាវត្តមង្គលវន្តទី ២ ហៅវត្តស្ទឹងតូច ។ អាស្រ័យដោយជីវភាពប្រជាជនមានការរីកចម្រើន វត្តនេះត្រូវបានធ្វើការសាងសង់ជាថ្មីឡើងវិញ ដែលក្នុងនោះមានរួមទាំងព្រះវិហារថ្មីនេះផងដែរ ដែលគិតជាទឹកប្រាក់ចំណាយអស់ចំនួន ៥១៧.៣៣៩.៥៦៦ រៀល ក្នុងនោះថវិការបស់សម្តេចចក្រី ប្រធានរដ្ឋសភា និងលោកជំទាវ មានចំនួន ៨០.៦០០.០០០ រៀល ។

ក្នុងឱកាសនោះ សម្តេចចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាក៏បានបំពាក់គ្រឿងឥស្សរិយយស មេដាយ ការងារជូនដល់សប្បុរសជនដែលបានចំណាយទ្រព្យសម្បត្តិផ្ទាល់ខ្លួនជួយកសាងវត្តអារាម ជួយកសាងភូមិ ឃុំឱ្យមានការរីកចម្រើនចំនួន ៣០ នាក់ និងនាំយកថវិកាចំនួន ៥០ លានរៀល ប្រគេនដល់វត្តស្ទឹងតូចនេះជាប្រយោជន៍សម្រាប់ព្រះសង្ឃប្រើប្រាស់ក្នុងវិស័យព្រះពុទ្ធសាសនា ព្រមទាំងនាំយកអំណោយមានក្រណាត់ស សៀវភៅ ប៊ិច និងថវិកាមួយចំនួនជូនតាជី យាយជី សិស្សានុសិស្ស និងប្រជាពលរដ្ឋជាច្រើននាក់ ។/

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី ៦ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តម **ស ខេង** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវក្រាលកៅស៊ូប្រវែង ១១៦០០ ម៉ែត្រ និងទទឹង ៥ ម៉ែត្រដែលឆ្លងកាត់ឃុំវត្តតាមិម ស្រុកសង្កែ និងឃុំបាយដំរាំ ស្រុកបាណន់ ខេត្តបាត់ដំបង ។ផ្លូវមួយខ្សែនេះចំណាយថវិកាចំនួន ៤.៥៨៧ លានរៀល ដែលជាគម្រោងថវិកាឆ្នាំ ២០១៣ ។

*ថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ១ ព្រឹទ្ធសភា ប្រធានគណៈប្រចាំការគណៈចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងជាអនុប្រធានទី ១ នៃក្រុមការងាររបស់គណៈកម្មាធិការកណ្តាលចុះជួយរាជធានីភ្នំពេញ ឯកឧត្តម **ស៊ីម កា** សមាជិកគណៈចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល បានជួបសំណេះសំណាលជាមួយសមាជិក សមាជិកាគណបក្សដែលជាសមាជិកនៃក្រុមប្រឹក្សាសង្កាត់នៅទូទាំងរាជធានីភ្នំពេញ ចំនួនជិត ៦០០ នាក់ នៅទីស្នាក់ការកណ្តាលរបស់គណបក្ស ។នៅក្នុងឱកាសនោះ សមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ បានស្តាប់នូវការបកស្រាយរបស់បណ្តាមន្ទីរជំនាញជុំវិញរាជធានី អំពីបញ្ហានានាដែលទាក់ទងនឹងការផ្តល់សេវារបស់ថ្នាក់ក្រោមជាតិ បញ្ហាដីធ្លី បញ្ហាអគ្គិសនី បញ្ហាសណ្តាប់ធ្នាប់ក្នុងរាជធានី ទំនាក់ទំនងរវាងប្រជាជនជាមួយបណ្តាក្រុមហ៊ុន ការថ្នាំងថ្នាក់របស់អាជីវករតាមផ្សារ ការថ្នាក់ថ្នាំងចំពោះបញ្ហាពុករលួយ ។ល។ ឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនាពេលខាងមុខនេះ ឯកឧត្តម **សាយ ឈុំ** បានណែនាំដល់អង្គពិធីទាំងមូលឱ្យយកចិត្តទុកដាក់ដល់ការពង្រឹងទំនាក់ទំនងរវាងមន្ទីរ អាជ្ញាធរ និងអង្គបោះឆ្នោត ពង្រឹងសាមគ្គីភាពរវាងបណ្តាស្ថាប័ន និងអ្នកដែលមានការពាក់ព័ន្ធទាំងអស់ ដើម្បីលើកកម្ពស់ការចូលរួមយុទ្ធនាការឃោសនាបោះឆ្នោតខាងមុខនេះ ព្រមទាំងធានាឱ្យបាននូវសុខភាពទាំងផ្លូវកាយ និងផ្លូវចិត្តរបស់អង្គបោះឆ្នោត ។*





ថ្ងៃទី ៦ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តមបណ្ឌិត **ខួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី ១ នៃរដ្ឋសភា បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធ និងបុណ្យឆ្លងសមិទ្ធផលនានា ព្រមទាំងបូជាព្រះសពអតីតព្រះចៅអធិការវត្តបារាយណ៍ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដែលក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ខួន ញឹល** បាននាំបច្ច័យ ថវិកា និងសម្ភារៈប្រគេន និងផ្តល់ជូនរួមមាន ប្រគេនបច្ច័យចំនួន ៤០០០ ដុល្លារ សម្រាប់រៀបចំពិធីបុណ្យ ។ ប្រគេនបច្ច័យ ១៨.៨១០.០០០ រៀល និង ៦០០ ដុល្លារ សម្រាប់កសាងសមិទ្ធផលក្នុងវត្តបារាយណ៍ ។ ជូនចាស់សីលវតីចំនួន ១០០ នាក់ ក្នុងម្នាក់ៗក្រណាត់ ស ១ ដុំ និងថវិកា ១ ម៉ឺនរៀល ។ ជូនប្រជាជនចូលរួមចំនួន ១០០០ នាក់ ក្នុងម្នាក់ៗសារុង ១ ។ ជូនលោកគ្រូ អ្នកគ្រូចំនួន ១៣៩ នាក់ ក្នុងម្នាក់ៗ ២ ម៉ឺនរៀល ជូនសិស្សានុសិស្សចំនួន ៧០៥ នាក់ ក្នុងម្នាក់ៗ សៀវភៅ ១ ក្បាល ប៊ិច ១ ដើម និងថវិកា ៣ ពាន់រៀល ជូនក្រុមភ្លេងពិណពាទ្យ ១០ ម៉ឺនរៀល ។ ជូននារីកាន់ខ្សែបូ ១០ ម៉ឺនរៀល ។ ឧបត្ថម្ភសាលាស្រុកបារាយណ៍ ១ លានរៀល និងសាលាឃុំបារាយណ៍ថវិកា ១ លានរៀល ។





*ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងក្នុងនាមប្រធានក្រុមការងារថ្នាក់ជាតិចុះខេត្តតាកែវ បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋមកពី ១០ ស្រុក នៅទីរួមខេត្តតាកែវ ។នាពេលនោះឯកឧត្តមបានជំរុញឱ្យអាជ្ញាធរមូលដ្ឋានត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ ជាពិសេសត្រូវខិតខំរៀបចំបើកវេទិការសាធារណៈឱ្យបានច្រើន ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០១៤ លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច បានអញ្ជើញជាអធិបតីក្នុងពិធី សម្ពោធសមិទ្ធផលនានា ដែលចំណាយថវិកាសាងសង់សរុបចំនួនជាង ១០ ម៉ឺនដុល្លារអាមេរិក ក្នុងនោះរួមមានប្រព័ន្ធទឹកស្អាត និងសាលារៀន ១ ខ្នង មាន ៤ បន្ទប់ នៃសាលាបឋមសិក្សាមិត្តភាពខ្មែរ-វៀតណាម ស្ថិតនៅភូមិព្រៃឆ្លាក់ សង្កាត់ព្រៃឆ្លាក់ ក្រុងស្វាយរៀង ខេត្តស្វាយរៀង ។ ក្នុងឱកាសនោះ លោកជំទាវ **ម៉ែន សំអន** បានសម្ដែងនូវការចូលរួមអបអរសាទរ និងថ្លែងអំណរគុណចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់និងមន្ត្រីជាន់ខ្ពស់ក្នុងរាជរដ្ឋាភិបាលសប្បុរសជនជិតឆ្ងាយ ពិសេសមិត្តវៀតណាម ខេត្តឡុងអាន ខេត្តតៃនិញ ខេត្តដុងថាប់ និងក្រុងហូជីមិញព្រមទាំងប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងព្រះសង្ឃ ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ ។





*ថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តម **កែ គឹមយ៉ាន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងលោកជំទាវ បានអញ្ជើញសម្ពោធកុដិ និងសមិទ្ធផលនានានៅវត្តប្រាសាទស្រះឈ្ងួរ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ វត្តប្រាសាទស្រះឈ្នួរមានផ្ទៃដីទំហំ ៤៨.៦៥៧ ម៉ែត្រការ៉េ ចាប់ផ្ដើមកសាងនៅគ.ស ១៨១២ ត្រូវនឹងព.ស ២៣៥៦ គឺមានអាយុកាល ២០២ ឆ្នាំមកហើយ ។*



ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០១៤ នៅសាលមហោស្រពខេត្តកោះកុង ឯកឧត្តម **តេព ងន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី ២ ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីបើកវេទិកាស្ដីពីសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី ៧ និងផលប្រយោជន៍ក្រុមប្រឹក្សាឃុំ-សង្កាត់ខេត្តកោះកុង ។ឯកឧត្តម**តេព ងន** បានផ្ដល់ទស្សនៈសំខាន់ៗមួយចំនួនជុំវិញប្រធានបទ ដើម្បីជាគំនិតសម្រាប់វេទិកាពិភាក្សា សមាជិកព្រឹទ្ធសភាភាគច្រើនលើសលប់ត្រូវបានបោះឆ្នោតជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងរាស្ត្រ ។ ហេតុនេះសមាជិកព្រឹទ្ធសភាជាអ្នកតំណាងឱ្យសិទ្ធិនិងផលប្រយោជន៍របស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងផលប្រយោជន៍របស់ប្រជាជាតិខ្មែរទាំងមូល ។ ក្នុងការបំពេញតួនាទីជាតំណាងបានល្អ សមាជិកព្រឹទ្ធសភាម្នាក់ៗត្រូវចូលរួមយ៉ាងសកម្មក្នុងការតាមដានវាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍឃុំ សង្កាត់ ផ្ដល់អនុសាសន៍តាមរយៈការចុះជួបផ្ទាល់ និងធ្វើវេទិកានានា ចូលរួមបដិភាគក្នុងគម្រោងជាក់លាក់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ បង្កលក្ខណៈងាយស្រួល និងជួយជំរុញឱ្យមានទំនាក់ទំនងសហប្រតិបត្តិការគ្រប់រូបភាពជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៃប្រទេសជាដៃគូនានា ដើម្បីទទួលបានការគាំទ្រ និងការជួយឧបត្ថម្ភផ្សេងៗ ។



*ថ្ងៃទី៩ខែមេសាឆ្នាំ២០១៤ឯកឧត្តម**អ៊ឹម ឈុនលឹម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខនាយទាហាន ពលទាហាននៃយោធភូមិភាគទី ៣ នៅខេត្តកំពង់ស្ពឺ ។ នាឱកាសនោះឯកឧត្តមបានប្រគល់ថវិកាចំនួន ៣៧ ៦០០ ដុល្លារ ជូនដល់អង្គភាពយោធភូមិភាគទី ៣ និងសំភារៈមួយចំនួនទៀត សម្រាប់សាង សង់អគារវិទ្យុទាក់ទងមួយខ្នង ព្រមទាំងឧបត្ថម្ភថវិកា ៤ លានរៀល រួមនិងអំណោយមួយចំនួន សម្រាប់រៀបចំកម្មវិធីជួបជុំពិសាអាហារដើម្បីអបអរសាទរទទួលអំណរឆ្នាំថ្មី ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា និងលោកជំទាវ បានអញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបូសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលនានានៅវត្តពោធិវណ្ណារាម ហៅវត្តពោធិខាវ ក្នុងឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ ។សមិទ្ធផលទាំងនេះរួមមានកុដិមួយខ្នងកម្ពស់ពីរជាន់ ទំហំ ១១,៥០ ម៉ែត្រគុណនឹង ៧,៥០ ម៉ែត្រ ដែលចំណាយថវិកា ៤២១១៥ ដុល្លារអាមេរិក។ ព្រះវិហារបណ្តោយ ២៦ ម៉ែត្រ និងទទឹង ១១,៨០ ម៉ែត្រ ចំណាយថវិកា ៨៩៦៥២ ដុល្លារ ដែលកើតចេញពីសទ្ធាជ្រះថ្លារបស់ឯកឧត្តម និងលោកជំទាវ ព្រមទាំងប្រជាពលរដ្ឋពុទ្ធបរិស័ទចំណុះជើងវត្ត និងសប្បុរសជនជិតឆ្ងាយ ។



*ថ្ងៃទី ៦ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អគ្គស្នងការនគរបាលជាតិ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយផ្តល់ជូនដល់កងនគរបាលជាតិប្រចាំទិសយោធភូមិភាគទី ៤ ស្ថិតនៅក្នុងបញ្ជាការនគរបាលជាតិភូមិភាគទី ៤ ខេត្តព្រះវិហារ ។ ក្នុងឱកាសនោះឯកឧត្តមនាយឧត្តមសេនីយ៍បាននាំយកថវិកា និងគ្រឿងឧបភោគបរិភោគជាច្រើនសរុបទឹកប្រាក់ប្រមាណ ៤០០ លានរៀល ប្រគល់ និងចែកជូនដល់ទីបញ្ជាការនគរបាល-ជាតិភូមិភាគ ៤ និងបែងចែកទៅតាមវរចំណុះទីបញ្ជាការនានាផងដែរ ។*



ថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសិប្បកម្មនិងឧស្សាហកម្ម បានអញ្ជើញជួបសំណេះសំណាលជាមួយមន្ត្រីមូលដ្ឋានរបស់គណបក្សនៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ខេត្តកែប ។ជំនួបនេះក៏ផ្តោតទៅលើការត្រៀមខ្លួនជាស្រេចផងដែរសម្រាប់ការបោះឆ្នោតក្រុម-ប្រឹក្សារាជធានី ខេត្ត ខណ្ឌ ស្រុក នៅថ្ងៃទី ១៨ ខែឧសភា ខាងមុខ។



*ថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តម **ស៊ុយ សែម** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងឯកឧត្តម **ខូយ សុខា** អភិបាលនៃគណៈអភិ-បាលខេត្តពោធិ៍សាត់ បានអញ្ជើញសម្ពោធផ្តិលដ៏ធំដែលធ្វើពីថ្មកែវនៅរង្វង់មូល ដែលមានចម្ងាយ ប្រ-មាណ ៥ គីឡូម៉ែត្រខាងកើតទីប្រជុំជនក្រុងពោធិ៍សាត់ ។ ផ្តិលមានគម្របឆ្លាក់អំពីថ្មកែវ ស្ថិតនៅលើជើងពានមានខឿនថ្មទម្រ ។ ផ្តិលមានជើងទម្របីថ្នាក់ ។ មានអង្កត់ផ្ចិត ១១,២០ ម៉ែត្រ កម្ពស់ ៣,១៥ ម៉ែត្រ ។ តួផ្តិលកម្ពស់ដល់គម្របលើកំពស់ ៨,៨៥ ម៉ែត្រ អាចផ្ទុកទឹកប្រមាណ ១៣៥ ម៉ែត្រគូប ។*



ថ្ងៃ៨ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តម **អ៊ិត សំហេង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខនាយទាហានពលទាហាន និងក្រុមគ្រួសារកងទ័ព ដោយនាំយកអំណោយជាស្បៀងអាហារ និងសំភារៈប្រើប្រាស់ជាច្រើន ឧបត្ថម្ភដល់កងទ័ពជួរមុខនៃកងពលតូចអន្តរាគមន៍លេខ ៧ ដែលស្ថិតនៅឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តម **វង សូត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាអគ្គលេខាធិការស្តីទីសមាគមអតីតយុទ្ធជនកម្ពុជា បានអញ្ជើញប្រគល់ផ្ទះចំនួនបីខ្នងជូនដល់គ្រួសារអតីតយុទ្ធជនដែលជាជនពិការក្រីក្រចំនួនបីគ្រួសារ ស្ថិតនៅក្នុងភូមិឃ្លៃ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ផ្ទះនេះជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។





*ថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០១៤ ឯកឧត្តម **ម៉ម ប៊ុនហេង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានអញ្ជើញប្រគល់ឱសថចំនួន ៣១ មុខ ជូនដល់មន្ទីរពេទ្យយោធភូមិភាគ ៥ មានតម្លៃជាង ១៤១ លានរៀល នៅខេត្តបាត់ដំបង ។ ឯកឧត្តមក៏បានអញ្ជើញសួរសុខទុក្ខ និងជូនអំណោយតម្លៃជាង ៥ ម៉ឺនដុល្លារអាមេរិក ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ដល់មេបញ្ជាការមេបញ្ជាការរង នាយ នាយរង និងពលទាហាន កងពលតូចថ្មើរជើងលេខ ៥១ នៅខេត្តបន្ទាយមានជ័យផងដែរ ។*



ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤ លោកជំទាវ **មាន សំអាន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា សមាជិកព្រឹទ្ធសភា បានអញ្ជើញផ្តល់រទេះរុញចំនួន ១០០ គ្រឿង ជាអំណោយមូលនិធិរបស់ព្រះសងវៀតណាម ជូនដល់ប្រជាពលរដ្ឋពិការចំនួន ១០០ នាក់ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ **ប៊ុន រ៉ានី ហ៊ុន សែន** ពោធិសាត់ ក្រុងពោធិសាត់ ខេត្តពោធិសាត់ ។



*ថ្មីៗនេះដែរឯកឧត្តម **ប៉ា សុជាតិវង្ស** ប្រធានណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ អភិបាលរាជធានីភ្នំពេញ បានអញ្ជើញពិនិត្យការបើកការដ្ឋាន ៤ កន្លែង កំពុងដាក់ប្រព័ន្ធលូប្រឡាយក្នុងក្រុងជំហានទី ៣ ដើម្បីបន្ថយការលិចដោយទឹកភ្លៀង ។ ការដ្ឋានក្នុងជំហានទី ៣ នេះចាប់ផ្តើមដាក់បណ្តាញលូមេថ្មីដើម្បីរំដោះទឹកចេញពីតំបន់អូរឫស្សី តំបន់បឹងរាំង និងតំបន់ទួលស្វាយព្រៃ ។*



ថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៤ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឯកឧត្តម **ឃឹម ប៊ុនសុង** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងក្នុងនាមជាខេត្តសម្ព័ន្ធមេត្រីភាព បានដឹកនាំគណៈប្រតិភូអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ ព្រមទាំងនាំយកគ្រឿងឧបភោគបរិភោគ ដែលជាអំណោយរបស់រដ្ឋបាលខេត្តសៀមរាប ឧបត្ថម្ភជូនដល់នាយទាហាន ពលទាហាន កងពលតូចអន្តរាគមន៍លេខ ៥ នៃកងពលធំអន្តរាគមន៍លេខ ២ ឈរជើងនៅភូមិ ឈើស្លាប់នៃស្រុកបន្ទាយអម្ពិល ខេត្តឧត្តរមានជ័យ ។

# លទ្ធផលមួយចំនួននៅវិស័យសេដ្ឋកិច្ច

### ប្រាក់បញ្ញើត្រីមាសទី ១ ឆ្នាំ ២០១៤

ធនាគារជាតិនៃកម្ពុជាបានបញ្ជាក់ថា សម្រាប់ត្រីមាសទី ១ ឆ្នាំ ២០១៤ នេះ សាធារណជនមកដាក់ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជាមានទំហំទឹកប្រាក់ប្រមាណ ៧ ០០០ លានដុល្លារអាមេរិក ។ តួលេខនេះគឺមានការកើនឡើងប្រមាណ ១៨% ។ ដោយឡែកប្រាក់កម្ចីវិញមានទំហំទឹកប្រាក់ប្រមាណ ៦ ០០០ លានដុល្លារ ដែលបានរួមចំណែក ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

កត្តាដែលជំរុញឱ្យមានការកើនឡើងទាំងប្រាក់បញ្ញើ និងប្រាក់កម្ចីនេះគឺដោយសារកត្តាសំខាន់ពីរ : ទី ១. ប្រជាជនមានការទុកចិត្តមកលើរាជរដ្ឋាភិបាល និងទី ២.ការរក្សាបាននូវសន្តិភាពនិងស្ថិរភាពនយោបាយ ។ ការជឿទុកចិត្តវាមានសារៈសំខាន់ណាស់ ។

ដោយឡែកប្រាក់បញ្ញើរបស់សាធារណជនផ្ញើតាមរយៈធនាគារពាណិជ្ជ ធនាគារឯកទេស តាមរយៈមីក្រូហិរញ្ញវត្ថុមានការកើនឡើងផងដែរ ដែលធ្វើឱ្យប្រព័ន្ធប្រតិបត្តិកររបស់ធនាគារជាតិនៃកម្ពុជាចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។

### កំណើនសេដ្ឋកិច្ចកម្ពុជាព្យាករណ៍ដោយធនាគារពិភពលោក

តាមការព្យាករណ៍របស់ធនាគារពិភពលោក(WB)ដែលបានប្រកាសកាលពីថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០១៤ កន្លងទៅនេះបានបង្ហាញថា អត្រាកំណើនផលិតផលក្នុងស្រុកសរុប(GDP)របស់កម្ពុជានៅឆ្នាំ ២០១៤ នេះ នឹងអាចសម្រេចបាន ៧,២% ។ នេះគឺខ្ពស់ជាងការព្យាករណ៍មុនចំនួន ០,២% ដែលដូចគ្នាជាមួយប្រទេសឡាវ ។ ជាមួយគ្នានេះដែរ ប្រទេសមីយ៉ាន់ម៉ាត្រូវបានព្យាករណ៍ថាសម្រេចកម្រិតកំណើន ៧,៦% បន្ទាប់ពីនោះតាមលំដាប់រៀងគ្នាគឺហ្វីលីពីន ៦,៦% វៀតណាម ៥,៥% ឥណ្ឌូណេស៊ី ៥,៣% ម៉ាឡេស៊ី ៤,៩% និងប្រទេសថៃ ៣% ។

ធនាគារពិភពលោកបានបញ្ជាក់ថាការព្យាករណ៍ល្បឿនកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា គឺផ្អែកលើការវាយតម្លៃអំពីការរំពឹងទុកនៃស្ថិរភាពនយោបាយក្នុងប្រទេស រួមជាមួយនឹងបរិបទសេដ្ឋកិច្ចពិភពលោកដែលមានកំណើនឡើងវិញ ។ សេដ្ឋកិច្ចកម្ពុជាកំពុងស្ថិតក្នុងដំណើរការកែទម្រង់សំដៅបង្កើនប្រសិទ្ធភាព ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចក្នុងស្រុក និងការរក្សាកំណើន ។

ចំពោះឆ្នាំ២០១៥និង២០១៦ខាងមុខ ធនាគារពិភពលោករក្សាការព្យាករណ៍អំពីកំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅកម្រិត ៧% ។

កម្រិតព្យាករណ៍អំពីកំណើនសេដ្ឋកិច្ចកម្ពុជារបស់ធនាគារពិភពលោកមានភាពខុសគ្នា បើប្រៀបជាមួយការវាយតម្លៃមុននោះរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានវាយតម្លៃថា កម្ពុជានឹងសម្រេចកម្រិតកំណើនផលិតផលក្នុងស្រុកសរុប (GDP) ប្រមាណ ៧% នៅក្នុងឆ្នាំនេះនិង ៧,៣% នៅក្នុងឆ្នាំក្រោយ ។

### ការចុះបញ្ជីយានយន្តត្រីមាសទី ១ ឆ្នាំ ២០១៤ :

នាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការនិងដឹកជញ្ជូន បានបញ្ជាក់ថា យានយន្តដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងរយៈពេលបីខែដើមឆ្នាំ ២០១៤ នេះ មានចំនួន ៨៥ ៧៧៤ គ្រឿង ក្នុងនេះមានរថយន្តចំនួន ១០ ៤៦៤ គ្រឿង និងម៉ូតូ ៧៥ ៣១០ គ្រឿង ។

សូមបញ្ជាក់ថាក្នុងការចុះបញ្ជីយានយន្តរយៈពេលត្រីមាសទី១នេះគេអាចកត់សម្គាល់ឃើញមានការកើនឡើងតែម៉ូតូទេតែចំពោះរថយន្តវិញបានថយចុះ ។ ចំនួនម៉ូតូចុះបញ្ជីមានចំនួនដល់ ៧៥ ៣១០ គ្រឿង បើប្រៀបធៀបរយៈពេលដូចគ្នានៃឆ្នាំ ២០១៣ មានការកើន ឡើងចំនួនប្រមាណ ៥ ៦៦០ គ្រឿង ស្មើនឹង ៨,១% ។ តែចំពោះរថយន្តវិញមានចំនួនតែ១០៤៦៤គ្រឿងគឺបានថយចុះប្រមាណ១៩,១៥% ។

ចំនួនយានយន្តចុះបញ្ជីនាត្រីមាសទី ១ នេះដែរ គឺមានការកើនឡើងភាគច្រើននៅរាជធានីភ្នំពេញ ។ ចំនួនម៉ូតូកើនឡើងខ្លាំងនេះ ដោយសារកន្លងទៅនេះមានការទិញលក់តាមរយៈការបង់រំលស់ជាច្រើនក្រុមហ៊ុន ។

គួររំលឹកថា យានយន្តដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងសាធារណការ និងដឹកជញ្ជូនគិតត្រឹមដំណាច់ឆ្នាំ ២០១៣ មានចំនួនប្រមាណ ២,៤ លានគ្រឿង ដែលក្នុងនេះមានម៉ូតូប្រមាណ ២,១ លានគ្រឿង ។

### ពាណិជ្ជកម្មនាំចេញ នាំចូលត្រីមាសទីមួយ :

យោងតាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា ត្រីមាសទីមួយឆ្នាំ ២០១៤ នេះ ទំហំពាណិជ្ជកម្មនាំចេញ នាំចូលរបស់កម្ពុជាសម្រេចបានចំនួន ៤,៤៦ ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើងចំនួន ១៥% បើប្រៀបធៀបជាមួយពេលវេលាដូចគ្នាកាលពីឆ្នាំមុន ។

ក្នុងតួលេខខាងលើនេះ តម្លៃនៃការនាំចេញរបស់កម្ពុជាសម្រេចបានចំនួន ១,៩៩ ពាន់លានដុល្លារ ដោយកើនឡើងចំនួន ១៩% ។ ចំណែកការនាំចូលចំនួន ២,៤៧ ពាន់លានដុល្លារ កើនឡើងចំនួន ១២%បើធៀបជាមួយរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

ការនាំចេញទំនិញវាយនភណ្ឌនិងសម្លៀកបំពាក់មានចំនួនប្រមាណជាង៨០% ។ ដៃគូពាណិជ្ជកម្មសំខាន់របស់កម្ពុជារួមមានបណ្ដាប្រទេសក្នុងទ្វីបអឺរ៉ុប អាមេរិក ចិន ជប៉ុន និងបណ្ដាប្រទេសផ្សេងៗទៀតនៅក្នុងសមាគមប្រជាជាតិអាស៊ី ដូចជាថៃ សិង្ហបុរី និងវៀតណាម ។

### ចំណូលរដ្ឋាករទឹកស្វយ័តភ្នំពេញ :

រដ្ឋាករទឹកស្វយ័តភ្នំពេញបានអះអាងថា ក្នុងឆ្នាំ២០១៣ កន្លងទៅនេះ អង្គភាពទទួលបានចំណូលសរុបប្រមាណ ១៥១ ពាន់លានរៀល និងប្រាក់ចំណេញមុនបង់ពន្ធ ៤៨ ពាន់លានរៀល ។ កាលពីឆ្នាំ ២០១២ ទទួលបានចំណូលសរុប ១៣៥ ពាន់លានរៀល និងប្រាក់ចំណេញមុនបង់ពន្ធជិត ៤៣ ពាន់លានរៀល ។ ចំពោះលទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិកក្នុងឆ្នាំ ២០១៣ មានចំនួន ៣៨ ពាន់លានរៀល ។ អត្រាចំណេញក្រោយបង់ពន្ធប្រាក់ចំណេញ ធៀបនឹងទ្រព្យសកម្មមានកម្រិត ៣,៦៣% ។ ចំណែកឯអត្រាចំណេញក្រោយបង់ពន្ធប្រាក់ចំណេញធៀបនឹងមូលធនមានកម្រិត ៥,៦២% ។

រដ្ឋាករទឹកស្វយ័តបានបញ្ជាក់ថាប្រាក់ចំណេញដែលមានការកើនឡើងរាល់ឆ្នាំនេះ គឺដោយសាររដ្ឋាករទឹក ធានាបាននូវការផ្គត់ផ្គង់ទឹក ២៤ ម៉ោង ជាមួយនឹងគុណភាពដែលអាចទទួលទានបានដោយផ្ទាល់ពីរ៉ូប៊ីណេ ។

### ទេសចរណ៍ខែកុម្ភៈ ឆ្នាំ ២០១៤ :

ទេសចរអន្តរជាតិមកទស្សនាកម្ពុជាក្នុងខែកុម្ភៈ ឆ្នាំ ២០១៤ មានចំនួន ៤២៥ ៨០១ នាក់ កើនឡើង ១០,៤% ធៀបនឹងខែកុម្ភៈ ឆ្នាំ២០១៣ ។ ទីផ្សារទេសចរណ៍សំខាន់ៗមកកម្ពុជា ២ ខែដើមឆ្នាំ ២០១៤ នេះមាន កូរ៉េ ១៤១ ២៥៣ នាក់ វៀតណាម ១១៤ ៨៤១ នាក់ ចិន ១១២ ៧៩៧ នាក់ ឡាវ ៦៤ ៦៦៨ នាក់ ជប៉ុន ៤២ ៤៥៥ នាក់ អាមេរិក ៤១ ០៧៧ នាក់ រុស្ស៊ី ៤០ ៦៧៧ នាក់ បារាំង ៣២ ៦៤៤ នាក់ ថៃ ៣២ ៥៣៧ នាក់ និងអង់គ្លេស ២៧ ៩៥៨ នាក់ ។

ដោយឡែកទេសចរកម្ពុជាចេញទៅក្រៅប្រទេសក្នុងរយៈពេល ២ ខែ ដើម ឆ្នាំ ២០១៤ មានចំនួន ១៣៦ ៩៤២ នាក់ ថយចុះ ០,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៣ ។/



# វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ កំពុងតែខិតខំឈានឱ្យទាន់ ការរីកចម្រើននៃបច្ចេកវិទ្យាទំនើប

**• ឆ្នាំ ២០១៣ មានអ្នកប្រើ Internet ជិត ៤ លាននាក់**

រាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ខ្ពស់លើវិស័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ដែលជាវិស័យអាទិភាព និងជាឆ្អឹងខ្នងសម្រាប់ទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រមទាំងការអភិវឌ្ឍវិស័យដទៃទៀត ។

ឯកឧត្តម **ត្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានប្រសាសន៍ថា ក្រសួងបានប្តេជ្ញាចិត្តខិតខំបណ្តុះបណ្តាលជំនាញដល់មន្ត្រីក្រោមឱវាទឱ្យដើរទាន់មហិច្ឆតាបច្ចេកវិទ្យាដើម្បីប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ដោយផ្អែកលើការវិវត្តប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គមនិងផ្អែកលើការការពារដែលធានានូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ សាធារណៈ តាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ ។ បញ្ហាប្រឈមជាច្រើន ដែលបន្សល់ពីអាណត្តិមុន យើងត្រូវតែរួមគ្នាដោះស្រាយឱ្យបានច្បាស់លាស់ទាំងអស់គ្នានៅអាណត្តិនេះ មានន័យថា យើងត្រូវប្រមើលមើលសម្រាប់អនាគត ។ ហេតុនេះ ក្នុងន័យកំណែទម្រង់ស៊ីជម្រៅ ក្រសួងប្រៃសណីយ៍នឹងខិតខំកសាងនូវគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍មូលដ្ឋានច្បាប់ លិខិតបទដ្ឋានគតិយុត្តិ បង្កើនសមត្ថភាពធនធានមនុស្ស ប្រសិទ្ធភាពនៃបញ្ញត្តិកម្ម ដើម្បីដើរឱ្យទាន់មហិច្ឆតាបច្ចេកវិទ្យាទំនើប ។ ឯកឧត្តមបន្តថា ការបណ្តុះបណ្តាលធនធានមនុស្ស ការកែប្រែទម្លាប់ កែប្រែឥរិយាបថរបស់មនុស្សគឺជាការងារដែលមានសារសំខាន់នៅក្នុងអង្គភាពស្ថាប័នរបស់យើង ។ ប្រសិនបើយើងមានសមត្ថភាព យើងនឹងរកឃើញនូវបញ្ហាប្រឈមនានាជាច្រើន ដូចជាបទល្មើសកេងចំណេញក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ បទឧក្រិដ្ឋផ្សេងៗពាក់ព័ន្ធនឹងវិស័យ ហើយពង្រឹងដល់ការបំបាត់អំពើអសកម្មនានា ការគ្រប់គ្រងការប្រកួតប្រជែងក្នុងលក្ខណៈស្មោះត្រង់ ការបំពាក់ និងការធ្វើទំនើបកម្មឧបករណ៍សម្ភារៈប្រកបដោយគុណភាព និងប្រសិទ្ធភាព ការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន ការបង្កើនទំនាក់ទំនងសហប្រតិបត្តិការជាមួយប្រទេសនានាក្នុងតំបន់និងជាមួយអន្តរជាតិជាដើម ដែលទាំងអស់នេះជាទិសដៅដែលក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវតែធ្វើការកែទម្រង់ និងអនុវត្តសម្រាប់ឆ្នាំ ២០១៤ នេះ ។



*ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅរាជធានីភ្នំពេញ*

ឯកឧត្តមរដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា គោលដៅរបស់ក្រសួងប្រៃសណីយ៍ គឺបន្តរៀបចំប្រព័ន្ធប្រៃសណីយ៍ឱ្យមានលក្ខណៈទំនើបទាន់សម័យ ប្រកបដោយគុណភាពស្របតាមស្តង់ដារអន្តរជាតិ និងជួយឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់ និងទទួលផលប្រយោជន៍ពីវិស័យនេះបានគ្រប់ៗគ្នា បន្តពង្រឹង និងកសាងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ដោយជំរុញការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ កសាង និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ឆ្អឹងខ្នង បង្កើនសហប្រតិបត្តិការ លើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន ដើម្បីបន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការធ្វើទំនើបកម្មវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ជំរុញការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព ប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័ស





*បង្គោលបណ្តាញទូរស័ព្ទចល័ត និងផ្កាយរណបរបស់រដ្ឋ និងក្រុមហ៊ុនឯកជននានាតម្លើងពង្រាយតាមបណ្តាខេត្តនានាទូទាំងព្រះរាជាណាចក្រកម្ពុជា*



បណ្តាញខ្សែកាបអុបទិក និងខ្សែបណ្តាញណឺតវើត
នៃប្រព័ន្ធអ៊ិនធឺណែត



នៃបច្ចេកវិទ្យាទំនើបនាសម័យនេះ ។

តាមរបាយការណ៍របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានឱ្យដឹងថា ចំណូលក្នុងឆ្នាំ ២០១៣ របស់ប្រៃសណីយ៍កម្ពុជាមានចំនួនសរុប ៤ ៥៦៣ ០៩២,៥១ដុល្លារអាមេរិក ស្មើនឹង ១១១,៦៧% នៃផែនការប្រចាំឆ្នាំ ។ ក្នុងនោះ ចំណូលបានមកពីការលក់តែមប្រៃសណីយ៍ចំនួន ៥០ ១០៨,២៥ ដុល្លារ បានពីសេវាបញ្ញើលិខិត និង កញ្ចប់ធម្មតាចំនួន ៧៣២ ៤៦៣,២៤ ដុល្លារ បានពីជួលប្រអប់សំបុត្រចំនួន ១៨ ៩៧៨,១៥ ដុល្លារ បានពីសេវាបញ្ញើ EMS ចំនួន ២ ១៦១ ៩០២,៦៤ ដុល្លារ បានពីសេវាបញ្ញើប្រៃសណីយ៍ភណ្ឌចំនួន ១ ១៥០ ១៣២, ៨១ ដុល្លារ បានពីការទូទាត់ជាមួយដៃគូអន្តរជាតិចំនួន ៣៤៦ ៧៩២,៥០ ដុល្លារ បានពីការថែរក្សាទុកដាក់បញ្ញើចំនួន ៤៥ ០០១,៣៣ ដុល្លារ បានពីការលក់ប្រអប់វេចខ្ចប់ចំនួន ៣៤ ៦១៨,៨៤ ដុល្លារ បានពីសេវាអាណត្តិប្រៃសណីយ៍ចំនួន៧៩៥,៦៣ដុល្លារ បានពីសេវាទូរគមនាគមន៍ចំនួន ៧ ០៦៩,៧៤ ដុល្លារ និងបានពីផលហិរញ្ញវត្ថុផ្សេងៗ ចំនួន ១៥ ៣០៩,៣៨ ដុល្លារ ។

ជាមួយនឹងផលចំណូលដែលទទួលបាននេះ ការចំណាយនៅក្នុងឆ្នាំ ២០១៣ របស់ប្រៃសណីយ៍កម្ពុជាមាន ចំនួនសរុប ៤ ៣៦១ ២៥៨,០៨ ដុល្លារអាមេរិក ស្មើនឹង ១០៩,០៩% នៃផែនការប្រចាំឆ្នាំផងដែរ ក្នុងនេះមានការចំណាយទៅលើថ្លៃដើមលក់ចំនួន១៩៧៩៦៩៤,១០ដុល្លារ និងចំណាយប្រតិបត្តិការចំនួន ២ ៣៨១ ៥៦៣,៩៨ ដុល្លារ ។

តាមរបាយការណ៍របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានឱ្យដឹងទៀតថា ចំនួនទូរស័ព្ទចល័តនៅក្នុងប្រទេសកម្ពុជា កាលពីឆ្នាំ ២០១៣ មានចំនួន ២០ ២៦៤ ៥១៤ គ្រឿង កើនឡើង ៦% បើប្រៀបធៀបទៅនឹងឆ្នាំ ២០១២ ដែលមានចំនួនត្រឹមតែ១៩ ១០៥ ១១៥ គ្រឿងប៉ុណ្ណោះ ។ ការកើនឡើងនៃចំនួនអ្នកប្រើប្រាស់ទូរស័ព្ទដៃនេះ គឺដោយសារតែទូរស័ព្ទដៃមានមុខងារ និងអត្ថប្រយោជន៍ច្រើន និងមានតម្លៃថោកថែមទៀតផង ។

របាយការណ៍បានឱ្យដឹងទៀតថា ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទអចល័តវិញក្នុងឆ្នាំ ២០១៣ មានត្រឹមតែ ៤២០ ៩៤២ គ្រឿង ដោយចំនួននេះមានការថយចុះរហូតដល់ទៅ ២៨% បើប្រៀបធៀបទៅនឹងឆ្នាំ ២០១២ ដែលមានចំនួនដល់ទៅ ៥៨៤ ៤៧៥ គ្រឿងឯណោះ ។ ចំណែកចំនួនអ្នកប្រើប្រាស់អ៊ីនធើណែតវិញ សម្រាប់ឆ្នាំ ២០១៣ មានការកើនឡើងគួរឱ្យកត់សម្គាល់រហូតដល់ទៅ ៤២,៧% បើប្រៀបធៀបទៅនឹងឆ្នាំ ២០១២ ហើយឆ្នាំ២០១៣ មានចំនួន ៣ ៨៦១ ៨៤៣ នាក់ និងកាលពីឆ្នាំ ២០១២ មានចំនួនត្រឹមតែ ២ ៧០៦ ៩២២ នាក់ ប៉ុណ្ណោះ ។

ដើម្បីសម្រេចទិសដៅការងារឆ្នាំ ២០១៤ ឱ្យបានល្អ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានលើកទឹកចិត្ត និងជំរុញឱ្យមន្ត្រីទូរគមនាគមន៍កម្ពុជាខិតខំយកចិត្តទុកដាក់បម្រើដល់អតិថិជនដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសេចក្តីថ្លៃថ្នូរ ពិសេសមន្ត្រីដែលជាអ្នកផ្តល់សេវាដែលនៅជាប់នឹងអតិថិជន ថ្នាក់ដឹកនាំ និងនិយោជិត ទូរគមនាគមន៍កម្ពុជាត្រូវប្រកាន់ខ្ជាប់នូវជំហរជាអ្នកបម្រើអតិថិជន តាមរយៈការធានាឱ្យបាននូវគុណភាពនៃសេវាគ្រប់ប្រភេទ និងភាពរហ័សរហួនទប់ស្កាត់ឱ្យបានទាន់ពេលវេលានូវបាតុភាពអសកម្មទាំងឡាយដែលនាំឱ្យប៉ះពាល់ដល់អារម្មណ៍អតិថិជន និងកិត្តិយសរបស់អង្គភាព ។/



សិស្សសាលាត្រូវបានទទួលការបង្រៀនប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណែត

# ការរីកចម្រើននៅក្នុងវិស័យការងារ បានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ច



*ឯកឧត្តម **អ៊ិត សំហេង** ដឹកនាំកិច្ចប្រជុំការអនុវត្តការងារដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើង ការងាររៀបចំបញ្ជូនពលករចេញទៅធ្វើការនៅបរទេស ការផ្តល់លក្ខខណ្ឌការងារល្អប្រសើរ*

នៅក្នុងឆ្នាំ២០១៣ កន្លងទៅនេះ ការខិតខំប្រឹងប្រែងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៤ ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន**ជាប្រមុខបានជួយលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជាឱ្យកាន់តែប្រសើរឡើង ដោយបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។

តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថា នៅឆ្នាំ ២០១៣ កន្លងទៅនេះ ក្រសួងសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើន ។

សមិទ្ធផលដ៏សំខាន់នោះ គឺការអនុវត្តការងារដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងដេរស្បែកជើង ការងាររៀបចំបញ្ជូនពលករចេញទៅធ្វើការនៅបរទេស ការផ្តល់លក្ខខណ្ឌការងារ ល្អប្រសើរដោយធានាឱ្យមានសុខភាពសុវត្ថិភាពដល់កម្មករនិយោជិតនៅតាមរោងចក្រសហគ្រាស គ្រឹះស្ថាន និងការដោះស្រាយវិវាទការងារក្នុងរោងចក្រសហគ្រាស ។ ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងត្រូវបានដំឡើងពីចំនួន ៥០ ដុល្លារ ទៅ ៨០ ដុល្លារ ព្រមទាំងលើកទឹកចិត្តឱ្យនិយោជកផ្តល់ប្រាក់បំណាច់ផ្សេងៗមួយចំនួនទៀត ហើយក្នុងឆ្នាំ ២០១៤ ចាប់ពីខែកុម្ភៈមក ប្រាក់ឈ្នួលអប្បបរមាត្រូវបានបង្កើនដល់ចំនួន ១០០ ដុល្លារអាមេរិក ។

នៅក្នុងឆ្នាំ ២០១៣ នេះដែរ ក្រសួងបានបញ្ជូនពលករខ្មែរតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនទៅធ្វើការនៅបរទេសសរុបចំនួន ១៣ ៧៨០ នាក់ ថយចុះចំនួន ៤៨.៣៣% បើប្រៀបធៀបទៅនឹងឆ្នាំ ២០១២ មានចំនួន ២៦ ៦៧២ ដែលមានក្រុមហ៊ុនសរុបចំនួន ៣៦ ក្រុមហ៊ុន ។ តាមការប៉ាន់ស្មានបើពលករ ១ នាក់ៗផ្ញើប្រាក់តែ ៥០% នៃប្រាក់ឈ្នួលប្រចាំខែមកក្រុមគ្រួសារនោះ ប្រាក់ដែលបានផ្ញើចូលប្រទេសសរុបមានប្រមាណ ២០០ លានដុល្លារ ក្នុង ១ ឆ្នាំ។ ក្រៅពីនេះបានចុះធ្វើអធិការកិច្ចទូទាំងប្រទេសចំនួន ២ ៤៤៦ សហគ្រាសសម្រេចលើសផែនការ ១១,១៨% ក្នុងនោះបានដាក់កំហិតដល់សហគ្រាសគ្រឹះស្ថានដែលល្មើសច្បាប់ចំនួន ២៩៥ សហគ្រាសគ្រឹះស្ថាន ។ បានធ្វើការផ្សះផ្សាវិវាទការងារចំនួន ២១៨ ករណី ។ បានធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារ តាមរយៈការចុះធ្វើអធិការកិច្ចស្តីពីអនាម័យ និងសុវត្ថិភាពការងារនៅតាមបណ្តារោងចក្រសហគ្រាសចំនួន ១១ ២២២ គ្រឹះស្ថាន។

ចំពោះការអនុវត្តរបបសន្តិសុខសង្គមវិញ អនុវត្តតាមគោលនយោបាយជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់បេឡាជាតិ របបសន្តិសុខសង្គម ដើម្បីបាននូវប្រព័ន្ធសុវត្ថិភាពការងារ និងសុខុមាលភាពឱ្យកាន់ប្រសើរឡើងជូនដល់កម្មករ និយោជិត និងដោយឈរលើគោលការណ៍ធានាបាននូវប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ បេឡាជាតិរបបសន្តិសុខសង្គម បានពង្រីកវិសាលភាពចំនួន២៤រាជធានី-ខេត្តចុះកិច្ចសន្យាប្រើប្រាស់សេវាព្យាបាលជាមួយមន្ទីរពេទ្យ និងមន្ទីរព្យាបាលឯកជនចំនួន ៥០ នៅទូទាំងប្រទេស និងបានចុះបញ្ជីការសហគ្រាស គ្រឹះស្ថានសរុបចំនួន ៦ ១០៧ សហគ្រាស ដែលមានកម្មករ និយោជិតចំនួន ៤៨៧ ១៧៥ នាក់ និងបានទទួលការទាមទារគាវកាលិកហានិភ័យការងារ សរុបទាំងអស់ចំនួន ១៥ ០៥៩ នាក់ ក្នុងនោះ គាវកាលិកថែទាំ និងព្យាបាលមានចំនួន ៨ ២៤៥ នាក់ គាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នមានចំនួន ៦,៥៤០ នាក់ និងគាវកាលិកផ្សេងៗទៀតមានចំនួន ២៧៤ នាក់ ។ បើប្រៀបធៀបនឹងឆ្នាំ ២០១២ ការទាមទារគាវកាលិកមានតែចំនួន ១១ ៩០២ នាក់ ដូច្នេះចំនួននេះមានការ កើនឡើង ៣ ១៥៧ នាក់ ត្រូវជា ២៦,៥២% ។ ចំណាយគាវកាលិកជាក់ស្តែងសម្រាប់ឆ្នាំ ២០១៣ មានចំនួន ៦ ៩២២ ៧៧៨ ៨០០ រៀល ។ បើប្រៀបធៀបទៅនឹងការចំណាយគាវកាលិកសម្រាប់ឆ្នាំ ២០១២ មានចំនួន ៥ ០៥៧ ៧៩៥ ៥០០ រៀល ដូចនេះការចំណាយគាវកាលិកនៅឆ្នាំ ២០១៣ កើនឡើងចំនួន ១ ៨៦៤ ៩៨៣ ៣០០ រៀល ត្រូវជា ៣៦,៨៧% ។

ក្រៅពីនេះ គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារហៅកាត់ថាស.ទ.ប.ក បានបំពេញតួនាទីយ៉ាងសកម្មក្នុងការសិក្សាស្រាវជ្រាវរកមូលហេតុករណីសន្លប់របស់កម្មករ និយោជិត ចាត់វិធានការសង្គ្រោះបន្ទាន់ និងសម្របសម្រួលជាមួយមន្ទីរពេទ្យ ជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីឱ្យជនរងគ្រោះទទួលបានការសង្គ្រោះបន្ទាន់ និងរៀបចំការផ្សព្វផ្សាយពីកម្មវិធីបង្ការគ្រោះថ្នាក់ការងារ ។ ជាការគួរឱ្យកត់សម្គាល់សម្រាប់ឆ្នាំ ២០១៣ កន្លងទៅ គណៈកម្មការ ស.ទ.ប.ក បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំបានចំនួន ៣២ លើក មានរោងចក្រចំនួន ៧១ មានកម្មករនិយោជិត ប្រមាណជា ១ ម៉ឺននាក់។

នៅក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងបានជំរុញការអភិវឌ្ឍសមត្ថភាពជំនាញ បច្ចេកទេស និងវិជ្ជាជីវៈជូនប្រជាពលរដ្ឋជាបន្តបន្ទាប់ ជាក់ស្តែងក្នុងឆ្នាំ ២០១៣ នៃការអនុវត្តផែនការសកម្មភាព អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ឆ្នាំ ២០០៩-២០១៣ ក្រសួងបានផ្តល់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមរយៈគ្រឹះស្ថានអប់រំ



*កម្មករ កម្មការិនីកំពុងផលិតសម្លៀកបំពាក់ ក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់នៅរាជធានីភ្នំពេញ*

បណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្រោមឱវាទនិងចុះអនុស្សរណៈជាមួយក្រសួងចំនួន ៨៧ ក្នុងនោះមានគ្រឹះស្ថានសាធារណៈចំនួន ៣៨ ឯកជនចំនួន ៣៣ និងគ្រឹះស្ថានអង្គការ មិនមែនរដ្ឋាភិបាលចំនួន ១៦ ដោយបានបណ្ដុះបណ្ដាលតាមកម្រិតថ្នាក់ឧត្ដម និងក្រោយឧត្ដម ថ្នាក់ជាន់ខ្ពស់បច្ចេកទេស បរិញ្ញាបត្ររង កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈរយៈពេលវែង និងរយៈខ្លី សរុបទាំងអស់ចំនួន ៧៥ ៧២៧ នាក់ ក្នុងនោះស្រីចំនួន ៣៤ ៥២៦ នាក់ ស្មើនឹង ៤១,២១% ។

ជាមួយគ្នានេះ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍវិស័យកាងារ និងការពង្រីកគុណភាពប្រព័ន្ធអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យកាន់តែប្រសើរឆ្លើយតបតាមតម្រូវការទីផ្សារការងារ ព្រមទាំងផ្ដល់ឱកាសឱ្យប្រជាពលរដ្ឋកម្ពុជាអាចធ្វើការសិក្សាពេញមួយជីវិត គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល(National Training Board–NTB) បានរៀបចំនូវក្របខ័ណ្ឌគុណវុឌ្ឍិជាតិឯកភាពមួយ និងស្ដង់ដារសមត្ថភាពតាមវិស័យ ដើម្បីធ្វើសុខុដុមនីយកម្មប្រព័ន្ធវិញ្ញាបនបត្រកម្ម បង្កើនការទុកចិត្តលើការអប់រំបណ្ដុះបណ្ដាលរៀបចំឱ្យមានជណ្ដើរអាជីព ព្រមទាំងការបង្កលក្ខណៈងាយស្រួលក្នុងការទទួលស្គាល់ទៅវិញទៅមកនូវជំនាញនិងចល័តកម្មនៃកម្លាំងពលកម្មក្នុងតំបន់ ។ទន្ទឹមនឹងនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារហៅកាត់ថា ទ.ជ.ម.ក នៃគណៈ-កម្មាធិការជាតិបណ្ដុះបណ្ដាលក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកធានានូវភាពចល័ត ភាពងាយបត់បែន និងដំណើរការល្អប្រសើររបស់ទីផ្សារការងារ ។ ក្នុងចន្លោះឆ្នាំ ២០១០-២០១៣ ទីភ្នាក់ងារជាតិនេះបានប្រមូលព័ត៌មាន និងជ្រើសរើសកម្លាំងពលកម្មកើនឡើងជាលំដាប់ពីចំនួន ១០ ៦៤៨ ក្នុងឆ្នាំ ២០១០ ទៅចំនួន ៣០ ៨៥៤ ក្នុងឆ្នាំ ២០១១ នៅឆ្នាំ ២០១២ មានចំនួន ៥៣ ៦៤០ ។

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលនាពេលកន្លងមកនេះ ក្នុងវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជានៅក្នុងវិស័យការងារ បរិយាកាស និងបរិស្ថាននៅកន្លែងធ្វើ-ការ និងជិតកន្លែងធ្វើការនៅមិនទាន់បានរៀបចំឱ្យបានល្អប្រសើរនៅឡើយ ដែលកន្លងមកគ្រោះថ្នាក់ការងារ ក៏ដូចជាការចុះខ្សោយនៃសុខភាព និងការដួលសន្លប់របស់កម្មករ និយោជិត នៅវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងនៅតែមានការកើតឡើង កង្វះខាតបទប្បញ្ញត្តិគ្រប់គ្រងក្រុមហ៊ុនឬវិស័យឯកជនដែលផ្ដល់សេវារកការងារឱ្យពលករធ្វើការក្នុងស្រុក កង្វះខាតបទប្បញ្ញត្តិមួយចំនួនសម្រាប់គ្រប់គ្រងផ្នែកនីមួយៗនៃវិស័យការងារដូចជាច្បាប់ស្ដីពីសហជីព និងច្បាប់ស្ដីពីតុលាការការងារជាដើម ។រីឯក្នុងវិស័យសន្តិ-សុខសង្គមវិញក៏ជួបប្រឈមបញ្ហាលំបាកមួយចំនួនដែរ ដូចជាកង្វះខាតការយល់ដឹងច្បាស់លាស់ពីសំណាក់និយោជកស្ដីពីច្បាប់នីតិវិធី និងបែបបទនៃការអនុវត្តគោលនយោបាយ របបធានារ៉ាប់រង ហានិភ័យការងារ និងកង្វះខាតនៃការបំពេញកាតព្វកិច្ចរបស់និយោជកមួយចំនួនចំពោះកម្មករនិយោជិតជាដើម ។

លទ្ធផលជាផ្លែផ្កាខាងលើនេះបានបញ្ជាក់ឱ្យឃើញថា វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានរួមចំណែកអនុវត្តផែនការអភិវឌ្ឍន៍សហស្សវត្សកម្ពុជា គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងអនុវត្តគោលនយោ-បាយកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈ គោលនយោបាយកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទម្រង់ផ្សេងៗទៀត និងផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ទទួលបានជោគជ័យតាមការព្យាករណ៍ ហើយបានកំណត់នូវសូចនាករថ្មីៗបន្ថែមទៀត ក្នុងការបន្តចូលរួមអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៥ នេះឱ្យទទួលបានលទ្ធផលកាន់តែល្អប្រសើរឡើងថែមទៀត ។

នៅក្នុងឆ្នាំ ២០១៤ នេះ ដើម្បីចូលរួមអនុវត្តកម្មវិធីនយោបាយរបស់រាជ-រដ្ឋាភិបាលសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា មុំទាំងឡាយនៃយុទ្ធសាស្ត្រចតុ-កោណដំណាក់កាលទី ៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ដែលពាក់ព័ន្ធនឹងវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការចាប់ផ្ដើមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០១៤-២០១៨ នោះ ក្រសួងបានកំណត់នូវកម្មវិធីការងារសម្រាប់អនុ-វត្តតាមទិសដៅជាយុទ្ធសាស្ត្រដែលរួមមាន : បន្តការលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករនិយោជិត និងនិយោជក បន្តដំឡើងប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិត ពង្រឹងការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារ ពង្រឹង និងពង្រីកសេវាអប់រំបណ្ដុះបណ្ដាលបច្ចេក-ទេស និងវិជ្ជាជីវៈប្រកបដោយសមធម៌ និងបន្តរៀបចំគោលនយោបាយជាតិស្ដីពីមុខរបរ និងកាងារ ។/



*ការបណ្ដុះបណ្ដាលជំនាញកាត់ដេរដល់ស្ត្រីក្រីក្រ នៅរាជធានីភ្នំពេញ*

# ខិតខំពង្រីកវិសាលភាព ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយ

*ឆ្នាំ ២០១៣ កន្លងទៅនេះ វិស័យព័ត៌មាន និងសោតទស្សន៍នៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយអនុវត្តបានជោគជ័យនូវការពង្រីកវិសាលភាព គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ គ្របដណ្ដប់បានទូលំទូលាយទាំងនៅក្នុងប្រទេស ក្នុងតំបន់និងទ្វីបនានា ។ គោលនយោបាយអាទិភាព ៣ ចំណុច ដែលវិស័យព័ត៌មាន និងសោតទស្សន៍ទទួលបានជោគជ័យនោះគឺ ១-ពង្រីកវិសាលភាព និងប្រសិទ្ធភាពនៃសេវាផ្សព្វផ្សាយផ្ដល់ព័ត៌មាន ការអប់រំ និងការកម្សាន្តប្រកបដោយគុណភាព និងសមធម៌ជូនប្រជាជននៅ ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៨៥% ដល់ ៩៥% ២-លើកទឹកចិត្តការអនុវត្តសេរីភាពសារព័ត៌មាន និងការបញ្ចេញមតិស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស លើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស ៣-រួមចំណែកអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ប្រពៃណី ដើម្បីលើកកម្ពស់អត្តសញ្ញាណជាតិ និងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ។*





*ឯកឧត្តម **ខៀវ កាញារីទ្ធ** ថ្លែងនៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារវិស័យព័ត៌មាន និងសោតទស្សន៍ឆ្នាំ ២០១៣ និងទិសដៅការងារឆ្នាំ ២០១៤*

វិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិទាំងមូល ទាំងរដ្ឋ និងឯកជន ត្រូវបានពង្រីក និងលើកកម្ពស់។ ប្រជាពលរដ្ឋដែលមានមធ្យោបាយសមស្របអាចទទួលបានពេញលេញនូវសេវាផ្ដល់ព័ត៌មាន ការអប់រំ និងការកម្សាន្ត តាមរយៈប្រព័ន្ធផ្សព្វផ្សាយសម្បូរបែប និងទំនើបប្រកបដោយសមធម៌ និងគុណភាពតាមចំណង់ចំណូលចិត្តរបស់គ្រប់មជ្ឈដ្ឋាន។ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសម្បូរបែបនេះ កិត្យានុភាព អត្តសញ្ញាណ និងអារ្យធម៌ជាតិខ្មែរត្រូវបានលើកកម្ពស់នៅលើពិភពលោក ។ក្នុងចំណោមគ្រួសារប្រជាជនទូទាំងប្រទេស ២,៨ លានគ្រួសារ មាន ៦៤% នៃចំនួនគ្រួសារសរុបមានទូរទស្សន៍មើល និង ៤១% នៃចំនួនគ្រួសារសរុបមានវិទ្យុស្ដាប់ ។ ក្រៅពីនេះមានប្រជាជនប្រមាណ២០% បានទទួលព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណេត និងបណ្ដាញសង្គមហ្វេសប៊ុកដ៏ពេញនិយមតែខ្វះក្រមសីលធម៌ ។

ការងារគ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍ ក៏ត្រូវបានពង្រឹងតាមរយៈការអនុវត្តច្បាប់ស្ដីពីរបបសារព័ត៌មាន និងលិខិតបទដ្ឋានគតិយុត្ត ។បច្ចុប្បន្ននេះនៅរាជធានីភ្នំពេញមានស្ថានីយទូរទស្សន៍ចំនួន ១៦ ក្នុងនោះ មាន ១៤ ស្ថានីយផ្សាយផ្ទាល់ និង ២ ស្ថានីយផ្សាយបន្តពីបរទេស (វៀតណាម VTV និងបារាំង (TV5) ។ នៅតាមខេត្តមានចំនួន ៧0 ស្ថានីយផ្សាយបន្ត (Relay Station) ពីរាជធានីភ្នំពេញ ។ ស្ថានីយទូរទស្សន៍ខ្សែកាប និងប្រព័ន្ធផ្សេងៗកំពុងដំណើរការនៅរាជធានីភ្នំពេញមាន ៤ ក្រុមហ៊ុន។ ស្ថានីយវិទ្យុផ្សាយសំឡេងនៅរាជធានីភ្នំពេញមានចំនួន ៦៩ ស្ថានីយ ក្នុងនោះមាន ៦៦ ស្ថានីយ ផ្សាយផ្ទាល់ និង ៣ ស្ថានីយផ្សាយបន្តពីបរទេស (BBC, RFI, ABC) ។ នៅតាមខេត្តមានចំនួន ១១៩ ស្ថានីយ ក្នុងនោះមាន ៦៦ ស្ថានីយផ្សាយផ្ទាល់ និង ៥៣ ស្ថានីយ ផ្សាយបន្តពីភ្នំពេញ។ នៅកម្ពុជាមានកាសែតចំនួន ១៣៩ អង្គភាព ទស្សនាវដ្ដីចំនួន ៥៦ អង្គភាព ព្រឹត្តប័ត្រចំនួន ៩ អង្គភាព គេហទំព័រចំនួន ១៥ អង្គភាព រោងពុម្ពចំនួន ១១០ អង្គភាព គ្រឹះស្ថានបោះពុម្ពផ្សាយចំនួន ៦ អង្គភាព។ ប្រព័ន្ធព័ត៌មានទាំងនេះបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវព្រឹត្តិការណ៍ទាំងឡាយដែលទាក់ទិនដល់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ទាំងវិស័យនយោបាយ យោធា សន្តិសុខ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ផ្សព្វផ្សាយអំពីព្រះរាជសកម្មភាពព្រះមហាក្សត្រ និងសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ស្ថាប័នជាតិ និងក្រសួងមន្ទីររាជធានី ខេត្ត ជាពិសេសព្រឹត្តការណ៍ទាក់ទងដល់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ នៃរដ្ឋ

សភា ចាប់តាំងពីយុទ្ធនាការឃោសនាបោះឆ្នោត ការប្រកាសលទ្ធផល ការបង្កើតរដ្ឋសភានីតិកាលទី ៥ និងការបង្កើតរាជរដ្ឋាភិបាលថ្មីក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ជាមួយនឹងការប្រកាសដាក់ឱ្យអនុវត្តនូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ។

ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មានបានថ្លែងនៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារវិស័យព័ត៌មាន និងសោតទស្សន៍ឆ្នាំ ២០១៣ និងទិសដៅការងារឆ្នាំ ២០១៤ ថា ក្រសួងព័ត៌មាននៅតែវាយតម្លៃខ្ពស់ចំពោះប្រព័ន្ធផ្សព្វផ្សាយរបស់ក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលបាននិងកំពុងពង្រឹងនិងពង្រីកគុណភាព ប្រសិទ្ធភាព និងវិសាលភាពនៃការផ្សព្វផ្សាយរបស់ខ្លួនយ៉ាងផុសផុល និងមានលក្ខណៈប្រកួតប្រជែងលើទីផ្សារក្នុងការផ្តល់សេវាផ្តល់ព័ត៌មាន ការអប់រំ និងការកម្សាន្តជូនប្រជាជនគ្រប់ទិសទី។ ឯកឧត្តម **ខៀវ កាញារីទ្ធ** ក៏បានធ្វើការកត់សម្គាល់ថា មធ្យោបាយជូនព័ត៌មានថ្មីមួយទៀតគឺបណ្តាញទំនាក់ទំនងសង្គម (Facebook, Twitter, Google, What's App ... ដែលងាយនឹងបង្កើតដោយមិនបាច់សុំច្បាប់អ្នកណា ងាយនឹងបញ្ជូនព័ត៌មាន និងរូបភាពគ្រប់ប្រភេទដោយមិនគិតទៅដល់ក្រមសីលធម៌ និងវិជ្ជាជីវៈសារព័ត៌មាន ហើយដែលនៅលើពិភពលោកទាំងមូលអាចទទួលបាននោះត្រូវបានមនុស្សជាច្រើន



អង់តែននៃស្ថានីយវិទ្យុ និងទូរទស្សន៍មួយនៅរាជធានីភ្នំពេញ



ក្រុមអ្នកយកព័ត៌មានវិទ្យុ និងទូរទស្សន៍ជាតិ និងអន្តរជាតិ

និយមប្រើប្រាស់យ៉ាងគំហុកក្នុងឆ្នាំ ២០១៣ កន្លងមកនេះ ។ ការលេចឡើងនូវបណ្តាញទំនាក់ទំនងសង្គមគឺជាវិញ្ញាសាមួយដ៏ស្មុគស្មាញសម្រាប់ក្រសួងព័ត៌មាន ព្រោះថាវាក៏មានជ្រុងវិជ្ជមាន និងអវិជ្ជមានដើរទន្ទឹមគ្នា ។ ជ្រុងវិជ្ជមានគឺរហ័សងាយស្រួលនៅទីណា ពេលណាក៏បាន ហើយពិភពលោកទាំងមូលអាចទទួលបានគ្រប់ទិន្នន័យដែលផ្សាយចេញពីបណ្តាញទាំងនេះ ។ ជ្រុងអវិជ្ជមាន គឺអ្នកប្រើប្រាស់ដោយគ្មានសីលធម៌យកបណ្តាញទាំងនេះធ្វើជាវេទិកាជេរប្រមាថ មួលបង្កាច់បំភ្លៃ បំផ្លើស ញុះញង់ អុជអាល បញ្ឆេះកំហឹង ប្រើពាក្យសម្តីអសុរោះ ប្រើរូបភាពកាត់ត ប្រើរូបភាពអាសអាភាស គ្មានសីលធម៌ ដែលផ្ទុយទាំងស្រុងទៅនឹងក្រមសីលធម៌ ផ្ទុយនឹងច្បាប់ស្តីពីរបបសារព័ត៌មាន ផ្ទុយពីប្រពៃណីទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ប្រជាជនកម្ពុជា។ ឯកឧត្តម **ខៀវ កាញារីទ្ធ** បានបញ្ជាក់ទៀតថា អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមមួយចំនួនបានឈានទៅដល់ការប្រមាថមើលងាយព្រះមហាក្សត្រដែលជាទីសក្ការៈ ហើយដែលតាមស្មារតីនៃរដ្ឋធម្មនុញ្ញគ្មានអ្នកណាម្នាក់អាចប៉ះពាល់បានទៀតផង ។ នេះជាវិញ្ញាសាមួយដែលយើងទាំងអស់គ្នាត្រូវពិនិត្យពិចារណា។ប៉ុន្តែក្រសួងព័ត៌មានសូមប្រកាសសាជាថ្មីថា ក្រសួងមិនមានបំណងបិទ បណ្តាញទំនាក់ទំនងសង្គមនេះឡើយ ។

យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងារវិស័យព័ត៌មាន និងសោតទស្សន៍ឆ្នាំ ២០១៣ របស់ក្រសួងព័ត៌មានក៏បានបញ្ជាក់ឱ្យដឹងថា នៅមានបញ្ហាប្រឈម ការលំបាក និងចំណុចខ្សោយមួយចំនួនដែលត្រូវដោះស្រាយ នោះគឺ សមត្ថភាពដឹកនាំ និងសមត្ថភាពជំនាញរបស់មន្ត្រីនៅផ្នែកខ្លះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមានកម្រិត។ បណ្តាអង្គភាពផ្សព្វផ្សាយរបស់រដ្ឋ (វិទ្យុ ទូរទស្សន៍ និងទីភ្នាក់ងារសារព័ត៌មាន ជាតិ) ពុំមានលទ្ធភាពថវិកាគ្រប់គ្រាន់សម្រាប់ម្ចាស់ការផលិតកម្មវិធីអប់រំឱ្យបានទូលំទូលាយលើគ្រប់វិស័យបានឡើយ ពិសេសការអប់រំសង្គម។ ការផ្សព្វផ្សាយកម្មវិធីអប់រំភាគច្រើន





*កាសែត ព្រឹត្តិបត្រ និងទស្សនាវដ្ដី ទាំងភាសាជាតិ និងបរទេស*
*មានដាក់លក់តាមតូបនានាក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តទូទាំងប្រទេស*

កន្លងមកគឺពឹងផ្អែកច្រើនលើកិច្ចសហការជាមួយដៃគូជាអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ។ មូលដ្ឋានសម្ភារៈបច្ចេកទេសសម្រាប់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិឈានដល់ដំណាក់កាលត្រូវផ្លាស់ប្ដូរពីប្រព័ន្ធអាណាឡូក ទៅប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីឆ្លើយតបនឹងគម្រោងផ្លាស់ប្ដូររបស់អាស៊ាន និងពិភពលោក និងការបន្តអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងរដ្ឋបាលអេឡិចត្រូនិច (e-Government) ។

ក្រសួងព័ត៌មានបានផ្ដោតគោលដៅសំខាន់ទៅលើទិសដៅផែនការសកម្មភាពសម្រាប់អនុវត្តនៅឆ្នាំ ២០១៤ ដោយខិតខំបន្តជំរុញប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ និងលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយឯកជនឱ្យខិតខំពង្រីកសក្ដានុពលភាព ប្រសិទ្ធភាព និងវិសាលភាពនៃការផ្សាយ រួមចំណែកលើកតម្កើងអត្តសញ្ញាណ មោទនភាពជាតិខ្មែរ និងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាលើឆាកអន្តរជាតិ ។ កសាង និងធ្វើទំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស ដើម្បីប្រសិទ្ធភាពការងារសម្រាប់អង្គភាពផ្សព្វផ្សាយថ្នាក់ជាតិ ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់នៃការផ្សព្វផ្សាយ ។ បង្ហាញពីជំហរ និងសំឡេងផ្លូវការរបស់ជាតិមួយដែលមានអធិបតេយ្យពេញលេញ អាចម្ចាស់ការប្រតិកម្មតបទាន់ពេលវេលាចំពោះរាល់ការផ្សាយ និងព័ត៌មានទាំងឡាយដែលប្រាសចាកការពិត ប៉ះពាល់ដល់កិត្តិយស និងអន្តរាយដល់សន្តិសុខជាតិ ។ ជំរុញការអនុវត្តច្បាប់ស្ដីពីរបបសារព័ត៌មាន និងខិតខំសិក្សាស្រាវជ្រាវ ដើម្បីកសាង លិខិតបទដ្ឋានគតិយុត្តថ្មីសម្រាប់គ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍ឱ្យស្ថិតក្នុងក្របខណ្ឌនីតិរដ្ឋ ដោយធានាបានទាំងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាន និងលទ្ធិប្រជាធិបតេយ្យ ។ លើកកម្ពស់គុណភាពនៃកម្មវិធីផ្សាយព័ត៌មានគ្របដណ្ដប់ដោយព័ត៌មានជាតិ ដែលឆ្លុះបញ្ចាំងពីគ្រប់ទិដ្ឋភាពនៃជីវភាពសង្គមកម្ពុជា ជាព័ត៌មានពិតត្រឹមត្រូវតាមទិសស្លោក ប្លែក លឿន ទុកចិត្តបាន នៅទីណា ពេលណាក៏បាន ដោយឈរលើស្មារតីទទួលខុសត្រូវ និងគោរពសីលធម៌វិជ្ជាជីវៈ ដើម្បីធានានូវការលើកស្ទួយនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស និងលើកកម្ពស់ជំនឿទុកចិត្តរបស់ប្រជាជន ។



ព័ត៌មានតាមប្រព័ន្ធអ៊ីនធ័រណេតកំពុងពេញនិយមនៅកម្ពុជា

ឯកឧត្ដម **ខៀវ កាញារីទ្ធ** ក្នុងនាមជារដ្ឋមន្ត្រីក្រសួងព័ត៌មានបានអំពាវនាវឱ្យអ្នកសារព័ត៌មានទាំងអស់យកចិត្តទុកដាក់លើការកែទម្រង់លើការសរសេរព័ត៌មានរបស់ខ្លួនពីការសរសេរជារបៀបពិធីការតាមលក្ខណៈស្ដង់ដារដែលនោះឱ្យទៅជាការសរសេរមានលក្ខណៈស៊ីជម្រៅ រស់រវើក បកស្រាយបំភ្លឺឱ្យទាន់ពេលវេលា ទាន់ហេតុការណ៍ ដើម្បីឱ្យប្រជាជនយើងមានការកក់ក្ដៅ មានការទុកចិត្តលើការដឹកនាំរបស់រាជរដ្ឋាភិបាល ។ ក្នុងនោះ ក៏ត្រូវសកម្មចូលរួមផ្សព្វផ្សាយការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ នៅក្នុងនីតិកាលទី ៥ នៃរដ្ឋសភាដើម្បីបន្តអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើនខ្លាំងក្លាឡើង ធានាដល់ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន លើកស្ទួយវិស័យសង្គមកិច្ច ពង្រឹងយុត្តិធម៌សមធម៌សង្គម ព្រមទាំងផ្ដល់សេវាសាធារណៈឱ្យបានល្អប្រសើរ ។/



# អង្គរសង្ក្រាន្តលើកទី ២ បានរួមចំណែកលើកស្ទួយវប្បធម៌ជាតិ

ព្រឹត្តិការណ៍( អង្គរសង្ក្រាន្ត) ដែលត្រូវបានរៀបចំដោយសហភាពសហព័ន្ធយុវជនកម្ពុជា ( ស.ស.យ.ក ) សហការជាមួយអាជ្ញាធរខេត្តសៀមរាប ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងស្ថាប័នផ្សេងៗទៀត បានប្រព្រឹត្តទៅដោយជោគជ័យ បន្ទាប់ពីដំណើរការអស់រយៈពេល ៤ថ្ងៃ ពីថ្ងៃ ១៣ ដល់ ១៦ ខែមេសា ឆ្នាំ ២០១៤ ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំមមីឆស័ក ព.ស ២៥៥៨ ។ ក្រុមយុវជនស្ម័គ្រចិត្តពីក្រុងភ្នំពេញ និងពីបណ្ដាខេត្ត ព្រមទាំងសិល្បករ សិល្បការិនី ដែលបានចូលរួមរៀបចំនិងសម្ដែងក្នុងកម្មវិធីសិល្បៈលេងល្បែងប្រជាប្រិយ និងបង្ហាញវប្បធម៌ខ្មែរនៅក្នុងឱកាសនោះមានចំនួនជាងបីពាន់នាក់ ។ ពិធីនេះបានប្រព្រឹត្តទៅក្នុងបរិយាកាសដ៏សប្បាយរីករាយក្រៃលែង ដោយមានការចូលរួមពីមហាជននិងភ្ញៀវទេសចរក្នុងស្រុក និងបរទេសជិត ៣០ ម៉ឺននាក់ ។

នៅក្នុងពិធីបើកដំណើរការ( អង្គរ-សង្ក្រាន្ត) នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០១៤ នៅបរិវេណប្រាសាទបាយ័ន ឯកឧត្តមឧបនា-យករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីបានសម្ដែងការស្វាគមន៍យ៉ាងកក់ក្ដៅចំពោះភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានមកទស្សនារមណីយដ្ឋានអង្គរ ដែលជារមណីយដ្ឋានវប្បធម៌ប្រវត្តិ-សាស្ត្ររបស់កម្ពុជា និងជាបេតិកភណ្ឌពិភព-លោក ជាពិសេសទី-ក្រុងសៀមរាបអង្គរដែលត្រូវបានគេទទួលស្គាល់ថាជាទីក្រុងវប្បធម៌ ប្រវត្តិសាស្ត្រដ៏មានវ័យចំណាស់នោះ ។ក្នុងនាមរាជរដ្ឋាភិបាល ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនៃសហភាពសហព័ន្ធយុវជនកម្ពុជា ដែលបានផ្ដួចផ្ដើមគំនិត និងចលនាឱ្យមានដំណើរការព្រឹត្តិការណ៍ ( អង្គរសង្ក្រាន្ត)ដ៏មានសារៈសំខាន់នេះឡើង ។



*ឯកឧត្តម **សុខ អាន** និងលោកជំទាវកាត់ខ្សែបូបើកអង្គរសង្ក្រាន្ត នៅប្រាសាទបាយ័ន ខេត្តសៀមរាប*

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានថ្លែង ថា អង្គរសង្ក្រាន្តមិនត្រឹមតែឆ្លុះបញ្ចាំងឱ្យឃើញនូវគំនិតច្នៃប្រឌិតដ៏ឈ្លាសវៃនិងសមិទ្ធផលគួរឱ្យមានមោទនភាពរបស់ ស.ស.យ.ក ប៉ុណ្ណោះទេ តែថែមទាំងជាសក្ខីភាពបញ្ជាក់ពីស្មារតីរួបរួមសាមគ្គីគ្នា ដើម្បីរួមចំណែកលើកកម្ពស់វប្បធម៌ អរិយធម៌ និងថែរក្សាកេរដំណែលទំនៀមទម្លាប់ និងប្រពៃណីជាតិផងដែរ ។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ( អង្គរសង្ក្រាន្ត) ដែលទើបតែមានជាលើកទីពីរនៅតំបន់រម-ណីយដ្ឋានប្រវត្តិ-សាស្ត្រដ៏រុងរឿងនៃសៀមរាបអង្គរជាឱកាសដ៏ប្រពៃសម្រាប់បើកទំព័រសករាជថ្មីឱ្យយុវជនបានចូលរួមកាន់តែខ្លាំងក្លាថែមទៀតនៅក្នុងកិច្ចការនយោបាយ សេដ្ឋកិច្ច វប្បធម៌និងសង្គមដែលជាបេសកកម្មដ៏ឧត្ដុង្គឧត្ដមនិងជាការបន្តវេនរបស់យុវជនពីជំនាន់មួយទៅជំនាន់មួយទៀតដើម្បីបុព្វហេតុជាតិ មាតុភូមិជាទីស្នេហានៃយើង ។



*ឯកឧត្តម **សុខ អាន** និងលោកជំទាវ និងឯកឧត្តម **ហ៊ុន ម៉ានី** ប្រគេនទេយ្យវត្ថុដល់ព្រះសង្ឃ*

នៅក្នុងឱកាស នោះ ឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ និងជាអ្នកផ្ដួចផ្ដើមគំនិតរៀបចំពិធីជាប្រវត្តិសាស្ត្រនេះបានមានប្រសាសន៍ថា គោលបំណងនៃការរៀបចំឱ្យមានព្រឹត្តិការណ៍( អង្គរសង្ក្រាន្ត) នេះឡើង គឺដើម្បីចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងផ្ដល់ឱកាសឱ្យយុវជនក៏ដូចជាប្រជាពលរដ្ឋខ្មែរទូទៅ និងភ្ញៀវទេសចរជាតិ អន្តរជាតិ បានចូលរួមកម្សាន្តសប្បាយតាមលក្ខណៈប្រពៃណីជាតិ និងជាការបំផុសទឹកចិត្តយុវជនកម្ពុជាយើងឱ្យចាប់អារម្មណ៍ស្វែងយល់កាន់តែច្បាស់ និងចូលរួមចំណែកលើកស្ទួយវប្បធម៌ អរិយធម៌ដ៏ពិសិដ្ឋនិងល្អផូរផង់របស់ជាតិ ជាពិសេសអំពីសិល្បៈ របាំប្រជា






*ការសម្ដែងរបាំនៅមុខប្រាសាទបាយ័ន ខេត្តសៀមរាប*

ប្រិយ ល្បែងប្រជាប្រិយខ្មែរ ទំនៀមទម្លាប់ប្រពៃណី និងសាសនា ដែលកម្ពុជាធ្លាប់ប្រតិបត្តិជាយូរយារណាស់មកហើយ ។

នៅថ្ងៃបញ្ចប់ព្រឹត្តិការណ៏ ( អង្គរសង្ក្រាន្ត) ឯកឧត្ដម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៏ បានសម្ដែងការកោតសរសើរ និងថ្លែងអំណរគុណចំពោះ ស.ស.យ.ក អាជ្ញាធរខេត្ត អាជ្ញាធរអប្សរា ក្រសួង មន្ទីរ អង្គភាព ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ ក្រុមសិល្បករ តារាសម្ដែងនិងអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងភ្ញៀវទេសចរ និងមហាជន ដែលបានចូលរួមចំណែក និងសាមគ្គីពួតដៃគ្នា ខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការរៀបចំ និងចូលរួមព្រឹត្តិការណ៏ ( អង្គរសង្ក្រាន្ត) ឆ្នាំ ២០១៤ នេះ ដែលជាព្រឹត្តិការណ៏ទេសចរណ៏វប្បធម៌ដ៏ធំមួយរបស់កម្ពុជា ។ ឯកឧត្ដម **ថោង ខុន** ក៏បានមានប្រសាសន៏ឱ្យដឹងថាក្នុងព្រឹត្តិការណ៏អង្គរសង្ក្រាន្តរយៈពេល ៣ ថ្ងៃនៃពិធីបុណ្យចូលឆ្នាំថ្មីនេះមានភ្ញៀវទេសចរជាតិមិនតិចជាង ២៥ ម៉ឺននាក់ និងទេសចរបរទេសប្រមាណ ២ ម៉ឺននាក់ បានមកទស្សនាខេត្តសៀមរាប និងបានចូលរួមកម្សាន្តសប្បាយក្នុងព្រឹត្តិការណ៏អង្គរសង្ក្រាន្ត ហើយភ្ញៀវទេសចរទាំងនោះបាននាំចំណូលប្រមាណ ៣០ លានដុល្លារចូលក្នុងចរន្តសេដ្ឋកិច្ចខេត្តសៀមរាប ។ ឯកឧត្ដមរដ្ឋមន្ត្រីបន្ថែមថា ព្រឹត្តិការណ៏នេះបានធ្វើឱ្យពិភពលោកស្គាល់កម្ពុជាកាន់តែច្បាស់ និងចង់មកទស្សនាកម្ពុជាកាន់តែច្រើនឡើងថែមទៀត ។ ជាមួយគ្នានេះ ឯកឧត្ដមបានអះអាងថានឹងបន្តរៀបចំព្រឹត្តិការណ៏ធំៗជាបន្តទៀតដើម្បីទាក់ទាញភ្ញៀវទេសចរ ដូចជាអង្គរសង្ក្រាន្តនៅខេត្តសៀមរាប នៅភូមិភាគព្សសានមានបុណ្យទន្លេ និងនៅតំបន់ឆ្នេរមានបុណ្យសមុទ្រ ។

សូមបញ្ជាក់ថាការរៀបចំ( អង្គរសង្ក្រាន្ត) ត្រូវបានប្រារព្ធធ្វើនៅតំបន់ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ទីលានជល់ដំរី និងនៅទីតាំងមួយចំនួនក្នុងក្រុងសៀមរាប ដូចជានៅតំបន់អង្គរ-ឃ្យុងយូ តំបន់តាមដងស្ទឹងសៀមរាប និងតំបន់ទេសចរណ៏ផប់ស្រ្ទីត ក្រុងសៀមរាបជាដើម ។ក្នុងព្រឹត្តិការណ៏( អង្គរសង្ក្រាន្ត) មានកម្មវិធីភូមិខ្ញុំល្បែងប្រជាប្រិយ ក្បាច់គុនល្បុក្កតោ ល្បែងចត្រង្គ ឬល្បែងអុក របាំប្រពៃណី បច្ចេកទេសសិលាឋាន ពិព័រណ៏ពាណិជ្ជកម្ម ពិព័រណ៏សិប្បកម្ម និងម្ហូបអាហារខ្មែរ គោមបណ្ដែតទឹក និងផលិតផល ស.ស.យ.ក ។

សម្រាប់កម្មវិធីខាងសាសនាមានពិធីបួងសួង ពិធីទទួលទេវតាឆ្នាំថ្មី ពិធីស្រង់ព្រះ ពិធីទៅវត្តពូនភ្នំខ្សាច់ ។ ចំពោះផ្ទាំងទស្សនីយភាព គឺមានពិធីបើកព្រឹត្តិការណ៏អង្គរសង្ក្រាន្តមហោស្រពសិល្បៈបុរាណ ព្រះសុធន និងនាងកែវមនោហ៏រា ពិធីដង្ហែក្បួនអង្គរសង្ក្រាន្ត ពិធីដង្ហែនំអន្សមយក្ស ដែលមានទម្ងន់រហូតដល់ ២ តោន និងការប្រគំតន្ត្រីអង្គរសង្ក្រាន្តផងដែរ ។/





*នំអន្សមយក្ស និងការប្រកួតល្បែងចត្រង្គនៅមុខប្រាសាទបាយ័ន ខេត្តសៀមរាប*

# គុណប្រយោជន៍នៃផ្លែក្រូចឆ្មារ



*ផ្លែក្រូចឆ្មារគឺជាថ្នាំបុរាណមួយដែលអាចជួយព្យាបាលបាលជំងឺផ្សេងៗ*

ផ្លែក្រូចឆ្មារគឺជាថ្នាំបុរាណមួយដែលគួរមាននៅក្នុងផ្ទះ ព្រោះក្រៅពីបន្ថែមរសជាតិទៅលើមុខម្ហូប ដែលត្រូវការជាតិជូរឱ្យមានរសជាតិឆ្ងាញ់ ហើយក៏នៅអាចជួយព្យាលបាលជំងឺផ្សេងៗបានផងដែរ។ ដើមក្រូចឆ្មារមានប្រភពនៅប្រទេសកម្ពុជា ដែលប្រជាជនកម្ពុជាយើងច្រើនដាំជាលក្ខណៈចម្ការដីទួលមិនលិចទឹក បន្ទាប់មកការដាំបានរីកសាយភាយរហូតទៅដល់ប្រទេសវៀតណាម និងឡាវទៀត។ ក្នុងផ្លែក្រូចឆ្មារចំនួន ៥0 ផ្លែ គេអាចទាញយកនូវសារ-ជាតិរាវបាន ១ លីត្រ ក្នុងនោះមានជាតិទឹកពី ៨0 ទៅ ៨២% ជាតិអាស៊ីតស៊ីទ្រិកពី ៥ ទៅ ៧% ជាតិស៊ីត្រាតរបស់កាល់ស្យូម និងប៉ូតាស្យូមពី ១ ទៅ ២% ជាតិស៊ីត្រាអេទីល CITRATE DETH-YLE GasuIt m:alik ACIDE MALIQUE តិចតួច ក្រៅពីនោះមានជាតិស្ករអាំងទែរវ៉ាកទី INTERVERTI ស្ករសាក់ការ៉ូស SACC HA-ROSE ជាតិប្រូទីត ជីវជាតិសេ ជីវជាតិបេ ១ ជីវជាតិបេ ២។

ក្រូចឆ្មារជួយធ្វើឱ្យខួរក្បាលទទួលការចងចាំបានយូរចំពោះមនុស្សចាស់ជរា ពេលដែលបរិមាណសារធាតុ HOMOCYSTERINE កើនឡើងកាន់តែច្រើននឹងមានទាក់ទងជាមួយនឹងសមត្ថភាពចងចាំ។ ក្រុមអ្នកវិទ្យាសាស្ត្របានឱ្យដឹងថា ជនចាស់ជរាដែលបរិភោគក្រូចឆ្មារពិតជាទទួលបានការចងចាំបានច្រើនជាងមនុស្សចាស់ជរាដែលមិនបានបរិភោគផ្លែក្រូចឆ្មារដោយសារតែផ្លែក្រូចឆ្មារសម្បូរទៅដោយជីវជាតិសេ និងជាតិ FOLATE.

បរិភោគក្រូចឆ្មារបានច្រើនពិតជាជួយធ្វើឱ្យសុខភាពគ្រោងឆ្អឹងកាន់តែល្អថែមទៀត ដោយសារតែជាតិក្រូចឆ្មារជួយធ្វើឱ្យមានតុល្យភាពនៃបរិមាណអាស៊ីតក្នុងរាងកាយ និងវីតាមីសេជួយធ្វើឱ្យឆ្អឹងកាន់តែរឹងមាំថែមទៀត។

ក្រូចឆ្មារជួយកម្ចាត់ជាតិពុលនិងជួយសម្អាតថ្លើម ដោយយកផ្លែក្រូចឆ្មារស្រស់មកច្របាច់យកទឹក ហើយលាយជាមួយទឹកដាំពុះរួចពិសារៀងរាល់ព្រឹកព្រលឹមពិតជាបានជួយសម្អាតថ្លើម ហើយកាន់តែមានប្រសិទ្ធភាពក្នុងការកម្ចាត់ជាតិពុល។ ពិសាទឹកក្រូចឆ្មារពិតជាជួយដល់រាងកាយផលិតទឹកប្រមាត់ ជួយសម្អាតក្រពះ ពោះវៀន ឱ្យកាន់តែមានភាពល្អប្រសើរថែមទៀត។

## ក្រូចឆ្មារព្យាបាលជំងឺដុះសាច់បំពង់ក

គ្រាន់តែលាយទឹកក្រូចឆ្មារជាមួយទឹកឃ្មុំ និងកំបោរស ផ្សំចូលគ្នាផឹក ក៏ព្យាបាលជំងឺដុះសាច់បំពង់កបានដែរ។

## ក្រូចឆ្មារព្យាបាលជ្រាំង ពងបែក និងស្លេស្ម

គ្រាប់ក្រូចឆ្មារអាចបណ្តេញស្លេស្ម ព្យាបាលរោគជ្រាំងអណ្តាតរបស់ក្មេង និងព្យាបាលពងបែកក្នុងមាត់។

## ក្រូចឆ្មារព្យាបាលសំឡេងស្អក :

ក្រូចឆ្មារអាចធ្វើឱ្យសំឡេងមិនស្អកបាន។ នៅពេលព្រឹក គ្រាន់តែយកក្រូចឆ្មារមួយចំហៀងបៀមអំបិលច្របាច់ក្រូច រួចលេបរាល់ព្រឹក និងបាត់សំឡេងស្អកជាមិនខាន។

## ក្រូចឆ្មារកាត់បន្ថយជំងឺគ្រុន :

គ្រាន់តែយកស្លឹកក្រូចឆ្មារហាន់ជាចម្រៀកៗឆុងជាមួយនឹងទឹកក្តៅផឹកក៏អាចជួយបន្ធូរបន្ថយអាការៈគ្រុន និងបៀមជាមួយអំបិល ក៏អាចសម្លាប់មេរោគបានដែរ។

## ក្រូចឆ្មារព្យាបាលហូរឈាមតាមជើងធ្មេញ :

ប្រសិនបើមានឈាមហូរចេញតាមជើងធ្មេញគឺអាចមកពីកង្វះវិតាមីន C ធ្វើឱ្យហើមអញ្ចាញ និងមានឈាមហូរចេញតាមជើងធ្មេញជាប្រចាំ ដូចនេះអាចទទួលទានក្រូចឆ្មារ និងបន្ថែមជាតិជូរ ឬ យកក្រូចឆ្មារមកដុសជើងធ្មេញ ដើម្បីឃាត់ឈាមមួយរយៈ។

## ក្រូចឆ្មារព្យាបាលហើមអញ្ចាញ :

យកសំឡីមកផ្តិតជាមួយក្រូចឆ្មារជូតអញ្ចាញមួយថ្ងៃ ២ ដង ពេលព្រឹក និងល្ងាច នឹងធ្វើឱ្យបាត់ និងមិនកើតអាការៈហើមអញ្ចាញបានយ៉ាងមានប្រសិទ្ធភាព។

តាមការសិក្សាស្រាវជ្រាវកាលពីពេលថ្មីៗនេះរបស់ក្រុមអ្នកវិទ្យាសាស្ត្រនៅសកលវិទ្យា-ល័យ HAWAI បានឱ្យដឹងថា ការបរិភោគផ្លែក្រូចឆ្មារក៏ដូចជាការបរិភោគផ្លែក្រូចប្រភេទផ្សេងៗទៀតផងដែរសុទ្ធតែមានសមត្ថភាពជួយទប់ស្កាត់ករណីមហារីកបានយ៉ាងប្រសើរបំផុត នោះក៏ដោយសារ ក្រូចឆ្មារមានផ្ទុកទៅដោយសារជាតិ FLAVONOID ជួយទប់ស្កាត់រាល់ប្រភពទាំងឡាយ ដែលឈានដល់កើតមានជំងឺមហារីក ដែលអាចមានដោយសារតែករណីកើតប្រតិកម្មអុកស៊ីសែនបង្កឡើង។

ដើម្បីទទួលបានផលប្រយោជន៍ខ្ពស់ អ្នកគួរតែពិសាផ្លែក្រូចឆ្មារដូចគ្នា និងការពិសារផ្លែក្រូចថ្លុង ឬ បើពិសាទឹកក្រូចឆ្មារជាប្រចាំថ្ងៃនោះ គឺកាន់តែប្រសើរថែមទៀត។/

# កំពង់ឆ្នាំង ៖ ទិន្នផលស្រូវនៅតំបន់ផលិតស្រូវប្រាំងតេជោសែនទី ២ កើនឡើងបួនដង



*ភោគផលស្រូវកើនឡើងជាលំដាប់របស់ប្រជាកសិករនៅតំបន់ផលិតស្រូវប្រាំងតេជោសែនទី ២*

តំបន់ផលិតស្រូវប្រាំងសម្ដេចតេជោសែនទីពីរ នៅក្នុងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង បានធ្វើឱ្យ ប្រជាកសិករទទួលទិន្នផលស្រូវកើនឡើងបួនដងក្នុងរយៈពេលមួយរយថ្ងៃ។ ពេលនេះកសិករមួយចំនួនកំពុងឈានទៅធ្វើស្រែឱ្យបានពីរដងក្នុងមួយឆ្នាំ។ មុននេះនៅទីនោះក្នុងមួយឆ្នាំនៅលើផ្ទៃដីមួយហិកតាទទួលផលស្រូវឡើងទឹកប្រមាណ ១,២ តោន ទៅ ២ តោនប៉ុណ្ណោះ តែបច្ចុប្បន្នកសិករអាចទទួលបានពី ៤ ទៅ ១០ តោន លើផ្ទៃដីដូចគ្នា។ ការប្រែប្រួលនេះកើតឡើងបន្ទាប់ពីការផ្លាស់ប្ដូរពីការធ្វើស្រូវឡើងទឹកមកជាការធ្វើស្រូវប្រាំងវិញរបស់កសិករដែលមានជំនួយពីក្រសួងធនធានទឹក។

លោក *អ៊ុក ញូន* ប្រធានភូមិស្រះកែវ និងជាជំនួយការសហគន៍តំបន់ផលិតស្រូវប្រាំងតេជោសែនទីពីរ នៅក្នុងឃុំមេលំ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំងនិយាយឱ្យដឹងថា សព្វថ្ងៃប្រជាកសិករមានក្ដីសប្បាយរីករាយខ្លាំងណាស់នៅពេលធ្វើស្រែបានស្រូវគិតជាលុយក្នុងមួយហិកតាដល់ជាងបួនលានរៀល ក្នុងរយៈពេលមួយរយថ្ងៃ ដែលកាលពីមុនក្នុងមួយរដូវធ្វើស្រូវឡើងទឹកបានច្រើនបំផុតពី ៩០ ម៉ឺនរៀល ទៅមួយលានរៀលប៉ុណ្ណោះ។

រំឭកទៅរកអតីតកាលកន្លងទៅ លោកមេភូមិរូបនោះបានបញ្ជាក់ថា ពីមុនតំបន់ផលិតស្រូវនេះជាតំបន់លិចទឹក។ ប្រជាកសិករធ្វើស្រូវឡើងទឹកបានផលមិនទៀងទាត់។ ទឹកធំក៏បានផលតិចទឹកតូចក៏បានផលតិច។ ឆ្នាំខ្លះមិនទទួលបានផលសោះក៏មាន ។ ផលទទួលបានច្រើនបំផុតក្នុងមួយហិកតាពី ១,២ តោន ទៅ ២ តោន គឺអស់ហើយ មិនមែនទទួលបាន ពី ៤ តោន ដល់ ១០ តោន ក្នុងរយៈពេល ៨៥ ថ្ងៃ ដូចជាស្រូវប្រាំងដែលកំពុងតែធ្វើ និងប្រមូលផលនេះទេ។ លោកបានបន្តថាអ្វីដែលប្រែប្រួលនាពេលនេះ គឺផ្ដើមចេញពីការគិតគូរបស់រាជរដ្ឋាភិបាលតាមរយៈក្រសួងជំនាញ និងការបញ្ជ្រាបនូវបច្ចេកទេសថ្មី ការប្រើពូជថ្មី និងការផ្លាស់ប្ដូរទម្លាប់ថ្មីរបស់កសិករ។ កត្តាសំខាន់គឺកត្តាទឹក និងដំណោះស្រាយប្រព័ន្ធធារាសាស្ត្រ។

ក្នុងសម្លៀកបំពាក់ជាកសិករ លោក *ឈុន មន* អនុប្រធានសហគមន៍ផលិតស្រូវប្រាំងតេជោសែនទីពីរបាននិយាយថា ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រជាបន្តបន្ទាប់បានធ្វើឱ្យជីវភាពរបស់ប្រជាពលរដ្ឋជាងបីរយគ្រួសារនៅភូមិស្រះកែវធូរធារដោយសារការបង្កបង្កើនផលស្រូវប្រាំងទទួលបានមិនត្រឹមតែគ្រប់គ្រាន់សម្រាប់ហូបទេ គឺនៅសល់ស្រូវ អង្ករ សម្រាប់លក់ដូរបានថែមទៀតផង ។ កាលពីមុននេះប្រជាជនធ្វើស្រែប្រវាស់ទឹកនៅឆ្នាំណាទឹកឡើងធំលិចស្រូវខូចអស់។ ឆ្នាំណាទឹកតូចឡើងមិនដល់ ស្រូវគ្មានបានផល ធ្វើឱ្យជីវភាពរបស់ ប្រជាពលរដ្ឋលំបាកព្រោះប្រភពចំណូលខ្សត់ខ្សោយថែមទាំងមិនទៀងទាត់។ លោកបានរំឭកទៀតថា នាគ្រានោះ គ្រួសារខ្លះបានចេញពីភូមិទៅរកការងារធ្វើនៅខាងក្រៅ តែចាប់តាំងពីក្រសួងធនធានទឹកធ្វើទំនប់ជីកប្រឡាយរួចមកប្រជាជនឈប់ធ្វើស្រែប្រវាស់ទឹក (ស្រូវឡើងទឹក) ទៀតហើយគឺធ្វើស្រូវប្រាំងបានផលច្រើនហូបមិនអស់។ ភាពម្ចាស់ការបានលើបញ្ហាទឹក បានធ្វើឱ្យកសិករមានសង្ឃឹមចំពោះ





*ឯកឧត្តម **លឹម គានហោ** ពិនិត្យសកម្មភាពបូមទឹកបញ្ចូលស្រែប្រជាកសិករនៅតំបន់ផលិតស្រូវប្រាំងតេជោសែនទី ២*



*ប្រជាកសិករនៅតំបន់ផលិតស្រូវប្រាំងតេជោសែនទី ២ ច្រូតកាត់ប្រមូលភោគផលស្រូវដោយគ្រឿងចក្រ*

ការងារដាំដុះរបស់ពួកគេ។

កសិករឈ្មោះ *គីម ហួរ* ដែលមានដីស្រែបួនហិកតានៅភូមិស្រះកែវ ឃុំមេលំ បាននិយាយដោយក្តីរីករាយថា ទិន្នផលស្រូវប្រាំងទទួលបានពេលនេះ បើប្រៀបធៀបទៅនឹងផលស្រូវឡើងទឹកគឺខុស គ្នា ឆ្ងាយណាស់ ។ ពីមុនធ្វើស្រូវឡើងទឹកអត់បានផលច្រើនជាងបាន ។ បើបានផលវិញក៏បានទិន្នផលមិនខ្ពស់ដែរ។ *គីម ហួរ* បន្ថែមថា គឺខុសពីផលស្រូវប្រាំងដែលធ្វើនាពេលមុនក្នុងពេលនេះមួយហិកតាទទួលបានផលចាប់ពីប្រាំតោនឡើង។នៅលើផ្ទៃដីស្រែបួនហិកតារបស់គាត់ក្នុងមួយរដូវប្រមូលផលកន្លងទៅនេះបានជាង ២០ តោន។ ទូទាត់លើការចំណាយ និងទុកហូបរួចនៅសល់ស្រូវជាង ១០ តោន សម្រាប់លក់។

លោក *ដោក ប៊ុនថុន* ប្រធានមន្ទីរធនធានទឹកខេត្តកំពង់ឆ្នាំងបានប្រាប់ថា តំបន់ផលិតស្រូវប្រាំងសម្តេចតេជោសែនទី២នៅស្រុកបរិបូណ៌និងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង គឺអាចផលិតស្រូវប្រាំងបានជាង ៦០០ ហិកតា នៅក្នុងចំណោមផ្ទៃដីជាងមួយពាន់ហិកតា។ អាងទឹក ២០ ឧសភាមានទឹកអាចធ្វើស្រែប្រាំងបានដល់ជាងមួយពាន់ហិកតា តែដោយសារមិនទាន់មានប្រឡាយគ្រប់គ្រាន់ទើបធ្វើមិនអស់ផ្ទៃដីដែលមាន ។ពេលនេះក្រសួងកំពុងតែធ្វើប្រឡាយមេទី ២ មួយខ្សែទៀត។ នៅមានប្រឡាយរងនិងប្រឡាយតូចៗជាច្រើនទៀតត្រូវធ្វើជាបន្តបន្ទាប់។

តំបន់ផលិតស្រូវប្រាំងសម្តេចតេជោសែនទីពីរ ស្ថិតក្នុងឃុំមេលំ ស្រុកបរិបូណ៌ត្រូវបានរៀបចំបង្កើតឡើងនៅក្នុងឆ្នាំ ២០១២ ដោយក្រសួងធនធានទឹក និងឧតុនិយម នៅពេលបន្ទាប់ពីសិក្សាឃើញថាតំបន់លិចទឹកនេះអាចធ្វើស្រូវប្រាំងបាន និងទទួលផលច្រើនជាងស្រូវឡើងទឹក។ ក្រសួងបានរៀបចំស្តារទំនប់អាងទឹក ២០ ឧសភា ឬទំនប់សាបអង្កាមឡើងវិញ ហើយពេលនេះកំពុងតែបន្តជីកប្រឡាយរង ដើម្បីបញ្ជូនទឹកឱ្យបានទៅដល់ស្រែនៅឆ្ងាយៗ និងរៀបចំធ្វើប្រឡាយបណ្តែត ។ ឆ្នាំនេះ ក្រៅពីធ្វើស្រូវប្រាំងបានជាងប្រាំមួយរយហិកតា នៅមានដំណាំជាច្រើនរយហិកតាទៀត។ពេលនេះប្រជាកសិករកំពុងរៀបចំដីស្រែប្រាំងធ្វើឡើងវិញម្តងទៀតឱ្យបានពីរដងក្នុងមួយឆ្នាំ។

លោក *ចាន់ យុត្ថា* អ្នកនាំពាក្យ និងជានាយកខុទ្ទល័យក្រសួងធនធានទឹកបានប្រាប់ទស្សនាវដ្តីប្រជាជនថា ការបង្កើតតំបន់ផលិតស្រូវប្រាំងតេជោសែនទី ២ នៅក្នុងខេត្តកំពង់ឆ្នាំងនេះគឺបានធ្វើឡើងបន្ទាប់ពីការបង្កើតតំបន់ផលិតស្រូវប្រាំងសម្តេចតេជោសែនទី ១ នៅក្នុងខេត្តបាត់ដំបងទទួលបានជោគជ័យរួចមក ។ តំបន់ផលិតស្រូវប្រាំង តេជោសែនទី ១ នៅក្នុងស្រុកថ្មគោលខេត្តបាត់ដំបងដែលក្រសួងធនធានទឹកបង្កើតឡើង គឺក្នុងបំណងកែប្រែទម្លាប់កសិករនៅក្នុងខេត្តបាត់ដំបងដែលធ្វើតែស្រូវវស្សាឱ្យមកធ្វើស្រូវប្រាំងវិញ។ ការធ្វើស្រូវប្រាំងនៅពេលដំបូងមានចំនួនប្រមាណ ៨០០ ហិកតាទេ តែពេលនេះផ្ទៃដីស្រូវប្រាំងនៅតំបន់ផលិតស្រូវប្រាំងតេជោសែនទី ១ បានកើនឡើងដល់ជាងមួយម៉ឺនហិកតា និងកំពុងមានការកើនឡើងថែមទៀត។ ក្រសួងកំពុងតែសម្លឹងរកមើលតំបន់ផលិតស្រូវប្រាំងតេជោសែនទី ៣ ដែលជាកន្លែងមានប្រភពទឹកគ្រប់គ្រាន់ ហើយកសិករមិនបានធ្វើស្រែប្រាំង ដូចជានៅអាងត្រពាំងថ្មជាដើម។

ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹកមានប្រសាសន៍ប្រាប់ទស្សនាវដ្តីប្រជាជនថា មូលហេតុនាំឱ្យមានការបង្កើតតំបន់ផលិតស្រូវប្រាំងសម្តេចតេជោសែនទី ២ នេះឡើង ដោយសារបានទទួលជោគជ័យខ្លាំងនៅតំបន់ផលិតស្រូវប្រាំងតេជោសែនទី ១ ក្នុងខេត្តបាត់ដំបង។ តំបន់ផលិតស្រូវប្រាំងតេជោសែនទី ២ នេះ ជាតំបន់លិចទឹក ប្រជាជនធ្វើស្រូវឡើងទឹកជួបការលំបាកច្រើន ដូច ជាខូះខាតពូជ ទទួលបានទិន្នផលទាបក្នុងមួយឆ្នាំ ធ្វើបានតែម្តង ស្រូវមានតម្លៃថោក ការធ្វើស្រែពឹងលើធម្មជាតិ( ទឹកតូចពេកធ្វើមិនកើតទឹកធំពេកខូចស្រូវអស់) កត្តាទាំងនេះមិនអាចធ្វើឱ្យជីវភាពរបស់ប្រជាជនធូរធារបានទេ។ ផ្ទុយទៅវិញការបង្កើតឡើងតំបន់ផលិតស្រូវប្រាំងតេជោសែនទី ២ នេះ បានធ្វើឱ្យកសិករផ្លាស់ប្តូររបៀបដាំដុះពីស្រូវឡើងទឹកទៅស្រូវស្រាល( ពូជស្រូវមានគុណភាពខ្ពស់ ) និងដំណាំបន្លែផ្សេងៗទៀតដូចជាឪឡឹកជាដើម ។ ងាយស្រួលរកពូជស្រូវ និងបន្លែ ហើយទិន្នផលទទួលបានខ្ពស់ ឯតម្លៃស្រូវអង្ករក៏ខ្ពស់។ កសិករអាចផលិតស្រូវប្រាំងបានពីរដងក្នុងមួយឆ្នាំ។ កត្តាទាំងនេះបានធ្វើឱ្យជីវភាពរបស់បងប្អូនប្រជាកសិករមានការរីកចម្រើនឆាប់រហ័ស។

នៅក្នុងការបង្កើតតំបន់ផលិតស្រូវប្រាំងតេជោសែនទី ២ នេះ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ក្រៅពីការជួយរៀបចំឱ្យមានរចនាសម្ព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ ឯកឧត្តមនៅបានជួយជាគោយន្តប្រាំគ្រឿងម៉ាស៊ីនបូមទឹកខ្នាតតូច និងខ្នាតធំចំនួន ១០ គ្រឿង ដល់តំបន់ដែលកំពុងមានការអភិវឌ្ឍនេះថែមទៀតផង។/

# រោគភ្លេច

(បទពាក្យ ៧)

១-ជិតដាច់ខ្យល់ស្លាប់ស្រាប់ដង្ហោយ ហៅអ្នកផងឱ្យជួយអាសា
បន់សូមបានរស់ខ្លួនប្ដេជ្ញា តាំងចិត្តសច្ចាមិនភ្លេចគុណ ។
២-គ្មានចង់បានអ្វីក្រៅជីវិត ធ្វើអ្វីមិនគិតទោះស្រាលធ្ងន់
សូមតែមួយឆ្អែតអរពេកពន់ គ្មានគិតលោភលន់បុណ្យមាសប្រាក់ ។
៣-ពេលរួចផុតទុក្ខអរពេកក្រៃ ជនខ្លះសប្បាយភ្លេចសច្ចៈ
កំហឹងក្ដៅធំប្រែត្រជាក់ ភ្លេចគុណជំពាក់ហាក់រសាយ ។
៤- ឈឺខ្លាំងតាំងយកដីរបន់ ពេលជំងឺគ្រាន់ពងមាន់ស្ដាយ
នេះជំងឺភ្លេចប្រចាំកាយ គួរជនទាំងឡាយគិតពិចារ ។
៥-ពេលខឹងច្រឡោតកាប់ទាត់ធាក់ តែពេលត្រជាក់មួយកែវស្រា
ស្រវឹងចូលពោះភ្លេចទោសា បណ្ដោយអាត្មាភ្លេចភ្លាំងបាន ។
៦-ឆាប់ខឹងចាប់ភ្លេចម្ដេចមិនចាំ អស់ជាងបីឆ្នាំយំគ្រប់ប្រាណ
ដល់ពេលបានឆ្អែតភ្លេចប្រមាណ សមពាក្យបូរាណមានភ្លេចក្រ ។
៧-លោភលន់ភ្លេចខ្លួនពួនសម្ងំ មាសប្រាក់ស្ដុកស្ដម្ភភ្លេច ខ្មៅ-ស
រកស៊ីខុសច្បាប់ភ្លេចផ្លូវធម៌ ចង់មានភ្លេចក្របួរក្ដីស្លាប់ ។
៨- មានកង់ចង់ជិះម៉ូតូឡាន គិតខាងតែបានចង់មានឆាប់
អប់រំផ្លូវល្អពុំស្ដាប់ ប្រព្រឹត្តខុសច្បាប់ទោសទុក្ខខ្លាំង ។
៩- ជួញកេរវប្បធម៌ឈើថ្មឆ្លាក់ ប្ដូរយកមាសប្រាក់លាក់បិទបាំង
ជក់ជួញថ្នាំញៀនចង់មានខ្លាំង ភ្លេចពាក្យសច្ចំថា ដឹងគុណ ។

*ដោយ : ឯកឧត្តម **អ៊ុយ លីវ***
*សមាជិកក្រុមប្រឹក្សាខេត្តបាត់ដំបង*

## ស្នាមជ្រួញ



បុរសពីរនាក់អង្គុយសន្ទនាគ្នាលេង ។ បុរសម្នាក់សួរ :

-នែឯងដឹងទេ មនុស្សប្រុសស្រីចាប់ពីអាយុ ៣០ ឆ្នាំឡើងទៅតែងបង្ហាញស្នាមជ្រីវជ្រួញលើផ្ទៃមុខដូចគ្នា តែម៉េចក៏ស្នាមជ្រួញមនុស្សប្រុសផ្ដេកទទឹងមុខ ចំណែកស្នាមជ្រួញរបស់មនុស្សស្រីបញ្ឈរបណ្ដោយមុខ ?

- អេហ៎...គ្នាធ្វើម៉េចដឹងទៅ...

-មានអីពិបាកយល់...នេះមកពីប្រពន្ធច្រើនសួរថា "ឯណាលុយ?" ។ ពេលនិយាយពាក្យទាំងនេះតែងជ្រួញចិញ្ចើម ហេតុហ្នឹងហើយ ទើបស្នាមជ្រួញលេចឡើងបណ្ដោយផ្ទៃមុខ ។ ចំណែកប្ដីពេលឮសួរដូច្នោះ តែងសួរតបវិញ "លុយស្អី ?" ពេលនិយាយពាក្យនេះគឺបើកភ្នែកធំៗ ។ ហេតុហ្នឹងហើយទើបលេចស្នាមជ្រួញទទឹងមុខ ។

## ស្ដាយណាស់

កំពុងផឹកកាហ្វេជាមួយគ្នា យុវជនម្នាក់និយាយប្រាប់មិត្តរបស់ខ្លួន :

-គ្នាមានដំណឹងល្អមួយ អាក្រក់មួយត្រូវប្រាប់ឯង តើចង់ស្ដាប់មួយណាមុន?

-ប្រាប់ដំណឹងល្អមុនមក !

-បាន...ដំណឹងល្អគឺ នាងស្រីស្រស់ដែលអង្គុយរៀននៅតុខាងក្រោយខ្នងឯងនោះយល់ព្រមទៅដើរលេងជាមួយឯងហើយ ។

- មែនឬ? ចុះដំណឹងអាក្រក់?

-គឺនាងផ្ដាំតាមយើងណាត់ដើរលេងជាមួយឯងនៅល្ងាចថ្ងៃសៅរ៍ម្សិលមិញ ព្រោះឪពុកម្ដាយនាងអត់នៅផ្ទះ ប៉ុន្តែគ្នាភ្លេចប្រាប់ឯង ទាល់តែដល់ពេលនេះជួបមុខទើបនឹកឃើញ..... ។

-អើយ....ចង្រៃយក៏ ស្ដាយណាស់ ។

## ដបស្រាស្មោះ

ថ្ងៃមួយ យាយម៉ៃ និយាយត្អូញត្អែរប្រាប់យាយ ម៉ាច ជាមិត្ត :

-កាលពីម្សិលមិញពេលឮពុកវានិយាយរង្វ៉ូវៗម្នាក់ឯងថា "សំណាងបងណាស់ដែលអូនឯងនៅតែស្អាត ស្រស់បំព្រងសម្រាប់ បង" ខ្ញុំរិះទ្រាំមិនបានចង់ស្ទុះចូលទៅសំពងគាត់ឱ្យណាណើម្ដង ។

-យ៉ាងម៉េចហ្នឹង ? គាត់សរសើរយាយឯង "ស្រស់ស្អាតបំព្រង" គួរតែសប្បាយចិត្តទើបត្រូវ ហេតុអីបែរជាមួម៉ៅចង់សំពងគាត់ទៅវិញ ?

-គាត់មានសរសើរខ្ញុំឯណា? គឺគាត់និយាយជាមួយដបស្រា របស់គាត់ឯណោះតើ! ។

## អត់បាន

លោកគ្រូសួរសិស្សក្នុងថ្នាក់របស់ខ្លួន :

-ឧបមាថា ឆ្នាំទៅលោកគ្រូកើតបានកូនភ្លោះ ២ នាក់ ហើយឆ្នាំនេះលោកគ្រូកើតបានកូនម្នាក់ទៀត តើលោកគ្រូកើតកូនសរុបបានប៉ុន្មាននាក់ ?

ក្នុងថ្នាក់ស្ងាត់ឈឹង ។ មួយសន្ទុះស្រាប់តែសិស្សតូចម្នាក់លើកដៃឆ្លើយ :

-បាទ....លោកគ្រូអត់មានកើតកូនបានម្នាក់ទេ!

លោកគ្រូបើកភ្នែកធំៗ :

-ឆ្នាំទៅលោកគ្រូកើតកូនបានពីរនាក់ ឯឆ្នាំនេះកើតបានម្នាក់ ទៀត សរុបពនាក់ទើបត្រូវ ។ ហេតុម៉េចថា គ្រូអត់បានកើតកូនបានម្នាក់សោះទៅវិញ?

-បាទ...ព្រោះលោកគ្រូជាបុរសកើតកូនបានយ៉ាងម៉េចទៅ ? ឆ្នាំទៅមិញក៏លោកគ្រូ កើតកូនអត់បាន ឆ្នាំនេះក៏លោកគ្រូកើតកូនអត់បានដូចគ្នា ហេតុនេះលោកគ្រូអត់មានកើតកូនបានម្នាក់សោះឡើយ ។/

### សេចក្ដីកែតម្រូវ

ទស្សនាវដ្ដីប្រជាជនសូមធ្វើការកែតម្រូវខ្លឹមសារអត្ថបទចេញផ្សាយក្នុងលេខ ១៥៤ ខែមីនា ឆ្នាំ ២០១៤ ទំព័រទី ១៥ ក្នុងសកម្មភាព ឯកឧត្តមបណ្ឌិត **ខួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី ១ នៃរដ្ឋសភា ដែលបានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធ និងបុណ្យឆ្លងសមិទ្ធផលនានាក្នុងវត្តមង្គលវ៉ែន និងវត្តនិរន្ទកោសីយ៍ ក្នុងស្រុកបារាយណ៍ និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នៅឃ្លាចុងក្រោយនៃអត្ថបទ សូមដាក់ថា សរុបថវិកាចំណាយទាំងអស់ចំនួន ៦៨.៤៦៥.000 រៀល ។

**សូមអរគុណ**

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# **អ្នកឧបត្ថម្ភ** ទស្សនាវដ្ដី ប្រជាជន លេខ ១៥៥

| | | | | |
|---|---|---|---|---|
| ១- | ឯ.ឧ | **កែ គឹមយ៉ាន** | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ២- | ឯ.ឧ | **ចម ប្រសិទ្ធ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលោកជំទាវ | ២០០ ដុល្លារ |
| ៣- | ឯ.ឧ | **មិន ឃិន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ឆួន** | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | **ត្រាំ អ៊ីវតឹក** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | **ថោង ខុន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | **លន់ លឹមថៃ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | **ជៀង អំ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | **ស្បោង សារ៉ាត** | ប្រធានគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | **ខុយ សុខា** | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តពោធិសាត់ | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | **អូស្មាន ហាស្សាន់** | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | **សរ ចន្ទ័រុង** | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | **ផា សុជាតិវង្ស** | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | **ម៉ម ប៊ុននាង** | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | **ប្រាក់ ចំរើន** | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | **អ៊ឹន វីរជាតិ** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | **យូ តិរម្យ** | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់ | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | ១០០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | ៥០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | ៥០ ដុល្លារ |
| ២២- | ឯ.ឧ | **លឹម គានហោ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ២០០.០០០ ៛ |
| ២៣- | ឯ.ឧ | **ម៉ម ប៊ុនហេង** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៤- | ឯ.ឧ | **ថា យ៉ាវ** | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ២៥- | ឯ.ឧ | **ជូ យិនស៊ីម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៦- | ឯ.ឧ | **អ៊ុក ប្រាថ្នា** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | **ប៉ាវ ហាមផាន** | អនុប្រធានគណៈកម្មាធិការគណបក្សខេត្តរតនគិរី | ៥០ ដុល្លារ |
| ២៨- | ឯ.ឧ | **សូ ដុងហួរ** | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | **ចាយ បូរិន្ទ** | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | **នរៈ រតនៈវឌ្ឍនោ** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣១- | ឯ.ឧ | **ឃួន រ៉ានីន** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | **ប៊ុន លឹមហេង** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៣៣- | ឯ.ឧ | **សេង ឆៀង** | ជំនួយការផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ២០០.០០០៛ |
| ៣៤- | ឧកញ៉ា | **ម៉ក់ គឹមហុង** | ប្រធានអគ្គនាយកចំការកៅស៊ូជប់ | ២០០.០០០៛ |
| ៣៥- | ឯ.ឧ | **ម៉ៅ ប៊ុនណារិន** | សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា | ១០០.០០០៛ |
| ៣៦- | ឯ.ឧ | **ម៉ែន ស៊ំផាន់** | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៣៧- | ឯ.ឧ | **សុន គន្ធរ** | រដ្ឋមន្ត្រីប្រតិភូអមសម្ដេចនាយករដ្ឋមន្ត្រី | ១០០.០០០៛ |
| ៣៨- | ឯ.ឧ | **ប៉ាន ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៣៩- | លោកជំទាវ | **ស៊ឹង ស៊ុំយុត** | | ១០០.០០០៛ |
| ៤០- | ឯ.ឧ | **គឹម ឆា** | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤១- | ឯ.ឧ | **គាំម កុសល** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤២- | ឯ.ឧ | **ប៊ិច សុវណ្ណា** | | ១០០.០០០៛ |
| ៤៣- | ឯ.ឧបណ្ឌិត | **មាស ប៉ូ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៤៤- | លោកជំទាវ | **និត្យ ច័ន្ទតារីន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | **ឆា ច័ន្ទលីដា** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | **ម៉ែន វិបុល** | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៧- | លោក | **អោម ចន** | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | **ថ្កូន ថេរ៉ាវ៉ាត** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី ហេង សំរិន | ១០០.០០០៛ |
| ៤៩- | ឯ.ឧ | **ម៉ៅ ឡាំង** | ទីប្រឹក្សាឯកឧត្ដម **ខួន សុទ្ធារី** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៥០- | ឯ.ឧ | **ឆាយ ឬទ្ធិសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៥១- | លោក | **សាំ ពិសិដ្ឋ** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥២- | ឯ.ឧ | **អ៊ុន ឆាលី** | អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង | ១០០.០០០៛ |
| ៥៣- | លោក | **សុខ វិសាលសម្បត្តិ** | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំផ្អៅ១ ស្រុកស៊ីធរកណ្ដាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល ... | ១០០.០០០៛ |
| ៥៤- | លោកជំទាវ | **ខេង សំវ៉ាដា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ៥០.០០០៛ |
| ៥៥- | ឯ.ឧ | **សាយ បូរិន** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ៥០.០០០៛ |
| ៥៦- | ឯ.ឧ | **សេង គឹមសាន** | ជំនួយការសម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** | ៥០.០០០៛ |
| ៥៧- | ឯ.ឧ | **ពត ចាន់នី** | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |
| ៥៨- | ឯ.ឧ | **ហេង វណ្ណា** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៩- | លោក | **ជា វុទ្ធី** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦០- | លោកជំទាវ | **ស៊ៀ ច័ន្ទថា** | | ៥០.០០០៛ |
| ៦១- | លោក | **ហួត ពៅ** | ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៥៥

| | | | | | |
|---|---|---|---|---|---|
| ៦២- | កញ្ញា | ផាន | និតហ្វើរ | មន្ត្រីក្រសួងទេសចរណ៍ ........ | ៥០.០០០៛ |
| ៦៣- | លោក | ចៅ | ម៉េងជួន | អភិបាលក្រុងប៉ោយប៉ែត ........ | ៥០.០០០៛ |
| ៦៤- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ........ | ៥០.០០០៛ |
| ៦៥- | លោក | កែវ | សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ........ | ៥០.០០០៛ |
| ៦៦- | លោក | សួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ ........ | ៥០.០០០៛ |
| ៦៧- | លោក | គាត | ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ ........ | ៥០.០០០៛ |
| ៦៨- | លោក | ចាប | ឌីណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ ........ | ៥០.០០០៛ |
| ៦៩- | ឯ.ឧ | វេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ........ | ៤០.០០០៛ |
| ៧០- | លោក | លី | សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ ........ | ៤០.០០០៛ |
| ៧១- | លោក | គីម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ ........ | ៤០.០០០៛ |
| ៧២- | គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | ........ | ៤០.០០០៛ |
| ៧៣- | ឯ.ឧ | ស៊ិន | ទុន្នី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក ........ | ៣០.០០០៛ |
| ៧៤- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ ........ | ៣០.០០០៛ |
| ៧៥- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ ........ | ៣០.០០០៛ |
| ៧៦- | លោក | ចាន់ | ស៊ីណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក ........ | ៣០.០០០៛ |
| ៧៧- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក........ | ៣០.០០០៛ |
| ៧៨- | លោក | ទេព | វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ ........ | ៣០.០០០៛ |
| ៧៩- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា ........ | ២៥.០០០៛ |
| ៨០- | ឯ.ឧ | ចុង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ ........ | ២០.០០០៛ |
| ៨១- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ២០.០០០៛ |
| ៨២- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ២០.០០០៛ |
| ៨៣- | លោក | លឹម | វីរក្ស | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ២០.០០០៛ |
| ៨៤- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល........ | ២០.០០០៛ |
| ៨៥- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម ........ | ២០.០០០៛ |
| ៨៦- | លោក | ឡឹក | សន | អនុប្រធានមន្ទីរគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង ........ | ២០.០០០៛ |
| ៨៧- | លោក | ជា | គឹមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា ........ | ២០.០០០៛ |
| ៨៨- | ឯ.ឧ | ទេស | ច័ន្ទគិរី | សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប ........ | ២០.០០០៛ |
| ៨៩- | លោក | ទូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ ........ | ២០.០០០៛ |
| ៩០- | លោក | ហ៊ួង | ជ្រិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង ........ | ២០.០០០៛ |
| ៩១- | លោក | ម៉ុ | វុឌ្ឍា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង ........ | ២០.០០០៛ |
| ៩២- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ ........ | ២០.០០០៛ |
| ៩៣- | លោក | អ៊ឹក | ទូច | ប្រជាជនភូមិអូរអរិល ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ........ | ២០.០០០៛ |
| ៩៤- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ ........ | ១៥.០០០៛ |
| ៩៥- | លោក | អ៊ុច | សាវន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ ........ | ១៥.០០០៛ |
| ៩៦- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា ........ | ១០.០០០៛ |
| ៩៧- | ឯ.ឧ | ប៉ុញ | សច្ចៈ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម ........ | ១០.០០០៛ |
| ៩៨- | លោក | ម៉ុ | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម ........ | ១០.០០០៛ |
| ៩៩- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១០០- | លោក | មឹម | ប្រួស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម ........ | ១០.០០០៛ |
| ១០១- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម ........ | ១០.០០០៛ |
| ១០២- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១០៣- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១០៤- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១០៥- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១០៦- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម ..... | ១០.០០០៛ |
| ១០៧- | លោក | ទិត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម ........ | ១០.០០០៛ |
| ១០៨- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម . | ១០.០០០៛ |
| ១០៩- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១០- | លោក | ស៊ូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១១- | លោក | ហួត | ធាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១២- | លោក | ទឹម | វុឌ្ឍារី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៣- | លោក | ណុប | វៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៤- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៥- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៦- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៧- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៨- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ........ | ១០.០០០៛ |
| ១១៩- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង ........ | ១០.០០០៛ |
| ១២០- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង ........ | ១០.០០០៛ |
| ១២១- | លោក | ឡាច | តីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង ........ | ១០.០០០៛ |
| ១២២- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង ........ | ១០.០០០៛ |






កិច្ចប្រជុំកំពូលនៃគណៈកម្មការទន្លេមេគង្គលើកទី ២ ក្រោមប្រធានបទ"សន្តិសុខទឹក ថាមពល និងស្បៀង....

៦





ទស្សនកិច្ចប្រកបដោយផ្លែផ្កា នៃប្រមុខរាជរដ្ឋាភិបាលកម្ពុជា នៅសាធារណរដ្ឋអាស៊ែបៃហ្សង់ និងសាធារណរដ្ឋបេឡារុស

៨





សម្តេចចក្រី **ហេង សំរិន** ចូលរួមពិធីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តស្ទឹងតូច នៅស្រុកពញាក្រែក

១៣



**និពន្ធនាយក :**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខៀវ ណាវី

២. លោក អ៊ឹម សុន្ទរៈ

៣. លោក វង្ស សារ៉ុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ

២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរៈមុនី

**វិចិត្រករ**

១. លោក ធា សារ៉ុធ



អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

**Address :**

**No 203 Preah**

**Norodom Bld.**

**Phnom Penh Cambodia**

**Tel : 023 219 065**


## ក្របមុខ

*ទិដ្ឋភាពផ្សេងៗនៃព្រឹត្តិការណ៍*
*អង្គរសង្ក្រាន្តលើកទី ២*
*នៅខេត្តសៀមរាប*
*ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ*
*ឆ្នាំមមី ឆស័ក ព.ស ២៥៥៨*

# មាតិកា
# Contents


*វិចារណកថា : ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ អាណត្តិទីពីរ ជាជំហានថ្មីមួយទៀតនៃដំណើរការប្រជាធិបតេយ្យ និងនីតិរដ្ឋរបស់កម្ពុជា..................*

*Editorial : Municipal and District Council Elections – a New Step in Cambodia's Democratic Process and Rule of Law..........................................................................* ៣

⇨ *ថ្ងៃ ២០ ឧសភា ជាទិវាប្រវត្តិសាស្ត្រដ៏ឈឺចាប់ដែលត្រូវចងចាំ.......................................* ៥

⇨ *សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ..............................* ១៤

⇨ *លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច..............................................................................* ១៨

⇨ *វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ កំពុងតែខិតខំឈានឱ្យទាន់ការរីកចម្រើន នៃបច្ចេកវិទ្យាទំនើប...........................................................................................* ១៩

⇨ *ការរីកចម្រើននៅក្នុងវិស័យការងារ បានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ច...............................................................................* ២១

⇨ *ខិតខំពង្រីកវិសាលភាព ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយ ..........................* ២៤

⇨ *វប្បធម៌ : អង្គរសង្ក្រាន្តលើកទី ២ បានរួមចំណែកលើកស្ទួយវប្បធម៌ជាតិ ...............................* ២៧

⇨ *វិទ្យាសាស្ត្រ សុខភាព : គុណប្រយោជន៍នៃផ្លែក្រូចឆ្មារ .....................................................* ២៨

⇨ *ទឹកដីមាតុភូមិ : កំពង់ឆ្នាំង : ទិន្នផលស្រូវនៅតំបន់ផលិតស្រូវប្រាំងតេជោសែនទី ២ កើនឡើងបួនដង ...........................................................................................* ២៩

⇨ *កំណាព្យ : រោគភ្លេច ......................... សំណើច ..................................................* ៣១

ទស្សនាវដ្ដី

# ប្រជាជន

THE PRACHEACHUN MAGAZINE




ឆ្នាំទី១៣ លេខ ១៩៨ ខែមេសា ឆ្នាំ ២០១៤










ទិដ្ឋភាពកំសាន្តសប្បាយរបស់ប្រជាជននៅតាម
រមណីយដ្ឋាននានា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី

















